ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ



# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ការិយបរិច្ឆេទ២០១៨

លេខៈ ១៣

ឆ្នាំ២០២០

# **អារម្ភកថា**

សេដ្ឋកិច្ចកម្ពុជានាឆ្នាំ២០១៨ នៅតែអាចសម្រេចបានកំណើនដ៏រឹងមាំក្នុងអត្រា**៧,៥%**។ ផ.ស.ស សម្រាប់មនុស្សម្នាក់ៗបានកើនឡើងពី **១ ៤២៩** ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ដល់ **១ ៥៤៨** ដុល្លារអាមេរិកក្នុងឆ្នាំ២០១៨។ ទន្ទឹមនឹងនេះ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំក្នុងរង្វង់**២,៥%**ក្នុងឆ្នាំ២០១៨ និងអត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំរក្សាបានក្នុងកម្រិត**៤ ០៤៥**រៀល ក្នុងមួយដុល្លារអាមេរិក។ កំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០១៨ ត្រូវបានទ្រទ្រង់ដោយវិស័យសំខាន់ៗ រួមមាន៖ (១)-កំណើនវិស័យកសិកម្មបានថយចុះពី **១,៧%** ក្នុងឆ្នាំ២០១៧ ដល់ **១,៦%** ក្នុងឆ្នាំ២០១៨ (២)-វិស័យឧស្សាហកម្មនៅរក្សាបានកំណើនដ៏រឹងមាំក្នុងរង្វង់ **១២,៣%** ក្នុងឆ្នាំ២០១៨ និង(៣)-វិស័យសេវាកម្មនៅតែបន្តកំណើនល្អប្រសើរក្នុងរង្វង់**៦,៥%** ក្នុងឆ្នាំ២០១៨។ រាជរដ្ឋាភិបាលកម្ពុជាបន្តអនុវត្តនូវគោលនយោបាយអាទិភាពរបស់ខ្លួនប្រកបដោយជោគជ័យ ដែលឆ្លុះបញ្ចាំងតាមរយៈ ១-បន្តពង្រឹងយ៉ាងម៉ឺងម៉ាត់ និងដាច់ខាតនូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ វប្បធម៌សន្តិភាព សីលធម៌សង្គម និងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងភាពសុខដុមរមនាក្នុងសង្គម ក៏ដូចជាភាពសុខក្សេមក្សាន្តរបស់ប្រជាជន ២-បន្តធានាអនុវត្តគោលនយោបាយ ដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា និងបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ដល់ប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ ៣-បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់៧% ប្រកបដោយបរិយាប័ន្ន និងចីរភាព ដើម្បីបន្តបង្កើតការងារថ្មីកាន់តែច្រើនជូនប្រជាជន ជាពិសេសសម្រាប់ស្រទាប់យុវជន និងដើម្បីផ្តល់លទ្ធភាពកាន់តែច្រើនឱ្យប្រជាជនទទួលបានប្រាក់ចំណូលកាន់តែខ្ពស់ និងបង្កើនចំណូលថវិការដ្ឋផងដែរ ៤-បន្តធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសការគ្រប់គ្រងឱ្យបាននូវអតិផរណា និងស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ ៥-បន្តផ្តល់អាទិភាពដល់ការដំឡើងបៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីសម្រេចឱ្យបានគោលដៅជាង១លានរៀលនៅឆ្នាំ២០១៨ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងបង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការឱ្យកាន់តែល្អប្រសើរដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ៦-គាំទ្រដល់ការអនុវត្តកម្មវិធីថ្មីមួយចំនួនលើវិស័យសង្គមកិច្ចក្នុងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ ឱ្យចេញជាលទ្ធផលផ្លែផ្កាបណ្តើរៗ ជាពិសេសពាក់ព័ន្ធការថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ការផ្តល់ និងបង្កើនប្រាក់ឧបត្ថម្ភដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលជាស្ត្រីនៅពេលសម្រាលកូន និងសម្រាកលំហែមាតុភាព ការបង្កើនប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព ការផ្តល់ការថែទាំសុខភាពសម្រាប់កម្មករនិយោជិត និងការផ្តល់ប្រាក់ឧបត្ថម្ភមាតុភាពដល់កម្មករនិយោជិត ស្របពេលជាមួយគ្នានឹងការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់២០១៧-២០៣០ ៧-បន្តកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាថែមទៀតក្នុងការប្រមូលចំណូល តាមរយៈការជំរុញអនុវត្តវិធានការនៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨ ជាពិសេសគឺរក្សាបានចីរភាពចំណូលជាមួយនឹងកំណើនខ្ពស់ដូចសម្រេចបានក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ទន្ទឹមនឹងបន្តការកែសម្រួលនីតិវិធី និងសេវាពាក់ព័ន្ធនឹង

ការបង់ពន្ធឱ្យកាន់តែមានភាពសាមញ្ញ និងកាន់តែងាយស្រួល មានយុត្តិធម៌ និងកាន់តែមានអភិបាលកិច្ចខ្ពស់ ៨-ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិ ដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ និងបង្កើនចំណាយវិនិយោគផ្ទាល់ដោយថវិការដ្ឋ ដើម្បីបង្កើនឯករាជ្យភាពនៃថវិកា និងកាត់បន្ថយជាបណ្តើរៗនូវការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស ៩-បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ការលើកកម្ពស់សេវាសុខាភិបាល និងអាហារូបត្ថម្ភ ១០-បន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ទាំងផ្នែករឹង និងផ្នែកទន់ សម្រាប់គាំទ្រកំណើន និងការអភិវឌ្ឍជាពិសេសផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី ទឹកស្អាត សាលារៀន និងមន្ទីរពេទ្យជាដើម ព្រមជាមួយនឹងការផ្តល់អាទិភាពលើហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ជាពិសេសទូរគមនាគមន៍សម្រាប់កសាងមូលដ្ឋានគ្រឹះក្នុងការឈានទៅអនុវត្តសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា ១១-បន្តផ្តល់អាទិភាពដល់សកម្មភាពថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានកសាងរួច ជាពិសេសផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រស្រោចស្រព ១២-បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម និងវិស័យគាំទ្រ ដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និងជំរុញការកែច្នៃ និងការនាំចេញផលិតផលកសិ-ឧស្សាហកម្ម និងកសិផល ការចិញ្ចឹមសត្វ និងវារីវប្បកម្ម រួមទាំងបន្តការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ និងសកម្មភាពអភិវឌ្ឍវិស័យកសិកម្មដែលមានភាពធន់ទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដូចជា៖ ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងការផ្ទុះជំងឺ ដើម្បីបញ្ចៀសការខូចខាតពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយទៅលើការអភិវឌ្ឍសេដ្ឋកិច្ច ១៣-បន្តជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ១៤-បន្តអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០១៥-២០១៨ ដើម្បីរក្សាចីរភាពនៃបំណុលសាធារណៈផង ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទានសម្រាប់គាំទ្រដល់កំណើនផលិតភាព និងភាពប្រកួតប្រជែងរបស់កម្ពុជា ដែលមានទំហំកាន់តែធំ ស្របទៅតាមដំណាក់កាលនៃភាពរីកចម្រើនលូតលាស់របស់សេដ្ឋកិច្ចជាតិ ១៥-គាំទ្រដល់ការអនុវត្តកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល២០១៨-២០២០ ១៦-គាំទ្រដល់ការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០ ១៧-បន្តធានាការអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាលឱ្យមានលក្ខណៈកាន់តែស៊ីជម្រៅ និងទទួលបានលទ្ធផលផ្លែផ្កាជាក់ស្តែងកាន់តែច្រើនថែមទៀត រួមទាំងការពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ជាពិសេសការលើកកម្ពស់គុណភាព និងពង្រីកការទទួលបានភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ ក៏ដូចជាដើម្បីផ្តល់នូវអត្ថប្រយោជន៍ផ្ទាល់ដល់ប្រជាជនទូទៅ ១៨-ធានាភាពជោគជ័យនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦។ ជាក់ស្តែង ចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៨ កើនឡើង **១៨,៧%** និងចំណូលសារពើពន្ធបានកើនឡើង **១៩,១%** ធៀបនឹងការអនុវត្តឆ្នាំ២០១៧ ចំណូលថវិការបស់រាជធានី ខេត្តឆ្នាំ២០១៨ កើនឡើង ៦០,៣២% បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៧ និងចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ឆ្នាំ២០១៨ កើនឡើង ១៩,៣៩% បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៧។ រីឯចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៨ អនុវត្តបានកើនឡើង១២,៧% ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៧ ចំណាយថវិការាជធានី ខេត្ត អនុវត្តបានកើនឡើង ៦០,៦២% ធៀបទៅនឹងការអនុវត្ត

ឆ្នាំ២០១៧ និងចំណាយថវិការដ្ឋបាលក្រុង ស្រុក អនុវត្តបានកើនឡើង ១៩,៦៤ % ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៧។ ការអនុវត្តចំណូល និងចំណាយថវិកាថ្នាក់ជាតិបានធ្វើឱ្យមានការសន្សំអតិរេកថវិកាថ្នាក់ជាតិចំនួន ២ ៤៣៩ ១៦០,០លានរៀល។ ការគ្រប់គ្រងឆ្នាំ២០១៨ គោរពបានទាំងកាលវសាន ទាំងខ្លឹមសារនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបានបង្ហាញឱ្យឃើញថា រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តយ៉ាងសស្រាក់សស្រាំតាំងពីដើមនីតិកាលមក ហើយតម្រង់តម្រឹម និងពន្លឿនការអនុវត្តបញ្ចប់នូវកម្មវិធី និងអាទិភាពគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រត្រឹមត្រូវស្របតាមសភាពការណ៍ជាក់ស្តែង ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពរីកចម្រើន និងគត់មត់ពីមួយឆ្នាំទៅមួយឆ្នាំ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត គិតទាំងការគ្រប់គ្រងចំណូល ការគ្រប់គ្រងចំណាយថវិកា ការគ្រប់គ្រងបំណុល និងការធ្វើកិច្ចបញ្ជិកាគណនេយ្យ។

សមិទ្ធផលទាំងនេះ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមឺងម៉ាត់ និងឥតងាករេរបស់រាជរដ្ឋាភិបាល ក្នុងការបន្តរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការបន្តលើកស្ទួយកិត្យានុភាពកម្ពុជា ការការពារបាននូវអធិបតេយ្យជាតិ បូរណភាពទឹកដី ការបន្តពង្រឹងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ការបន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច និងធានាបាននូវស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា។ ទន្ទឹមគ្នានេះដែរ ថវិកាឆ្នាំ២០១៨ គឺពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ព្រមទាំងបានបុកគ្រឹះយ៉ាងរឹងមាំសម្រាប់បម្រើឱ្យការអភិវឌ្ឍរបស់កម្ពុជាតទៅមុខទៀត ថែមទាំងបានឆ្លើយតបទៅនឹងអាទិភាព និងតម្រូវការចាំបាច់របស់ក្រសួងស្ថាប័ននានាក្នុងការសម្រេចបាននូវគោលបំណងគោលនយោបាយរបស់ខ្លួន ក៏ដូចជាគោលនយោបាយជាអាទិភាពរួមរបស់រាជរដ្ឋាភិបាល។

សរុបមក ថវិកាឆ្នាំ២០១៨ ពិតជាសម្រេចបានតាមការប្រសិទ្ធនាម ថាជា **"ថវិកាយុទ្ធសាស្ត្រនៃការពូនផ្តុំកម្លាំង និងធនធានជាអតិបរមា ដើម្បីសម្រេចឱ្យខាងតែបាននូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា នៅក្នុងសភាពការណ៍តំបន់ និងពិភពលោក ដែលកាន់តែមានសភាពស្មុគស្មាញ សំដៅបន្តរក្សាសន្តិភាព ស្ថិរភាព ក៏ដូចជា ការទ្រទ្រង់នូវដំណើរការវិវឌ្ឍន៍ឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាពតទៅមុខឥតឈប់ឈរក្នុងនីតិកាលបន្តបន្ទាប់ទៀត។"**

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រា**៧,៥%** នាំមកនូវចំណូលមធ្យមសម្រាប់ប្រជាជនម្នាក់ៗ ក្នុងឆ្នាំ២០១៨ កើនឡើងដល់**១ ៥៤៨** ដុល្លារអាមេរិក និងអត្រាភាពក្រីក្របានធ្លាក់ចុះជាលំដាប់។

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មកំពូលមួយ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្នុងគោលបំណងបំពេញមុខងារត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អរាល់ចំណុចខ្វះខាតរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធនានា និងធ្វើរបាយការណ៍ស្តីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល សំដៅរួម

ចំណែកលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងារឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិ ផ្សព្វផ្សាយរបាយការណ៍សវនកម្មនេះ ជាសាធារណៈដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះលើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារក្នុងការិយបរិច្ឆេទ២០១៨ របស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន។

ការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ ការតស៊ូ អត់ធ្មត់ ពុះពារឆ្លងកាត់ការលំបាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងផ្នែកស្មារតី និងសម្ភារ បាននាំឱ្យអាជ្ញាធរសវនកម្មជាតិមានសក្តានុពលក្នុងការអនុវត្តការងារដោយសម្រេចបាននូវសមិទ្ធផលថ្មីៗជាច្រើនបន្តបន្ទាប់ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួន។ ចំពោះមុខ អាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចភារកិច្ចតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយរបស់ប្រទេសជាតិផងដែរ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងស្មារតី និងសម្ភារ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបាននូវជោគជ័យថ្មីៗថែមទៀតគួរឱ្យកត់សម្គាល់។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្មនានា និងសាធារណៈជនទាំងឡាយដែលបានសហការ គាំទ្រ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឱ្យវិស័យសវនកម្មសាធារណៈនាពេលកន្លងមក។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណផងដែរដល់ស្ថាប័នសវនកម្មកំពូលប្រទេសស៊ុយអែត ដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានា ដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការនៃការកសាងសមត្ថភាព និងអភិវឌ្ឍស្ថាប័ន។

អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា អាជ្ញាធរសវនកម្មជាតិនឹងសម្រេចនូវលទ្ធផលថ្មីៗថែមទៀតដែលបង្ហាញពីការចូលរួមចំណែកក្នុងការលើកស្ទួយ និងការអភិវឌ្ឍប្រទេសជាតិជាទីគោរព និងស្រឡាញ់នៃយើងទាំងអស់គ្នា។

ថ្ងៃ សុក្រ ៦កើត ខែ ផល្គុន ឆ្នាំ កុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០២០

**អគ្គសវនករ**

**សោម គីមសួគ៌**

# មាតិកា


**សេចក្តីសង្ខេប**........................................................................................... ១

**១. សេចក្តីផ្តើម**........................................................................................... ៥

**១.១.លក្ខណៈទូទៅ**........................................................................................... ៥

**១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម**........................................................................................... ៥

**១.៣. គោលបំណងនៃការផ្សព្វផ្សាយ**........................................................................................... ៥

**២. ការគ្រប់គ្រងថវិកា**........................................................................................... ៦

**២.១.មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា**........................................................................................... ៦

**២.២.កិច្ចប្រតិបត្តិការថវិកា**........................................................................................... ៦

**៣. លទ្ធផលសវនកម្ម**........................................................................................... ៩

**៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ**........................................................................................... ៩

៣.១.១. ការយឺតយ៉ាវក្នុងការចុះបញ្ជីក្រុមហ៊ុនសហគ្រាស........................................................................................... ៩

៣.១.២. ភាពយឺតយ៉ាវក្នុងការព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម........................................................................................... ១០

៣.១.៣. ការផ្ទេរក្រុមហ៊ុន សហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម........................................................................................... ១០

៣.១.៤. ការមិនទាន់ចុះបញ្ជីអាជីវកម្មចំពោះបុគ្គលប្រកបអាជីវកម្មអចលនទ្រព្យ........................................................................................... ១១

៣.១.៥. ភាពយឺតយ៉ាវក្នុងការធ្វើសវនកម្មសម្រាប់កម្មវិធីសវនកម្មឆ្នាំ២០១៨........................................................................................... ១២

៣.១.៦. ការយឺតយ៉ាវក្នុងការផ្តល់សេវាចំពោះឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រារបស់អ្នកជាប់ពន្ធមួយចំនួន........................................................................................... ១២

៣.១.៧. ភាពសហការគ្នាមិនទាន់មានភាពរលូននិងប្រទាក់ក្រឡាគ្នារវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា........................................................................................... ១៣

៣.១.៨. ការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយនៅមានកម្រិត........................................................................................... ១៣

៣.១.៩.ទំនិញនាំចូលជាប់កម្រិតកំណត់មិនស្របតាមលិខិតអនុញ្ញាតរបស់ក្រសួងស្ថាប័ន........................................................................................... ១៤

៣.១.១០.ការយឺតយ៉ាវក្នុងការជម្រះបញ្ជីប្រាក់កក់សម្រាប់បង់ពន្ធលើរថយន្តចង្កូតស្តាំ........................................................................................... ១៥

៣.១.១១.ការត្រួតពិនិត្យអនុលោមភាពទំនិញនាំចូលដែលទទួលបានការអនុគ្រោះព្យួរ ឬលើកលែងពន្ធអាករនៅមានកម្រិត........................................................................................... ១៦

៣.១.១២.ភាពយឺតយ៉ាវក្នុងការបង់ថ្លៃឈ្នួលជួលទីតាំងអចលនទ្រព្យរបស់ក្រុមហ៊ុនចូលថវិការដ្ឋ........................................................................................... ១៧

៣.១.១៣.ការរៀបចំបញ្ជីបេឡាសាច់ប្រាក់នៅធនាគារ........................................................................................... ១៨

៣.១.១៤.ភាពយឺតយ៉ាវក្នុងការចេញអាជ្ញាបណ្ណជូនគ្រឹះស្ថានសិក្សា........................................................................................... ១៩

៣.១.១៥.ភាពយឺតយ៉ាវក្នុងការប្រមូលចំណូលពីផលទុនអាកាសចរបង់ចូលថវិការដ្ឋ........................................................................................... ១៩

៣.១.១៦.ការប្រមូលចំណូលនៅមានកម្រិត ........................................................ ២០
៣.១.១៧.អ្នកប្រមូលចំណូលពុំមែនជារដ្ឋទេយ្យករចំណូលរង................................ ២១
៣.១.១៨.កង្វះខាតក្នុងការតាមដាន និងផ្ទៀងផ្ទាត់ចំណូល .................................... ២២
៣.១.១៩.ការចំណាយ និងការកត់ត្រាចំណាយមិនទាន់ស្របតាមចំណាត់ថ្នាក់ សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ ................................................................ ២៣
៣.១.២០.ការចំណាយថវិកាបុរេប្រទានពុំស្របទៅនឹងកម្មវត្ថុនៃការចំណាយ .............. ២៣
៣.១.២១.ការរៀបចំកិច្ចបញ្ជិកាគណនេយ្យ សម្រាប់កត់ត្រាការចំណាយប្រាក់ រដ្ឋទេយ្យបុរេប្រទាន ................................................................................ ២៤
៣.១.២២.ការប្រើប្រាស់សក្ខីបត្រចំណាយឆ្នាំ២០១៧មកធ្វើការទូទាត់ឥណទាន ថវិកាចំណាយឆ្នាំ២០១៨............................................................................ ២៥
៣.១.២៣.ការប្រមូលសក្ខីបត្រចំណាយយកមកទូទាត់ពុំបានត្រឹមត្រូវ........................ ២៦
៣.១.២៤.ការបំបែកបណ្តុំចំណាយដើម្បីគេចវេសនីតិវិធីលទ្ធកម្ម............................... ២៧
៣.១.២៥.ការចំណាយមុនការស្នើសុំការឯកភាពពីប្រធានអង្គភាពថវិកា ..................... ២៧
៣.១.២៦.ការអនុវត្តកិច្ចលទ្ធកម្មមិនស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំ....................... ២៨
៣.១.២៧.ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ..................................... ២៩
៣.១.២៨.ភាពយឺតយ៉ាវក្នុងការរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយប្រចាំឆ្នាំ ៣០
៣.១.២៩.វិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលសាងសង់មិនសមស្របនឹងទំហំទឹកប្រាក់ ចុះកិច្ចសន្យា ........................................................................................ ៣០
៣.១.៣០.ប៉ាតង់របស់ក្រុមហ៊ុនចូលរួមដេញថ្លៃពុំទាន់ស្របនឹងមុខរបរទំនិញដែល ត្រូវដេញថ្លៃ .......................................................................................... ៣១
៣.១.៣១.ភាពយឺតយ៉ាវក្នុងការទាមទារស្តុកមកវិញ ................................................ ៣៣
៣.១.៣២.ភាពយឺតយ៉ាវក្នុងការបូកសរុបចំណាយថវិកាកម្មវិធីទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព.................................................................................... ៣៣
៣.១.៣៣.ការអនុវត្តប្រកាសអន្តរក្រសួងលេខ២៦១ ស.អ.យ មិនទាន់បានពេញលេញ ៣៤
៣.១.៣៤.ការពុំទាន់បង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ................................................ ៣៥
៣.១.៣៥.អង្គភាពអនុវត្តគម្រោងពុំមានឧបករណ៍បំពេញការងារ ............................... ៣៥
៣.១.៣៦.ការមិនបានបែងចែក និងវិភាជឥណទានថវិកាទៅឱ្យអង្គភាពថវិកា .............. ៣៦
៣.១.៣៧.កង្វះខាតក្នុងការដាក់បញ្ចូលសម្ភារការិយាល័យក្នុងផែនការលទ្ធកម្ម............ ៣៧
៣.១.៣៨.ភាពយឺតយ៉ាវក្នុងការទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត.................................. ៣៨
៣.១.៣៩.ភាពយឺតយ៉ាវក្នុងការទារបំណុលពីកម្រៃសេវាចេញលិខិតអនុញ្ញាតសាងសង់ បង់ចូលថវិកាជាតិ ................................................................................ ៣៩
៣.១.៤០.ភាពយឺតយ៉ាវក្នុងការទារបំណុលពីផលទុនអាកាសចរស៊ីវិល...................... ៤០

៣.១.៤១.ការពុំមានវិធានការតឹងទារបំណុល ........................................................ ៤១
៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ...................................................... ៤១
៣.២.១. កង្វះខាតក្នុងការប្រមូលចំណូលអាករលើការស្នាក់នៅ ................................ ៤១
៣.២.២. ការប្រមូលពន្ធប៉ាតង់ ......................................................................... ៤២
៣.២.៣. ការប្រមូលពន្ធប្រថាប់ត្រា ...................................................................៤៣
៣.២.៤. កង្វះខាតក្នុងការប្រមូលចំណូលពីការអនុញ្ញាតបើក និងបិទការដ្ឋានសំណង់ .. ៤៤
៣.២.៥. ការបង់ចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្លងការិយបរិច្ឆេទ ...................... ៤៥
៣.២.៦. ការពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ ................. ៤៦
៣.២.៧. ការមិនបានចាត់តាំងអ្នកគ្រប់គ្រងគម្រោងដើម្បីតាមដានការងារសំណង់........ ៤៧
៣.២.៨. ការវាយតម្លៃអ្នកចូលរួមដេញថ្លៃ និងប្រគល់កិច្ចសន្យាដោយពុំមានតារាង ទិន្នន័យតម្លៃទីផ្សារ...................................................................... ៤៨
**៤.ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម** ...................... ៤៩
៤.១. ប្រសិទ្ធភាពនៃការធ្វើសវនកម្ម ............................................................... ៤៩
៤.២. ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន.... ៤៩
៤.៣. ការគ្រប់គ្រងអ្នកជាប់ពន្ធ......................................................................... ៤៩
៤.៤. ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ ..................................... ៥០
៤.៥. របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ................................................ ៥០
៤.៦. ការប្រើប្រាស់វិក្កយបត្រ ........................................................................ ៥១
៤.៧. ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ........................................................ ៥១
៤.៨. ការប្រមូលពន្ធអចលនទ្រព្យ ................................................................... ៥២
៤.៩. ការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ ................................................ ៥២
៤.១០. ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ ....................................៥៣
៤.១១.ការទូទាត់ និងការកត់ត្រាចំណាយ .......................................................... ៥៤
៤.១២.ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់........................................ ៥៥
៤.១៣. ការធ្វើរបាយការណ៍លទ្ធកម្មមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ...................... ៥៦
៤.១៤. ការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ................................................... ៥៦
៤.១៥. ការធ្វើបណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ...........................................៥៧
**៥.សេចក្តីសន្និដ្ឋាន**.................................................................................... ៥៨

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០១៨

## សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

សម្រាប់ការិយបរិច្ឆេទ២០១៨ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួនដែលមានលទ្ធផលសង្ខេបខាងក្រោម៖

### ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ចំណូលថវិកាថ្នាក់ជាតិឆ្នាំ២០១៨ អនុវត្តបានចំនួន **២៤ ៩៩០ ៤៨៣,១លានរៀល** ស្មើនឹង **២៥,៣០%** នៃ ផ.ស.ស គឺបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **១១,៤%** បានកើនឡើង **១៥,៥%** ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៧។ ចំណូលថវិកាខ្ពស់នេះ គឺជាលទ្ធផលនៃកិច្ចប្រឹងប្រែងយូរឆ្នាំរបស់រាជរដ្ឋាភិបាលលើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការអនុវត្តវិធានការជាក់ស្តែងសំខាន់ៗក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨ និងការរួមចំណែកពីសកម្មភាពសវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។ ការអនុវត្តចំណូលគយ និងរដ្ឋាករសម្រេចបានលទ្ធផលល្អប្រសើរ តាមរយៈ៖ (១).ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីគយ និងការងារបច្ចេកទេសគយ (២).ការបន្តពង្រឹងប្រសិទ្ធភាពការងារបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធ (៣).ការពង្រីកការប្រើប្រាសបច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាត្រួតពិនិត្យការងារគយ (៤).ការធ្វើវិចារណកម្ម និងពិពិធកម្មគោលនយោបាយគយ និង(៥).ការពង្រឹងអភិបាលកិច្ចអង្គភាពគយ និងអភិវឌ្ឍន៍ស្ថាប័ន។ ការអនុវត្តចំណូលពន្ធដារ សម្រេចបានលទ្ធផលល្អប្រសើរ តាមរយៈការកែលម្អគោលនយោបាយសារពើពន្ធ ការពង្រឹងរដ្ឋបាលសារពើពន្ធ និងការពង្រឹងអភិបាលកិច្ចល្អ ក្នុងគោលដៅបង្កើនចំណូលពន្ធ ធ្វើឱ្យប្រព័ន្ធពន្ធមានភាពសាមញ្ញ មានសមធម៌និងយុត្តិធម៌ មានស្ថិរភាព មានតម្លាភាព មានប្រសិទ្ធភាព បន្ថយអំពើគេចវេសពន្ធ និងអភិវឌ្ឍស្ថាប័ន។ ការអនុវត្តចំណូលមិនមែនសារពើពន្ធក៏បានល្អប្រសើរ តាមរយៈការកែលម្អគោលនយោបាយចំណូលមិនមែនសារពើពន្ធ និងកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តវិធានការប្រមូលចំណូល និងតឹងទារបំណុលម៉ឹងម៉ាត់ ដែលធ្វើឱ្យមុខសញ្ញាចំណូលសំខាន់ៗមានការកើនឡើង។

តាមរយៈការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា នៅមានការកត់សម្គាល់មួយចំនួនដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀត មានជាអាទិ៍៖ ការយឺតយ៉ាវក្នុងការចុះបញ្ជីក្រុមហ៊ុនសហគ្រាស ភាពយឺតយ៉ាវក្នុងការព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ការផ្ទេរក្រុមហ៊ុន សហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម ការមិនទាន់ចុះបញ្ជីអាជីវកម្មចំពោះបុគ្គលប្រកបអាជីវកម្មអចលនទ្រព្យ ភាពយឺតយ៉ាវក្នុងការធ្វើសវនកម្មសម្រាប់កម្មវិធីសវនកម្មឆ្នាំ២០១៨ ការយឺតយ៉ាវក្នុងការផ្តល់សេវាចំពោះឯកសារស្នើសុំបង់ពន្ធប្រចាំគ្រារបស់អ្នកជាប់ពន្ធមួយចំនួន ភាពសហការគ្នាមិនទាន់មានភាពរលូននិងប្រទាក់ក្រឡាគ្នារវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ប្រសិទ្ធភាពនៃការធ្វើសវនកម្ម ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន ការគ្រប់គ្រងអ្នកជាប់ពន្ធ ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ របាយការណ៍សវនកម្មរបស់សវនកររងករាជ្យ ការប្រើប្រាស់វិក្កយបត្រ ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ ការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយនៅមានកម្រិត ទំនិញនាំចូលជាប់កម្រិតកំណត់មិនស្របតាមលិខិតអនុញ្ញាតរបស់ក្រសួងស្ថាប័ន ការយឺតយ៉ាវក្នុងការជម្រះបញ្ជីប្រាក់កក់សម្រាប់បង់ពន្ធលើរថយន្តចង្កូតស្តាំ ការត្រួតពិនិត្យអនុលោមភាពទំនិញនាំចូលដែលទទួលបានការអនុគ្រោះព្យួរ ឬលើកលែងពន្ធអាករនៅមានកម្រិត ការកំណត់តម្លៃគិតពន្ធលើទំនិញល្មើសច្បាប់គយទាបជាងតម្លៃចម្លងការ ការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ ការគ្រប់គ្រងទិន្នន័យពីកម្រៃបង់សេវាតម្កល់ប្រតិវេទន៍របស់ក្រុមហ៊ុនមិនទាន់បានត្រឹមត្រូវ និងពេញលេញ ភាពយឺតយ៉ាវក្នុងការបង់ចំណូលចូលថវិកាជាតិ ការរៀបចំបញ្ជីបេឡាសាច់ប្រាក់នៅធនាគារ ភាពយឺតយ៉ាវក្នុងការប្រមូលចំណូលពីផលទុនអាកាសចរចូលថវិការដ្ឋ ការប្រមូលចំណូលនៅមានកម្រិត ការពុំបានកត់ត្រាចំណូលក្នុងរបាយការណ៍ហិរញ្ញវត្ថុ អ្នកប្រមូលចំណូលពុំមែនជារដ្ឋទេយ្យករចំណូលរង កង្វះខាតការតាមដាន និងផ្ទៀងផ្ទាត់ចំណូល និងភាពយឺតយ៉ាវក្នុងការចេញអាជ្ញាប័ណ្ណជូនគ្រឹះស្ថានសិក្សា។

ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានចំនួន**២២ ៥៥១ ៣២៣,១លានរៀល** ស្មើនឹង **២២,៨៣%** នៃ ផ.ស.ស គឺទាបជាងច្បាប់ហិរញ្ញវត្ថុ **៣,៩%** ហើយបានកើនឡើង **១២,៧%** ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៧ ដោយបានបំពេញតួនាទីជាឧបករណ៍ដ៏មានប្រសិទ្ធភាព ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលតាមការគ្រោងទុក និងដោះស្រាយបាននូវអាទិភាពគោលនយោបាយថ្មីៗ ឆ្លើយតបទៅនឹងសភាពការណ៍បន្ទាន់ និងគាំទ្រដល់ការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ក្នុងនោះរួមមាន៖(១).សម្រេចបានការអនុវត្តគោលនយោបាយដំឡើងបៀវត្សជូនមន្ត្រីរាជការ ដោយបានដំឡើងបៀវត្សមូលដ្ឋានក្នុងអត្រា១២% ចាប់ពីខែមករា ឆ្នាំ២០១៨ ដំឡើងប្រាក់បំណាច់មុខងារ ចាប់ពីខែមេសា ឆ្នាំ២០១៨ ដំឡើងប្រាក់សោធននិវត្តន៍ជូននិវត្តជន ប្រាក់បំណាច់របស់មន្ត្រីជាប់កិច្ចសន្យាក៏ត្រូវបានដំឡើងពីចំនួន១៦០ ពាន់រៀល ដល់ចំនួន៤០០ ពាន់រៀល ព្រមទាំងបានផ្តល់ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំ និងបុណ្យភ្ជុំបិណ្ឌ។ ការបើកបៀវត្សសម្រេចបាននៅក្នុងសប្តាហ៍ទី៤ នៃខែនីមួយៗ និងធ្វើឡើងតាមរយៈប្រព័ន្ធធនាគារ។ (២).បង្កើននូវប្រសិទ្ធភាពចំណាយតាមរយៈវិធានការបង្កើនប្រសិទ្ធភាពក្នុងការវិភាជន៍ និងក្នុងការពិនិត្យផ្តល់ធានាចំណាយ ដោយធានាបាននូវចំណាយចំមុខសញ្ញា មានភាពចាំបាច់ ថ្លៃសមរម្យ បរិមាណត្រឹមត្រូវ គុណភាពសមរម្យ និងទាន់ពេលវេលា។ (៣).នៅក្នុងវិស័យរដ្ឋបាលទូទៅ ការអនុវត្តចំណាយបានល្អគឺទាបជាងច្បាប់ហិរញ្ញវត្ថុ។ (៤).នៅក្នុងវិស័យការពារជាតិ និង

សន្តិសុខអនុវត្តលើសច្បាប់ហិរញ្ញវត្ថុ២.២% គឺចំណាយបៀវត្ស និងឧបត្ថម្ភបុណ្យចូលឆ្នាំថ្មី និងបុណ្យភ្ជុំបិណ្ឌ។ (៥).ក្នុងវិស័យសង្គមកិច្ច ការអនុវត្តត្រូវបានកែលម្អច្រើន ដោយអនុវត្តបាន៩៨.០% នៃច្បាប់ហិរញ្ញវត្ថុ។ (៦).ការអនុវត្តចំណាយក្នុងវិស័យសេដ្ឋកិច្ចបានល្អ គឺអនុវត្តបាន៩៨.៩%នៃច្បាប់ហិរញ្ញវត្ថុ។ (៧).ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសអនុវត្តបាន៨៦,១% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះគម្រោងវិនិយោគក្នុងស្រុកអនុវត្តបាន៨៥,៤% នៃច្បាប់ហិរញ្ញវត្ថុ លើកលែងតែការវិនិយោគដោយមូលនិធិទ្រទ្រង់ថវិកាដែលអនុវត្តបានទាប ដោយសារពាក់ព័ន្ធនឹងនីតិវិធីខាងដៃគូអភិវឌ្ឍន៍។ (៨).ក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងឆ្នាំ២០១៨ រាជរដ្ឋាភិបាលសន្សំសំចៃថវិកាបានចំនួន៦៧,៥ ប៊ីលានរៀល ស្មើនឹង២,២% គឺបានលើកកម្ពស់ប្រសិទ្ធភាពចំណាយក្នុងគ្រប់ដំណាក់កាលនៃការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈទាំងផ្នែកចំណាយចរន្ត និងទាំងផ្នែកចំណាយវិនិយោគ។ វិធានការលើកកម្ពស់ប្រសិទ្ធភាពចំណាយមិនត្រឹមតែធ្វើឱ្យមានការសន្សំជាសាច់ប្រាក់ប៉ុណ្ណោះទេ ថែមទាំងបានធ្វើឱ្យក្រសួងស្ថាប័នមួយចំនួនកម្រិតការចាយក្នុងទំហំទឹកប្រាក់ដដែល តែទទួលបានទំនិញ សេវា និងសំណង់ ក្នុងបរិមាណច្រើនជាងមុន និងមានគុណភាពល្អជាងមុន ព្រមទាំងចាយកាន់តែចំទិសដៅដែលបានកំណត់នៅក្នុងអំឡុងពេលរៀបចំថវិកាទៀតផង។ (៩).បំណុលបុរេប្រទានរបស់រដ្ឋបាលរាជធានីភ្នំពេញចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៤ បានទូទាត់ជម្រះក្នុងឆ្នាំថវិកា២០១៨ ដោយមានការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។ (១០).យន្តការផ្ទេរមុខងារ និងធនធានរបស់រដ្ឋាភិបាលថ្នាក់ជាតិឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈក្រសួងមួយចំនួនកំពុងដំណើរការអនុវត្ត។ (១១).ឱនភាពទូទៅនៃថវិកាត្រូវបានកាត់បន្ថយឱ្យមកស្ថិតនៅក្នុងកម្រិតដែលអាចធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និងរយៈពេលវែង ដែលឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវការគ្រប់គ្រងបំណុលសាធារណៈស្របតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០១៥-២០១៨ របស់រាជរដ្ឋាភិបាល ជាពិសេសតាមគោលការណ៍គន្លឹះទាំង៤ គឺៈ ១.ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន ២.ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់ ៣.ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពដែលទ្រទ្រង់ចីរភាពកំណើន និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម និង ៤.ត្រូវប្រើប្រាស់ឥណទានទាំងនោះប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់បំផុត។

ទោះបីជាការអនុវត្តចំណាយថវិកានេះបានល្អប្រសើរក៏ដោយ ក៏នៅមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួន ដូចជាការចំណាយ និងការកត់ត្រាចំណាយមិនទាន់ស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ ការចំណាយថវិកាបុរេប្រទានពុំស្របទៅនឹងកម្មវត្ថុនៃការចំណាយ ការរៀបចំកិច្ចបញ្ជិកាគណនេយ្យសម្រាប់កត់ត្រាការចំណាយប្រាក់រជ្ជទេយ្យបុរេប្រទាន ការប្រើប្រាស់សក្ខីបត្រចំណាយឆ្នាំ២០១៧មកធ្វើការទូទាត់ឥណទានថវិកាចំណាយឆ្នាំ២០១៨ ការប្រមូលសក្ខីបត្រចំណាយយកមកទូទាត់ពុំបានត្រឹមត្រូវ ការបំបែកបណ្ណចំណាយដើម្បីគេចវេសនីតិវិធីលទ្ធកម្ម ការចំណាយមុនការស្នើសុំការឯកភាពពីប្រធានអង្គភាពថវិកាជាក្រោយ ការអនុវត្តកិច្ចលទ្ធកម្មមិនស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំ ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ ភាពយឺតយ៉ាវក្នុងការរៀបចំរបាយ

ការណ៍បូកសរុបការអនុវត្តចំណាយប្រចាំឆ្នាំ ប៉ាតង់របស់ក្រុមហ៊ុនចូលរួមដេញថ្លៃពុំទាន់ស្របនឹងមុខរបរទំនិញដែលត្រូវដេញថ្លៃ វិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលសាងសង់មិនសមស្របនឹងទំហំទឹកប្រាក់ចុះកិច្ចសន្យា ភាពយឺតយ៉ាវក្នុងការទាមទារស្តុកមកវិញ ភាពយឺតយ៉ាវក្នុងការបូកសរុបចំណាយថវិកាកម្មវិធីទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ការអនុវត្តប្រកាសអន្តរក្រសួងលេខ២៦១ ស.អ.យ មិនទាន់បានពេញលេញ ការពុំទាន់បង្កើតអង្គភាពសវនកម្មផ្ទៃក្នុង អង្គភាពអនុវត្តគម្រោងពុំមានឧបករណ៍បំពេញការងារ ការមិនបានបែងចែក និងវិភាជឥណទានថវិកាទៅឱ្យអង្គភាពថវិកា កង្វះខាតក្នុងការដាក់បញ្ចូលសម្ភារការិយាល័យក្នុងផែនការលទ្ធកម្ម ភាពយឺតយ៉ាវក្នុងការទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត ភាពយឺតយ៉ាវក្នុងការទារបំណុលពីកម្រៃសេវាចេញលិខិតអនុញ្ញាតសាងសង់ចូលថវិកាជាតិ ភាពយឺតយ៉ាវក្នុងការទារបំណុលពីផលទុនអាកាសចរស៊ីវិល និងការពុំមានវិធានការតឹងទារបំណុល។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូលសរុប ស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះអនុវត្តបានចំនួន **៤ ៣២២ ២១២,២** លានរៀល ស្មើនឹង**៩៥,១%** នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន **៤ ៥៤៦ ៩៣៩,០**លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន **២២៤ ៧២៦,៨** លានរៀល។

### ខ. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបានចំនួន**១ ៨៩០ ៥០៦,៤**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ ចំនួន**៦៨,៣%** និងការអនុវត្តចំណាយថវិការបស់រដ្ឋបាលរាជធានីខេត្តអនុវត្តបាន**១ ៨៩០ ៥០៦,៤**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ ចំនួន**៦៨,៣%**។ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបាន **១៨៧ ៤០៥,០**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ ចំនួន**១៦,៨%** និងចំណាយថវិការបស់រដ្ឋបាលក្រុងស្រុក អនុវត្តបាន**១៧៦ ០៥៩,៩**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ ចំនួន**៩,៨%**។ រីឯចំណូលថវិការបស់រដ្ឋបាលឃុំសង្កាត់ អនុវត្តបាន **៥៦៧ ៥៩៣,៧** លានរៀលគឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ ចំនួន**៣០,៨%** និងចំណាយថវិការបស់រដ្ឋបាលឃុំសង្កាត់អនុវត្តបាន**៤៣០ ៣៩០,៦**លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ ចំនួន**០,៨%**។

ផ្អែកតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានបញ្ហាគួរឱ្យកត់សម្គាល់ ដូចជាកង្វះខាតក្នុងការប្រមូលចំណូលអាករលើការស្នាក់នៅ ការប្រមូលពន្ធប៉ាតង់ ការប្រមូលពន្ធប្រថាប់ត្រាការប្រមូលពន្ធអចលនទ្រព្យ កង្វះខាតក្នុងការប្រមូលចំណូលពីការអនុញ្ញាតបើក និងបិទការដ្ឋានសំណង់ ការពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ ការបង់ចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្លងការិយបរិច្ឆេទ និងការមិនបានចាត់តាំងអ្នកគ្រប់គ្រងគម្រោងដើម្បីតាមដានការងារសំណង់។ ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាស និងសារាចរណែនាំច្រើនរំលឹកជាញឹកញាប់ឱ្យក្រសួង ស្ថាប័ន និងសាលារាជធានី ខេត្តធ្វើការផ្ទៀងផ្ទាត់តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះ ដោយអនុវត្តបានមួយចំនួនធំ និងនៅមានខ្វះខាតមួយចំនួនតូច។ ចំពោះការធ្វើបណ្ណសម្គាល់កម្មសិទ្ធិវិញ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតមកដល់ឆ្នាំ២០១៨ ទ្រព្យសម្បត្តិរដ្ឋមួយចំនួនតូចនៅតែពុំទាន់បានធ្វើបណ្ណសម្គាល់កម្មសិទ្ធិនៅឡើយ។

## ១. សេចក្តីផ្តើម

### ១.១. លក្ខណៈទូទៅ

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ធ្វើសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យ គណនីប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន។

ក្រៅពីការងារខាងលើនេះ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ និងធ្វើរបាយការណ៍សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងធ្វើជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មានព្រមទាំងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

### ១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ២០១៨ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗជាពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ។ សម្រាប់ការិយបរិច្ឆេទ២០១៨ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងរៀបចំរបាយការណ៍នេះដោយដកស្រង់ចំណុចគត់សម្គាល់សំខាន់ៗដូមមានបង្ហាញក្នុងចំណុចទី៣ នៃរបាយការណ៍នេះសម្រាប់ផ្សព្វផ្សាយជាសាធារណៈ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានការរៀបចំផែនការ និងអនុវត្តការងារសវនកម្មដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗ ដើម្បីទទួលបានភស្តុតាងសវនកម្មសមស្របសម្រាប់ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ។

### ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា

តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះ សំដៅធ្វើឱ្យការគ្រប់គ្រងកាន់តែប្រសើរឡើង។

អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងករណីដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅ។

## ២. ការគ្រប់គ្រងថវិកា

### ២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០១៨ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលមានជាអាទិ៍ ៖

- ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខជស/រកម/០៣០១/១៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

### ២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០១៨ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូល ចំណាយតាមរយៈរតនាគារជាតិ រតនាគាររាជធានី ខេត្ត និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

## ក/ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

*ឯកតា : លានរៀល*

| បរិយាយ | ២០១៨ | | |
|---|---|---|---|
| | **ច្បាប់ហិរញ្ញវត្ថុ** | **អនុវត្ត** | **ភាគរយ** |
| | ***1*** | ***2*** | ***3 = (2/1)*** |
| I. **សរុបចំណូល** | **២២ ៤៣៧ ១៣៨,0** | **២៤ ៩៩0 ៤៨៣,១** | **១១១,៤%** |
| -ចំណូលចរន្ត | ១៧ ៤៦0 00៦,0 | ២0 ១៤៦ ៧៣៦,0 | ១១៥.៤% |
| -ចំណូលមូលធនក្នុងប្រទេស | ១៨0 ១៩៣,0 | ១៩៤ ៧៤៣,0 | ១0៨,១% |
| -ចំណូលមូលនិធិទ្រទ្រង់ថវិកា | ២៥0 000,0 | ៣២៦ ៧៩១,៩ | ១៣0,៧% |
| -ចំណូលមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ៥៤៦ ៩៣៩,0 | ៤ ៣២២ ២១២,២ | ៩៥,១% |
| II. **សរុបចំណាយ** | **២៣ ៤៥៦ ១៤៨,0**.* | **២២ ៥៥១ ៣២៣,១** | **៩៦,១%** |
| -ចំណាយចរន្ត | ១៥ ២៤៦ 0១៦,0* | ១៤ ៩៧២ ៥00,៦ | ៩៨,២% |
| -ចំណាយមូលធន | ៣ ៦៦៣ ១៩៣,0 | ៣ ២៥៦ ៦១0,៣ | ៨៨,៩% |
| -ចំណាយមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ៥៤៦ ៩៣៩,0 | ៤ ៣២២ ២១២,២ | ៩៥,១% |

* តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន២៧ ៨៥០លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។

## ខ-កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ខ₁/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

*ឯកតា : លានរៀល*

| បរិយាយ | ២០១៨ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| I. **សរុបចំណូលថវិកា** | **១ ១២៣ ៣៨៣,០*** | **១ ៨៩០ ៥០៦,៤** | **១៦៨,៣%** |
| -ចំណូលចរន្ត | ៩៤១ ៤១៩,០ | ១ ៦២៨ ១៨០,៨ | ១៧២,៩% |
| •ចំណូលសារពើពន្ធ | ៩១០ ៨៤៣,០ | ១ ៥៨៦ ៥១៣,៤ | ១៧៤,៣% |
| •ចំណូលពុំមែនសារពើពន្ធ | ៣០ ៩៧៦,០ | ៤១ ៦៦៧,៤ | ១៣៤,៥% |
| -ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ១៨១ ៩៦៤,០* | ២៦២ ៣២៥,៦ | ១៤៤,២% |
| II. **សរុបចំណាយថវិកា** | **១ ១២៣ ៣៨១,០**** | **១ ៨៩០ ៥០៦,៤** | **១៦៨,៣%** |
| -ចំណាយចរន្ត | ៨៣១ ០៥៥,៥** | ១ ៤៦៩ ៨៤៦,៤ | ១៧៦,៩% |
| -ចំណាយមូលធន | ២៩២ ៣២៥,៥** | ៤២០ ៦៦០,០ | ១៤៣,៩% |

### ខ₂/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

*ឯកតា : លានរៀល*

| បរិយាយ | ២០១៨ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| I. **សរុបចំណូលថវិកា** | **១៦០ ៤០០,០** | **១៨៧ ៤០៥,០** | **១១៦,៨%** |
| -ចំណូលចរន្ត (មិនមែនសារពើពន្ធ) | ៥ ៣៨៥,០ | ២១ ៧១០,៥ | ៤០៣,២% |
| -ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ១៥៥ ០១៥,០ | ១៥៥ ៨៨៥,៨ | ១០០,៦% |
| -អតិរេកឆ្នាំ២០១៧ | | ៩ ៨០៨,៧ | |
| II. **សរុបចំណាយថវិកា** | **១៦០ ៤០០,០** | **១៧៦ ០៥៩,៩** | **១០៩,៨%** |
| -ចំណាយចរន្ត | ១៦០ ៣៥៣,០ | ១៧៥ ៨០៨,៧ | ១០៩,៦% |
| -ចំណាយមូលធន | ៤៧,០ | ២៥១,២ | ៥៣៤,៦% |

---

* តួលេខនេះបូកបញ្ចូលនូវ៖ (១)-ឥណទានចំនួន២៧ ៨៥០លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ និង (២)-តួលេខបូកបញ្ចូលនូវឥណទានចំនួន៥ ៣០០ លានរៀល ដោយយោងការធ្វើនិយ័តឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ជូនសាលាខេត្តសៀមរាប។

** តួលេខនេះបូកបញ្ចូលនូវ៖ (១)-ឥណទានចំនួន២៧ ៨៤៨លានរៀល ដោយយោងការធ្វើប្រកាសបន្ថែមឥណទានសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ សម្រាប់ជម្រះបុរេប្រទានរបស់រដ្ឋបាលរាជធានីភ្នំពេញចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៤ និង (២)-តួលេខបូកបញ្ចូលនូវឥណទានចំនួន៥ ៣០០ លានរៀល ដោយយោងការធ្វើនិយ័តឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ជូនសាលាខេត្តសៀមរាប។

ខ៣/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

*ឯកតា : លានរៀល*

| បរិយាយ | ២០១៨ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| I. សរុបចំណូលថវិកា | **៤៣៤ ០៤១,០** | **៥៦៧ ៥៩៣,៧** | **១៣០,៨%** |
| -ចំណូលមិនមែនសារពើពន្ធ | ០ | ១៨ ៣០៦,៤ | |
| -ចំណូលឧបត្ថម្ភពីថវិកាជាតិ | ៤៣៤ ០៤១,០ | ៤៣៤ ១៦៨,១ | ១០០,០% |
| -អតិរេកឆ្នាំ២០១៧ | ០ | ១១៥ ១១៩,២ | |
| II. សរុបចំណាយថវិកា | **៤៣៤ ០៤១,០** | **៤៣០ ៣៩០,៦** | **៩៩,២%** |
| -ចំណាយសង្កាត់ចំណុះរាជធានី | ៣០ ៧៥២,០ | ៣២ ៣០២,២ | ១០៥,០% |
| -ចំណាយសង្កាត់ចំណុះក្រុង | ៣៣ ៩៩៧,៥ | ៣៥ ២០៦,៦ | ១០៣,៦% |
| -ចំណាយឃុំ | ៣៦៩ ២៩១,៥ | ៣៦២ ៨៨១,៨ | ៩៨,៣% |

# ៣. លទ្ធផលសវនកម្ម

## ៣.១. ការគ្រប់គ្រងថវិកាថ្នាក់ជាតិ

### ៣.១.១. ការយឺតយ៉ាវក្នុងការចុះបញ្ជីក្រុមហ៊ុនសហគ្រាស

ដើម្បីគ្រប់គ្រងអ្នកជាប់ពន្ធ ប្រមូលពន្ធ និងផ្តល់សេវាល្អដល់អ្នកជាប់ពន្ធ រដ្ឋបាលសារពើពន្ធត្រូវចុះបញ្ជីសហគ្រាសដែលត្រូវចុះបញ្ជី និងសហគ្រាសដែលបានស្នើសុំចុះបញ្ជីឱ្យបានទាន់ពេលវេលា។ នៅក្នុងឆ្នាំ២០១៨ អគ្គនាយកដ្ឋានពន្ធដារបានទទួលសហគ្រាសស្នើសុំចុះបញ្ជីពន្ធដារមានចំនួន១៤ ០៩៤ សហគ្រាស ក្នុងនោះអគ្គនាយកដ្ឋានពន្ធដារបានចុះបញ្ជីសហគ្រាសសម្រេចចំនួន១០ ៦០៩ បានបដិសេធចុះបញ្ជីសហគ្រាសចំនួន១៦ និងមិនទាន់បានចុះបញ្ជីសហគ្រាសចំនួន ៣ ៤៦៩។ ទន្ទឹមគ្នានេះដែរ តាមការពិនិត្យរបាយការណ៍ស្ថិតិចុះបញ្ជីថ្មីសម្រាប់ឆ្នាំ២០១៨ របស់សាខាពន្ធដារខណ្ឌចំនួន៤ និងខេត្តចំនួន៨ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាពន្ធដារខេត្ត ខណ្ឌទាំងនោះបានទទួលចុះបញ្ជីអ្នកជាប់ពន្ធមធ្យមចំនួន៣៩៧ និងអ្នកជាប់ពន្ធតូចចំនួន១ ៩៤៨ ដោយមិនមានឯកសារភ្ជាប់គ្រប់គ្រាន់ដូចជា រូបថត បណ្ណកម្មសិទ្ធិ ហត្ថលេខាលើខ្នងរូបថត កិច្ចសន្យាជួលជាដើម ហើយបញ្ជូនបន្តតាមឋានានុក្រម ដើម្បីចុះបញ្ជីពន្ធដារ។

ដោយសារ អគ្គនាយដ្ឋានពន្ធដារ និងសាខាពន្ធដារបានទទួលការស្នើសុំចុះបញ្ជីដោយមិនមានឯកសារភ្ជាប់គ្រប់គ្រាន់ដូចខាងលើ នាំឱ្យដំណើរការនៃការចុះបញ្ជីអ្នកជាប់ពន្ធចំណាយពេលវេលាយូរ និងនាំឱ្យមានការមិនពេញចិត្តពីអ្នកស្នើសុំចុះបញ្ជីមួយចំនួន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីផ្តល់ព័ត៌មានដល់អគ្គនាយកដ្ឋានពន្ធដារក្នុងការចុះបញ្ជីក្រុមហ៊ុន។ ជាងនេះទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំដល់អគ្គនាយកដ្ឋានពន្ធដារឱ្យពិនិត្យភាពគ្រប់គ្រាន់នៃឯកសារចាំបាច់នានាដែលតម្រូវដោយរដ្ឋបាលសារពើពន្ធក្នុងការចុះបញ្ជីពន្ធមុនពេលទទួលសំណើសុំចុះបញ្ជីពន្ធ។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបានបំភ្លឺបន្ថែមថា កន្លងមក ការចុះបញ្ជីមានការយឺតយ៉ាវ ដោយឯកសារមួយចំនួនសល់ពីឆ្នាំចាស់ និងឯកសារមួយចំនួនដែលទទួលពីខេត្តខណ្ឌពុំមានភាពច្បាស់លាស់ ដោយខ្វះការសហការពីអ្នកជាប់ពន្ធ ជាពិសេសសហគ្រាសអ្នកជាប់ពន្ធតូច ទើបធ្វើឱ្យមានការយឺតយ៉ាវក្នុងការចុះបញ្ជីក្រុមហ៊ុន សហគ្រាស។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

**៣.១.២.ភាពយឺតយ៉ាវក្នុងការព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម**

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការប្រមូលពន្ធ ក៏ដូចជាការការពារ និងទប់ស្កាត់ការគេចវេះពន្ធ អង្គភាពសារពើពន្ធមានសិទ្ធិព្យួរទុក ឬដកហូតមកវិញនូវវិញ្ញាបនបត្រចុះបញ្ជីលើតម្លៃបន្ថែម ក្នុងករណីសហគ្រាសក្រុមហ៊ុនណាមួយមិនបានប្រកាសនូវការផ្គត់ផ្គង់ជាប់អាករក្នុងរយៈពេល ៣ខែជាប់គ្នា។ តាមការពិនិត្យស្ថិតិក្រុមហ៊ុនសហគ្រាសអ្នកជាប់ពន្ធមធ្យមក្នុងឆ្នាំ២០១៨ របស់សាខាពន្ធដារខណ្ឌចំនួន៤ និងខេត្តចំនួន១០ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានក្រុមហ៊ុនសហគ្រាសចំនួន៨៨០ ដែលបានដាក់លិខិតប្រកាសពន្ធប្រចាំខែសូន្យ (គ្មានសកម្មភាព) ក្នុងនោះសាខាពន្ធដារខេត្ត ខណ្ឌទាំងនោះបានព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមរបស់ក្រុមហ៊ុនសហគ្រាសចំនួន១៨៥ និងនៅសល់វិញ្ញាបនបត្រអាករលើតម្លៃបន្ថែមរបស់ក្រុមហ៊ុនសហគ្រាសមួយចំនួនទៀត មិនត្រូវបានព្យួរទុកឡើយ។

ការខកខានក្នុងការព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមរបស់ក្រុមហ៊ុនសហគ្រាស នាំឱ្យក្រុមហ៊ុន សហគ្រាសទាំងនោះមានឱកាសធ្វើសកម្មភាពសេដ្ឋកិច្ចដោយគេចវេសពន្ធ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយកដ្ឋានពន្ធដារឱ្យមានយន្តការចំពោះអ្នកជាប់ពន្ធដែលបានដាក់លិខិតប្រកាសពន្ធប្រចាំខែសូន្យ។

ឆ្លើយតបនឹងបញ្ហាខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបានបំភ្លឺបន្ថែមថា ចំពោះសហគ្រាសគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ) និងសហគ្រាសដាំដុះ (វិស័យកសិកម្ម) ដែលបានប្រកាសគ្មានផលរបរ (ប្រកាសពន្ធប្រចាំខែសូន្យ) មិនត្រូវបានព្យួរទុក ឬដកហូតវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមទេ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

**៣.១.៣.ការផ្ទេរក្រុមហ៊ុន សហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម**

អ្នកជាប់ពន្ធត្រូវបានធ្វើចំណាត់ថ្នាក់ទៅតាមកម្រិតនៃផលរបរ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបែងចែកជាបីប្រភេទ៖ អ្នកជាប់ពន្ធតូច គឺជាសហគ្រាស ឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធិដែលមានផលរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀល ដល់៧០០លានរៀល ឬមានផលរបរក្នុងរយៈពេលបីខែជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្ត...

អ្នកជាប់ពន្ធមធ្យម គឺជាសហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី៧០០លានរៀល ដល់ ៤ ០០០លានរៀល..... អ្នកជាប់ពន្ធធំ គឺជាសហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៤ ០០០លានរៀល....″។ តាមការធ្វើតេស្តលើក្រុមហ៊ុនសហគ្រាសអ្នកជាប់ពន្ធតូចមួយចំនួន នៅសាខាពន្ធដារខណ្ឌចំនួន២ និងខេត្តចំនួន១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មាន ក្រុមហ៊ុនសហគ្រាសមួយចំនួន មានផលរបរលើសពី៧០០លានរៀល ក្នុងឆ្នាំ២០១៨ ប៉ុន្តែ សាខាពន្ធដារខេត្តខណ្ឌទាំងនោះមិនទាន់បានចាត់វិធានការផ្ទេរសហគ្រាសទាំងនោះទៅជា អ្នកជាប់ពន្ធមធ្យមនៅឡើយ។

ដោយសារតែបុគ្គលដែលមានការតម្រូវឱ្យធ្វើការចុះបញ្ជីពន្ធខកខានក្នុងការចុះបញ្ជី បានធ្វើឱ្យរដ្ឋបាលសារពើពន្ធជួបការលំបាកក្នុងការគ្រប់គ្រងអ្នកជាប់ពន្ធ ប្រមូលពន្ធ និង ផ្តល់សេវា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរជំរុញឱ្យអគ្គនាយកដ្ឋានពន្ធដារបន្តពង្រឹងបន្ថែម ទៀតចំពោះអាជីវកម្មដ្ឋានដែលមិនបានមកចុះបញ្ជីពន្ធ។

ការខកខានក្នុងការផ្ទេរសហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យមអាចធ្វើឱ្យ ការប្រមូលពន្ធ និងអាកររបស់អគ្គនាយកដ្ឋានពន្ធដារ មិនទាន់អស់លទ្ធភាព។ អគ្គនាយក ដ្ឋានពន្ធដារគួរណែនាំសាខាពន្ធដារខេត្ត ខណ្ឌផ្ទេរសហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ ពន្ធមធ្យមឱ្យបានទាន់ពេលវេលា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងទទួលយកអនុសាសន៍របស់អាជ្ញាធរ សវនកម្មជាតិ។ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានវឌ្ឍនភាពជាបន្តទៀត។

### ៣.១.៤. ការមិនទាន់ចុះបញ្ជីអាជីវកម្មចំពោះបុគ្គលប្រកបអាជីវកម្មអចលនទ្រព្យ

ដើម្បីគ្រប់គ្រងអ្នកជាប់ពន្ធ ប្រមូលពន្ធ និងផ្តល់សេវាល្អដល់អ្នកជាប់ពន្ធ រដ្ឋបាល សារពើពន្ធបានលើកទឹកចិត្តបុគ្គលទាំងឡាយ ដែលធ្វើអាជីវកម្មឱ្យមកបំពេញកាតព្វកិច្ចចុះ បញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុង១៥ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមសកម្មភាពសេដ្ឋ កិច្ច។ ប្រសិនបើបុគ្គល ដែលមានការតម្រូវឱ្យធ្វើការចុះបញ្ជី ប៉ុន្តែមិនបានធ្វើការចុះបញ្ជីនោះ រដ្ឋបាលសារពើពន្ធអាចធ្វើការចុះបញ្ជីបុគ្គលនោះ។ តាមការពិនិត្យស្ថិតិអចលនទ្រព្យ និងធ្វើ តេស្តសំណុំឯកសារនៅសាខាពន្ធដារខេត្តចំនួន២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានបុគ្គលប្រកបអាជីវកម្មអចលនទ្រព្យមួយចំនួន ដែលមានផលរបរអាជីវកម្មត្រូវចុះបញ្ជី នៅរដ្ឋបាលសារពើពន្ធ នៅមិនទាន់បានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធនៅឡើយ។

ដោយសារតែបុគ្គលដែលមានការតម្រូវឱ្យធ្វើការចុះបញ្ជីខកខានក្នុងការចុះបញ្ជី វាធ្វើ ឱ្យរដ្ឋបាលសារពើពន្ធជួបការលំបាកក្នុងការគ្រប់គ្រងអ្នកជាប់ពន្ធ ប្រមូលពន្ធ និងផ្តល់សេវា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរជំរុញឱ្យអគ្គនាយកដ្ឋានពន្ធដារបន្តពង្រឹងបន្ថែមទៀតចំពោះ អាជីវកម្មដ្ឋានដែលមិនបានមកចុះបញ្ជីពន្ធ។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងទទួលយក អនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាព ជាបន្តទៀត។

### ៣.១.៥.ភាពយឺតយ៉ាវក្នុងការធ្វើសវនកម្មសម្រាប់កម្មវិធីសវនកម្មឆ្នាំ២០១៨

គោលបំណងនៃការធ្វើសវនកម្មសារពើពន្ធលើក្រុមហ៊ុន សហគ្រាសគឺជាការពង្រឹងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធ និងប្រមូលពន្ធពីការខកខាន ឬធ្វេសប្រហែលពីសំណាក់អ្នកជាប់ពន្ធ។ ដើម្បីសម្រេចគោលបំណងខាងលើ អង្គភាពសារពើពន្ធត្រូវរៀបចំកម្មវិធីសវនកម្មប្រចាំឆ្នាំ និងបញ្ចប់ការងារសវនកម្មពន្ធឱ្យបានទាន់ពេលវេលា។ តាមការពិនិត្យលើកម្មវិធីសវនកម្មរបស់សាខាពន្ធដារខណ្ឌចំនួន៨ និងខេត្តចំនួន៦ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៨ សាខាពន្ធដារខេត្តខណ្ឌខាងលើបានលើកកម្មវិធីសវនកម្មសរុបចំនួន១ ៧២៧ ក្នុងនោះសាខាពន្ធដារខាងលើបានបញ្ចប់ការធ្វើសវនកម្មលើក្រុមហ៊ុនសហគ្រាសចំនួន៩៩៨ នៅសល់មួយចំនួនទៀតមិនទាន់បានបញ្ចប់។

ភាពយឺតយ៉ាវក្នុងការធ្វើសវនកម្មសម្រាប់កម្មវិធីសវនកម្មឆ្នាំ២០១៨ នាំឱ្យអង្គភាពសារពើពន្ធយឺតយ៉ាវ ក្នុងការពង្រឹងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធ ជាពិសេសប្រមូលពន្ធពីការខកខាន ឬធ្វេសប្រហែលមិនបានទាន់ពេលវេលា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយកដ្ឋានពន្ធដារឱ្យរៀបចំកម្មវិធីសវនកម្មដោយផ្អែកមូលដ្ឋានប្រាកដនិយម។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបានបំភ្លឺបន្ថែមថា ការយឺតយ៉ាវនេះកើតឡើងដោយបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធកត្តាធនធានមនុស្ស និងខ្វះការសហការពីអ្នកជាប់ពន្ធ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

### ៣.១.៦.ការយឺតយ៉ាវក្នុងការផ្តល់សេវាចំពោះឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រារបស់អ្នកជាប់ពន្ធមួយចំនួន

អគ្គនាយកដ្ឋានពន្ធដារបានប្តេជ្ញាធ្វើកំណែទម្រង់ក្នុងអង្គភាពពន្ធ ជាពិសេសការផ្តល់សេវាអប់រំ និងសេវាសាធារណៈ ដូចជាកំណត់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិរយៈពេល ៤-៨ ថ្ងៃ (ថ្ងៃធ្វើការ)។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាពន្ធដារខេត្តចំនួន១ បានផ្តល់សេវាលើការផ្ទេរកម្មសិទ្ធិចំពោះសំណុំឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រារបស់អ្នកជាប់ពន្ធមួយចំនួនមានការយឺតយ៉ាវពី ១ខែ ដល់ទៅ ២ខែ ។ ភាពយឺតយ៉ាវក្នុងការផ្តល់សេវាផ្ទេរកម្មសិទ្ធិ អាចនាំឱ្យការអនុវត្តការងារពុំទាន់មានប្រសិទ្ធភាព និងអាចនាំឱ្យមានការថ្នាំងថ្នាក់ពីអ្នកជាប់ពន្ធមួយចំនួន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយកដ្ឋានពន្ធដារឱ្យត្រួតពិនិត្យតាមដានការផ្តល់សេវាលើការផ្ទេរកម្មសិទ្ធិ។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ ដូច្នេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

### ៣.១.៧.ភាពសហការគ្នាមិនទាន់មានភាពរលូននិងប្រទាក់ក្រឡាគ្នារវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

ដើម្បីប្រមូលពន្ធ និងអាករឱ្យអស់លទ្ធភាព និងទាន់ពេលវេលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើតក្រុមការងារចម្រុះរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាក្នុងគោលបំណងផ្តល់ជូនគ្នាទៅវិញទៅមកនូវព័ត៌មាន និងទិន្នន័យនានាទាក់ទងនឹងសកម្មភាពនាំចេញ និងនាំចូលរបស់ក្រុមហ៊ុន សហគ្រាស។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងឆ្នាំ២០១៨ អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយដ្ឋានគយ និងរដ្ឋាករកម្ពុជាបានធ្វើកិច្ចសហការផ្តល់ជូនគ្នាទៅវិញទៅមកនូវព័ត៌មាន និងទិន្នន័យរបស់ក្រុមហ៊ុនពុំទាន់បានល្អនៅឡើយ ដោយមានការយឺតយ៉ាវក្នុងការផ្តល់ជូនគ្នាទៅវិញទៅមកនូវព័ត៌មាន និងទិន្នន័យរបស់ក្រុមហ៊ុនមួយចំនួន។

ការផ្តល់ព័ត៌មាន និងទិន្នន័យរបស់ក្រុមហ៊ុនដែលមានសកម្មភាពនាំចេញ និងនាំចូលមិនទាន់ពេលវេលាអាចនាំឱ្យអគ្គនាយកដ្ឋានពន្ធដារជួបការលំបាកក្នុងការធ្វើសវនកម្មបញ្ជាក់លើភាពត្រឹមត្រូវនៃការប្រកាសពន្ធ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអង្គភាពទាំងពីរនេះ ឱ្យពង្រឹងកិច្ចសហការគ្នាឱ្យបានទាន់ពេលវេលា ដើម្បីគ្រប់គ្រងសហគ្រាស និងប្រមូលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបានបំភ្លឺបន្ថែមថា បញ្ហានេះកើតឡើងដោយសារភាពរអាក់រអួលផ្នែកបច្ចេកទេសខ្លះ ដោយសារមន្ត្រីនៃអគ្គនាយកដ្ឋានទាំងពីរកំពុងស្ថិតក្នុងដំណើរការពិភាក្សាគ្នាលើទម្រង់ និងប្រភេទព័ត៌មាននៅឡើយ ដែលធ្វើឱ្យការផ្លាស់ប្តូរព័ត៌មានរវាងអគ្គនាយដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារនៅមិនទាន់មានភាពរលូនទាំងស្រុង។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

### ៣.១.៨. ការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយនៅមានកម្រិត

នាយកដ្ឋានសវនកម្មគយបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាលើការងារសវនកម្មគយ ដោយមានតួនាទី និងភារកិច្ច ដូចជា កសាងផែនការ និងចាត់ចែងធ្វើសវនកម្មគយលើអាជីវកម្មដ្ឋានតាមគោលការណ៍គ្រប់គ្រងហានិភ័យ ប្រមូល វិភាគ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន និងទិន្នន័យពីប្រភពនានាបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន និងប្រព័ន្ធគ្រប់គ្រងលក្ខណៈវិនិច្ឆ័យជ្រើសរើសហានិភ័យ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានអនុញ្ញាតបណ្តាអង្គការ ស្ថានទូត វិនិយោគទុនកាត់ដេរ អំណោយ ជំនួយ ការនាំចូលបណ្តោះអាសន្ន និងវិនិយោគទុនផ្សេងៗ នាំចូលនូវសម្ភារ បរិក្ខារ វត្ថុធាតុដើម និងទំនិញគ្រប់ប្រភេទដោយប្រាក់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋដែលមានទឹកប្រាក់សរុបចំនួន ៨ ៦៩២ ៨៧៤ លានរៀល។

តាមការធ្វើសវនកម្មនៅនាយកដ្ឋានសវនកម្មគយ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា នៅក្នុងឆ្នាំ២០១៨ នាយកដ្ឋានសវនកម្មគយបានចុះធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ (PCA) បានចំនួន២៩ ក្រុមហ៊ុន ក្នុងនោះ ក្រុមហ៊ុនវិនិយោគទុនកាត់ដេរចំនួន ១៥ និងក្រុមហ៊ុនវិនិយោគទុនមិនមែនកាត់ដេរចំនួន៨ ព្រមទាំងបានអញ្ជើញក្រុមហ៊ុននាំចូលក្នុងរបបស្ថាពរបានចំនួន៦មកបំភ្លឺការងារមួយចំនួនប៉ុណ្ណោះ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបានបំភ្លឺបន្ថែមថា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា មានការរៀបចំរចនាសម្ព័ន្ធថ្មីសម្រាប់នាយកដ្ឋានមួយចំនួន ស្របតាមអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នាយកដ្ឋានសវនកម្មគយជានាយកដ្ឋានគ្រប់គ្រង និងប្រតិបត្តិលើការងារគ្រប់គ្រងហានិភ័យ និងសវនកម្មគយ ដែលទើបបំបែកចេញពីនាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ ហើយទើបតែងតាំងប្រធាននាយកដ្ឋានឱ្យទទួលខុសត្រូវនាខែធ្នូ ឆ្នាំ២០១៨នេះ។ ការជ្រើសរើសក្រុមហ៊ុនធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ត្រូវបានជ្រើសរើសតាមប្រព័ន្ធគ្រប់គ្រងហានិភ័យ ដែលបានកំណត់តាមលក្ខណៈវិនិច្ឆ័យជ្រើសរើសហានិភ័យច្បាស់លាស់ ស្របតាមធនធានមនុស្សដែលមាន និងតាមផែនការសកម្មភាពជ្រើសរើសប្រចាំឆ្នាំ។ ទោះបីការងារសវនកម្មគយបានធ្វើការជ្រើសរើសធ្វើសវនកម្មតិចតួចលើបណ្តាអង្គការ ស្ថានទូត វិនិយោគទុនកាត់ដេរ អំណោយ ជំនួយ ការនាំចូលបណ្តោះអាសន្ន និងវិនិយោគទុនផ្សេងៗ នាំចូលនូវសម្ភារបរិក្ខារ វត្ថុធាតុដើម និងទំនិញគ្រប់ប្រភេទដោយប្រាក់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋក៏ដោយ ក៏នាយកដ្ឋានរបបគយ តែងតែតាមដានការប្រើប្រាស់ទំនិញទាំងនោះ បន្ទាប់ពីនាំចូលតាមរយៈការចុះទៅដល់អាជីវកម្មដ្ឋានទាំងនោះ ដើម្បីពិនិត្យ និងកត់ត្រាការប្រើប្រាស់ផងដែរ។ ទន្ទឹមនេះ ក្នុងឆ្នាំ២០១៩ នាយកដ្ឋានសវនកម្មគយ បានរៀបចំរចនាសម្ព័ន្ធថ្មី និងបានជ្រើសរើសបណ្តាក្រុមហ៊ុនវិនិយោគក្រោមរបប QIP និង Non-QIP សរុបចំនួន ៣៥០ ក្រុមហ៊ុន ដើម្បីធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

**៣.១.៩.ទំនិញនាំចូលជាប់កម្រិតកំណត់មិនស្របតាមលិខិតអនុញ្ញាតរបស់ក្រសួងស្ថាប័ន**

អនុក្រឹត្យស្តីពីការកែសម្រួលលើកំណត់សម្គាល់II ឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ បានបញ្ជាក់ថា ការអនុញ្ញាតឱ្យនាំចេញ ឬនាំចូលទំនិញជាប់កម្រិតកំណត់ដោយតម្រូវមានអាជ្ញាបណ្ណ លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រផ្សេងៗ ព្រមទាំងឯកសារគតិយុត្តដែលមានទម្រង់ប្រហាក់ប្រហែលជាមុន ឬស្ថិតក្រោមប្រព្រឹត្តិកម្មដោយឡែក

មួយចំនួនពីអាជ្ញាធរមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល រួមមាន ក្រសួង ស្ថាប័ន ឬអង្គភាពជំនាញមានសមត្ថកិច្ចពាក់ព័ន្ធស្របតាមច្បាប់ ឬបទប្បញ្ញត្តិនានាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

តាមការធ្វើសវនកម្មនៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនមួយចំនួនដែលនាំចូលទំនិញជាប់កម្រិតកំណត់ ដូចជាម៉ាស៊ីនត្រជាក់បានធ្វើការប្រកាសបរិមាណនាំចូល និងយថាប្រភេទមិនស្របតាមលិខិតអនុញ្ញាតរបស់ក្រសួងបរិស្ថាននៅឡើយ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបានបញ្ជាក់បន្ថែមថា ក្នុងការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ មានមុខសញ្ញាដែលមានហានិភ័យខ្ពស់ប៉ុណ្ណោះត្រូវបានជ្រើសរើសធ្វើការត្រួតពិនិត្យលម្អិត ទាំងឯកសារ និងការត្រួតពិនិត្យរូបវ័ន្ត។ ដោយឡែក ចំពោះមុខសញ្ញាដែលមិនសូវមានហានិភ័យ ការត្រួតពិនិត្យជាទូទៅត្រូវបានធ្វើឡើងក្នុងរូបភាពចោះៗប៉ុណ្ណោះ។ យោងតាមអនុក្រឹត្យ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ជាធរមាន (កំណត់សម្គាល់ II.៨ នៃឧបសម្ព័ន្ធ២) មានតែឧបករណ៍ត្រជាក់ប្រភេទប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូនប៉ុណ្ណោះ ដែលត្រូវស្នើសុំការអនុញ្ញាតពីក្រសួងបរិស្ថាន។ ជាទូទៅ ម៉ាស៊ីនត្រជាក់ និងទូក្លាសេប្រភេទថ្មីត្រូវបានផលិតជាមួយហ្គាសដែលពុំមែនជាសារធាតុបំផ្លាញស្រទាប់អូហ្សូនឡើយ។ ដូច្នេះ ម៉ាស៊ីនត្រជាក់ និងទូក្លាសេប្រភេទថ្មីមិនត្រូវបានចាត់ទុកថាជាមុខសញ្ញាមានហានិភ័យខ្ពស់ផ្នែកបរិស្ថានទេ ទើបបានជាមន្ត្រីគយមានសមត្ថកិច្ចពុំបានធ្វើការត្រួតពិនិត្យលម្អិត។ ម្យ៉ាងទៀត មុខទំនិញម៉ាស៊ីនត្រជាក់ និងទូក្លាសេក៏ជាមុខទំនិញដែលត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថានក្រោយការនាំចូលផងដែរ ដែលអ្នកនាំចូលត្រូវបានតម្រូវឱ្យតម្កល់ប្រតិវេទន៍នាំចូលនៅក្រសួងបរិស្ថាន ដើម្បីតាមដានយថាប្រភេទបំផ្លាញស្រទាប់អូហ្សូនទាំងនេះ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១០.ការយឺតយ៉ាវក្នុងការជម្រះបញ្ជីប្រាក់កក់សម្រាប់បង់ពន្ធលើរថយន្តចង្កូតស្តាំ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីនិមុត្តិធានា ត្រង់ប្រការ១ ចែងថា រដ្ឋបាលគយអាចតម្រូវឱ្យតម្កល់នូវនិមុត្តិធានា ដើម្បីធានានូវការបង់ពន្ធ និងអាករ ឬដើម្បីធានាថាប្រតិវេទន៍ករ និងភាគីទទួលខុសត្រូវផ្សេងៗទៀតបំពេញនូវកាតព្វកិច្ចតាមនីតិវិធីគយ ឬការអនុវត្តច្បាប់ផ្សេងៗទៀត និងត្រង់ប្រការ៩ នៃប្រកាសខាងលើបានបញ្ជាក់ថា រដ្ឋបាលគយត្រូវដោះបន្ទុកនិមុត្តិធានាឱ្យបានឆាប់តាមដែលអាចធ្វើទៅបានក្រោយពេលដែលមន្ត្រីគយមានសមត្ថកិច្ចពិនិត្យឃើញថា កាតព្វកិច្ចនានានៃនិមុត្តិធានាត្រូវបានបំពេញរួចរាល់រាប់បញ្ចូលទាំងការបង់ពន្ធ និងអាករ។

តាមការធ្វើសវនកម្មនៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានសមតុល្យគណនីប្រាក់កក់សល់ចុងឆ្នាំ២០១៨ ចំនួន១៣ ០២៤ ៥៦៧ដុល្លារអាមេរិក និងប្រាក់កក់ជារៀលចំនួន៤១ ៦០២ ០០០ ៧៩២រៀល ក្នុងនោះប្រាក់កក់មួយចំនួនជាប្រាក់កក់ សម្រាប់បង់ពន្ធលើរថយន្តចង្កូតស្តាំ ដែលរយៈពេលសម្រាប់ទទួលការបង់ពន្ធលើរថយន្តចង្កូតស្តាំបានហួសសុពលភាពនៃការបង់ពន្ធទៅហើយ ប៉ុន្តែអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៅពុំទាន់មានវិធានការ និងដំណោះស្រាយប្រាក់កក់ដែលនៅសល់ទាំងនោះនៅឡើយ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបានបំភ្លឺបន្ថែម ដូចខាងក្រោម៖

- ការតម្កល់និមុត្តិធានាត្រូវបានកើតឡើងជាបន្តបន្ទាប់ ហើយការដោះបន្ទុកក៏ត្រូវបានធ្វើជាហូរហែ ក្រោយពេលកាតព្វកិច្ចនានានៃនិមុត្តិធានាត្រូវបានបំពេញរួចរាល់រាប់បញ្ចូលទាំងការបង់ពន្ធ និងអាករ ដោយអនុលោមតាមប្រកាសលេខ១១២ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីនិមុត្តិធានា។

- ដោយឡែកមានករណីខ្លះនិមុត្តិធានាត្រូវបានរក្សាទុកយូរ ឬមិនអាចជម្រះចូលថវិកាជាតិបានទេ (ដោយសារតែលក្ខខណ្ឌនៃនិមុត្តិធានា ត្រូវបានតម្រូវឱ្យតម្កល់ដើម្បីធានាការប្រកបធុរកិច្ចជើងសាគយប្រតិបត្តិករឃ្លាំងគយមានដែនកំណត់ និងប្រតិបត្តិករទីកន្លែងសន្និធិគយបណ្តោះអាសន្នជាដើម។

- ករណីនិមុត្តិធានានៃរថយន្តចង្កូតស្តាំត្រូវបានរក្សាទុកយូរដូចបានលើកឡើងដោយអាជ្ញាធរសវនកម្មជាតិខាងលើ គឺដោយសារម្ចាស់មិនចូលខ្លួនមកដោះបន្ទុក។ ការអនុវត្តវិធានការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ដើម្បីបង្វែថវិកាចូលថវិកាជាតិ លុះត្រាតែអស់លទ្ធភាពស្វែងរកម្ចាស់ ឬមានការបញ្ជាក់អះអាងពីម្ចាស់ថា ព្រមបោះបង់ចោល រួចមានការសម្រេចឱ្យរឹបអូសដោយដីការបស់តុលាការ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១១.ការត្រួតពិនិត្យអនុលោមភាពទំនិញនាំចូលដែលទទួលបានការអនុគ្រោះព្បួរឬលើកលែងពន្ធអាករនៅមានកម្រិត

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានបញ្ជាក់ថានាយកដ្ឋានរបបគយបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាលើការងាររបបគយដោយមានតួនាទី និងភារកិច្ច ដូចជា ត្រួតពិនិត្យ និងគ្រប់គ្រងការចេញលិខិតអនុញ្ញាតគយនាំចេញ នាំចូលទំនិញតាមរបបគយអនុគ្រោះនានាតាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងមានភារកិច្ចតាមដានត្រួតពិនិត្យការប្រើប្រាស់

សម្ភារ បរិក្ខារ និងទំនិញគ្រប់ប្រភេទដែលទទួលបានការអនុគ្រោះនានាតាមទិសដៅដែលបានកំណត់។

តាមការធ្វើសវនកម្មនៅនាយកដ្ឋានរបបគយ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងឆ្នាំ២០១៨ ទំនិញនាំចូល ដូចជា សម្ភារ បរិក្ខារ វត្ថុធាតុដើម និងទំនិញគ្រប់ប្រភេទដែលមានលក្ខណៈជាវិនិយោគទុនកាត់ដេរ និងវិនិយោគទុនផ្សេងៗ ដោយទទួលបាននូវរបបអនុគ្រោះក្រោមរបបព្យួរពន្ធ ឬលើកពន្ធអាករដែលមានទឹកប្រាក់ចំនួន ៧ ៥៣០ ៦៩២ លានរៀល។ ប៉ុន្តែ ការិយាល័យក្រោមចំណុះនាយកដ្ឋានរបបគយពុំមានរបាយការណ៍ស្តីពីការចុះត្រួតពិនិត្យតាមដានអនុលោមភាពលើការប្រើប្រាស់សម្ភារ បរិក្ខារ វត្ថុធាតុដើម និងទំនិញគ្រប់ប្រភេទដែលទទួលបាននូវរបបអនុគ្រោះពន្ធនៅឡើយ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងសូមបំភ្លឺបន្ថែមថា អនុវត្តតាមតួនាទី និងភារកិច្ច ដូចមានចែងក្នុងប្រកាសលេខ១៤៧ សហវ.ប្រក នាយកដ្ឋានរបបគយបានចាត់មន្ត្រីចូលរួមជាមួយគណៈកម្មការអន្តរស្ថាប័ន (ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា) និងសហការជាមួយមន្ត្រីនៃនាយកដ្ឋានពាក់ព័ន្ធនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានចុះពិនិត្យលើសំណើសុំលក់ ផ្ទេរ ទទួល កម្ទេច និងបោះបង់ចោលនូវគ្រឿងម៉ាស៊ីន សម្ភារ បរិក្ខារ និងវត្ថុធាតុដើម ដែលទទួលបានការលើកទឹកចិត្តរបស់ក្រុមហ៊ុនវិនិយោគមួយចំនួន។ ការចុះត្រួតពិនិត្យនេះ នាយកដ្ឋានរបបគយបានធ្វើរបាយការណ៍ជាប្រចាំជូនអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ ទន្ទឹមនឹងការចុះពិនិត្យតាមដានជាមួយគណៈកម្មការអន្តរស្ថាប័ននេះ នាយកដ្ឋានរបបគយ ក៏បានចូលរួមត្រួតពិនិត្យលើអនុលោមភាព និងបានធ្វើវិចារណកម្មលើមុខទំនិញ ដែលពុំគួរទទួលបានការលើកទឹកចិត្ត និងបានតម្រូវឱ្យស្ថាប័ន ក្រុមហ៊ុន ឬអង្គការមួយចំនួនបំពេញកាតព្វកិច្ចពន្ធអាករផងដែរ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១២.ការគ្រប់គ្រងទិន្នន័យពីកម្រៃបង់សេវាតម្កល់ប្រតិវេទន៍របស់ក្រុមហ៊ុនមិនទាន់បានត្រឹមត្រូវ និងពេញលេញ

ដើម្បីគ្រប់គ្រងការផ្តល់សេវាសាធារណៈ ក៏ដូចជាការគ្រប់គ្រងប្រមូលចំណូលពីកម្រៃសេវាសាធាណៈរបស់រដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានសហការគ្នាចេញប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ត្រង់ចំណុចយលេខរៀងទី១០ សេវាតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ តម្លៃសេវាត្រូវបង់ចំនួន៨០ ០០០រៀល។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការគ្រប់គ្រងទិន្នន័យពីកម្រៃបង់សេវារបស់ក្រុមហ៊ុនពាណិជ្ជកម្ម និងអាជីវកម្មក្នុងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំមិនបានពេញលេញ និង

ត្រឹមត្រូវនៅឡើយ ដោយក្នុងនោះមានលម្អៀងខ្វះទិន្នន័យក្រុមហ៊ុនដែលបានដាក់តម្កល់ប្រតិវេទន៍ប្រចាំឆ្នាំមានចំនួន១ ៥៥៧ ក្រុមហ៊ុនស្មើទឹកប្រាក់ចំនួន១២៤ ៥៦០ ០០០រៀល ទៀតពីរបាយការណ៍ចំណូល និងបង់ចូលថវិការដ្ឋ។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្មគួរធ្វើការគ្រប់គ្រងទិន្នន័យពីការបង់កម្រៃសេវាតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនឱ្យបានពេញលេញ និងត្រឹមត្រូវទៅតាមចំនួនប្រតិវេទន៍ដែលបានតម្កល់ប្រចាំឆ្នាំ។

ឆ្លើយតបនឹងករណីនេះ ក្រសួងពាណិជ្ជកម្មបានធ្វើការបញ្ជាក់ថាៈ ក្រសួងពាណិជ្ជកម្មបានដឹងនូវចំណុចខ្វះចន្លោះនេះ បច្ចុប្បន្នក្រសួងពាណិជ្ជកម្មកំពុងសិក្សាជាមួយក្រុមហ៊ុន Foster Moore International Limited ដែលជាក្រុមហ៊ុនផ្គត់ផ្គង់ និងថែទាំប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីពាណិជ្ជកម្ម និងធនាគារដៃគូ ដើម្បីធ្វើការកែលម្អបន្ថែមចំពោះបញ្ហានេះ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងពាណិជ្ជកម្ម។ ដូច្នេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១៣.ការរៀបចំបញ្ជីបេឡាសាច់ប្រាក់នៅធនាគារ

សារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨ ស្តីពីកិច្ចបញ្ជិកាគណនេយ្យ រជ្ជទេយ្យករចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ចំណុចទី៩ ចែងថា រជ្ជទេយ្យករចំណូលត្រូវបង្កើតបញ្ជីបេឡាសាច់ប្រាក់នៅក្នុងដៃ និងបញ្ជីបេឡាសាច់ប្រាក់នៅធនាគារដាច់ដោយឡែកពីគ្នា។

តាមការត្រួតពិនិត្យឯកសារ និងការសាកសួររជ្ជទេយ្យករចំណូល អាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញថា រជ្ជទេយ្យករចំណូលនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានរៀបចំតែបញ្ជីបេឡាតាមដានសាច់ប្រាក់នៅក្នុងដៃ ប៉ុន្តែពុំទាន់បានរៀបចំបញ្ជីបេឡាគ្រប់គ្រាន់សម្រាប់តាមដានសាច់ប្រាក់នៅធនាគារនៅឡើយទេ ដែលកត្តានេះអាចនាំឱ្យប៉ះពាល់ដល់ការគ្រប់គ្រងបេឡាសាច់ប្រាក់នៅធនាគារ និងការកត់ត្រាចំណូលសាច់ប្រាក់តាមរយៈធនាគារ។

ដូចនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិគួរធ្វើការរៀបចំបញ្ជីបេឡាសាច់ប្រាក់នៅធនាគារឱ្យបានត្រឹមត្រូវស្របតាមសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងបេឡាសាច់ប្រាក់នៅធនាគារ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានបញ្ជាក់ថា ក្រសួងបានកែលម្អរួចហើយ ចាប់ពីខែមករា ឆ្នាំ២០១៩ តរៀងមក។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១៤.ភាពយឺតយ៉ាវក្នុងការចេញអាជ្ញាបណ្ណជូនគ្រឹះស្ថានសិក្សា

ប្រកាសលេខ២៧៩២ អយក.ប្រក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ច្រកចេញចូលតែមួយ និងកន្លែងទទួលពាក្យបណ្តឹងតវ៉ាលើការផ្តល់សេវាសាធារណៈ និងប្រកាសរួមលេខ១០១១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រង់ប្រការ១ បានបញ្ជាក់ថា "អនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡា អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។ កម្រៃសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាពទៅតាមប្រភេទសេវាសាធារណៈនីមួយៗ។

តាមការធ្វើតេស្តលើសំណុំឯកសារ និងរបាយការណ៍លទ្ធផលស្តីពីការងារច្រកចេញចូលតែមួយ និងកន្លែងទទួលពាក្យបណ្តឹងតវ៉ា នៃការផ្តល់សេវាអប់រំ យុវជន និងកីឡា ប្រចាំឆ្នាំ២០១៨ និងការធ្វើតេស្តលើឯកសារដាក់ពាក្យសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថាន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ច្រកចេញចូលតែមួយបានទទួលឯកសារដាក់ពាក្យសុំបើកគ្រឹះស្ថានក្នុងឆ្នាំ២០១៨ សរុបចំនួន ១៥៨ ក្នុងនោះពាក្យស្នើសុំបើកសាលាចំនួន១២៦ (ចាប់ពីកម្រិតមត្តេយ្យដល់មធ្យមសិក្សាទុតិយភូមិ) និងគ្រឹះស្ថានមានចំនួន១០ និងបន្តនីតិវិធីឯកសារនៅសល់ពីឆ្នាំ២០១៧ ចំនួន២២។ ច្រកចេញចូលតែមួយបានចេញអាជ្ញាប័ណ្ណជូនគ្រឹះស្ថានក្នុងឆ្នាំ២០១៨បានចំនួន១៣៥ ក្នុងនោះចំនួន១០៣ ជាសាលា (ចាប់ពីកម្រិតមត្តេយ្យដល់មធ្យមសិក្សាទុតិយភូមិ) និងគ្រឹះស្ថានចំនួន១០ និងនៅសល់ចុងឆ្នាំ២០១៧ ចំនួន២២ទៀត ច្រកចេញចូលតែមួយបានយកតម្លៃសេវាស្របតាមប្រកាសរួម លើកលែងតែរយៈពេលផ្តល់សេវានៃការផ្តល់អាជ្ញាប័ណ្ណជូនគ្រឹះស្ថាននៅមានភាពយឺតយ៉ាវនៅឡើយ។

ភាពយឺតយ៉ាវនេះ នាំឱ្យការអនុវត្តប្រកាសខាងលើពុំទាន់ពេញលេញ។ ក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំច្រកចេញចូលតែមួយឱ្យអនុវត្តការងារតាមប្រកាសខាងលើឱ្យមានប្រសិទ្ធភាព។ ក្រសួងអប់រំ យុវជន និងកីឡាបានឯកភាពចំពោះចំណុចកត់សម្គាល់ខាងលើ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១៥.ភាពយឺតយ៉ាវក្នុងការប្រមូលចំណូលពីផលទុនអាកាសចរបង់ចូលថវិការដ្ឋ

អនុក្រឹត្យលេខ៨២ អនក្រ បក.ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញានៃគណនេយ្យសាធារណៈ ត្រង់ចំណុចទី៣ មាត្រា១០៦ បានចែងថា " ចំណូលថវិកាទោះបីស្ថិតក្នុងចំណូលប្រភេទណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយតាមទំនើងចិត្ត ឬពន្យារពេលបង់ចូលថវិការដ្ឋ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយឡើយ"។

តាមការពិនិត្យរបាយការណ៍ស្តីពីការអនុវត្តចំណូល និងការបែងចែកប្រាក់រង្វាន់ពីកម្រៃសេវាសាធារណៈ ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៨ និងសលាកប័ត្របង់ចំណូលចូលថវិការដ្ឋ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនៅមានភាពយឺតយ៉ាវក្នុងការបង់ចំណូលមួយចំនួនពីផលទុនអាកាសចរស៊ីវិលចូលថវិការដ្ឋ។

អាស្រ័យហេតុនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលគួរធ្វើការបង់ចំណូលចូលថវិការដ្ឋដែលបានពីផលទុនអាកាសចរស៊ីវិលឱ្យបានគ្រប់ចំនួន និងទាន់ការិយបរិច្ឆេទនៃឆ្នាំថវិកា។

ឆ្លើយតបចំពោះការលើកឡើងខាងលើ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានឯកភាពទៅនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ។ ប៉ុន្តែរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានបញ្ជាក់ថា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានខិតខំប្រមូលចំណូលបង់ចូលថវិកាជាតិលើសផែនការជារៀងរាល់ឆ្នាំ។ ដោយឡែកទឹកប្រាក់មួយចំនួននេះគឺជាទឹកប្រាក់ដែលក្រុមហ៊ុនអាកាសចរណ៍ផ្សេងៗធ្វើការទូទាត់នូវកម្រៃសិទ្ធិហោះហើរតែម្ខាង (Royalty fees) និងកម្រៃសេវារដ្ឋបាល និងសេវាផ្សេងៗ ពីក្រៅប្រទេសចូលមកគណនីរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនៅធនាគារជាតិនៃកម្ពុជា នៅចន្លោះពីថ្ងៃទី២៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ហើយនៅក្នុងអំឡុងពេលនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលទទួលបានប្រកាសឥណទានពីធនាគារជាតិនៃកម្ពុជា មានការយឺតយ៉ាវគឺនៅចុងខែតែម្តង ដូច្នេះការបង់ចំណូលចូលថវិកាជាតិមិនអាចធ្វើក្នុងឆ្នាំបានទេ។ បច្ចុប្បន្ន ទឹកប្រាក់ទាំងនោះរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានបង់ចូលថវិកាជាតិនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ រួចរាល់អស់ហើយ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.១៦.ការប្រមូលចំណូលនៅមានកម្រិត**

ក្រសួងព័ត៌មាន បានកំណត់ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ២៤១ ព.មប្រក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរព័ត៌មាន រាជធានី ខេត្ត បានចែងថា មន្ទីរព័ត៌មានរាជធានី ខេត្ត មានសិទ្ធិចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលើវិស័យព័ត៌មាន និងសោតទស្សន៍នូវមុខរបរមួយចំនួន ដូចខាងក្រោម ៖

១. បោះពុម្ពដោយដៃ (អូសស្បៃ) បោះពុម្ពលើអាវយឺត

២. បណ្ណាគារ តូបលក់កាសែត តូបលក់សៀវភៅ ផលិតផលបោះពុម្ព និងផលិតផលសោតទស្សន៍

៣. អគារថតរូប ថតចល័ត សេវាជួសជុលម៉ាស៊ីនថត ម៉ាស៊ីនថតចម្លង សេវាជួសជុលកុំព្យូទ័រ វាយកុំព្យូទ័រ សេវាជួសជុលវិទ្យុ ទូរទស្សន៍ ម៉ាញ៉េ រ៉ូណេអូ អំភ្លី មេក្រូ ។ល។

៤. អគារលក់ឧបករណ៍សោតទស្សន៍

៥. សេវាគំនូរផ្ទាំង ស្លាកយីហោ និងយីហោ ។ល។

៦. អ៊ីនធើណែតកាហ្វេ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០១៨ មន្ទីរព័ត៌មានខេត្តកំពង់ធំ បានប្រមូលចំណូលពីសេវាសោតទស្សន៍លើស្លាកប៉ាណូ អាហ្វីស និងវិទ្យុ ទូរទស្សន៍ និងទូរទស្សន៍ខ្សែកាបប្រចាំឆ្នាំ២០១៨ សរុបទឹកប្រាក់ចំនួន ៥៣ ៣៨០ ៥០០ រៀល។ ប៉ុន្តែមន្ទីរនៅពុំទាន់បានធ្វើការប្រមូលចំណូលសម្រាប់មុខសញ្ញាចំណូលដទៃទៀតនៅឡើយទេ។

អាស្រ័យហេតុនេះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងចំណូល គួរជំរុញឱ្យមន្ទីរប្រមូលចំណូលឱ្យអស់លទ្ធភាព។

ឆ្លើយតបនឹងការលើកឡើង រដ្ឋបាលខេត្តកំពង់ធំបានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងខិតខំជួយជំរុញមន្ទីរឱ្យខិតខំប្រមូលចំណូលឱ្យអស់លទ្ធភាពស្របតាមប្រកាសរបស់ក្រសួងព័ត៌មាន។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

**៣.១.១៧.អ្នកប្រមូលចំណូលពុំមែនជារជ្ជទេយ្យករចំណូលរង**

បទបញ្ជាលេខ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ចំណុច១១ បានចែងថា "ហាមដាច់ខាតការប្រគល់ភារកិច្ចប្រមូល ឬទទួលចំណូល និងការទទួលខុសត្រូវប្រាក់កាសឱ្យមន្ត្រីដែលពុំមែនជារជ្ជទេយ្យករចំណូល"។

ប្រកាសលេខ១៨៩០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ផ្នែកទី២ ប្រការ៦ បានចែងថា "រជ្ជទេយ្យករចំណូលអាចមានរជ្ជទេយ្យករចំណូលរងមួយចំនួនជាជំនួយការតាមការចាំបាច់"។

តាមការពិនិត្យរបាយការណ៍ចំណូលប្រចាំឆ្នាំ បញ្ជីបេឡា បណ្ណចំណូល បង្កាន់ដៃបង់ប្រាក់ និងសម្ភាសន៍ជាមួយមន្ត្រីដែលជាអ្នកប្រមូលចំណូលនេះផ្ទាល់ ព្រមទាំងពិនិត្យប្រកាសអន្តរក្រសួងស្តីពីការតែងតាំងរជ្ជទេយ្យករចំណូលនៅក្រសួងសាធារណការ និងដឹកជញ្ជូន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការប្រមូលចំណូលពីការអនុញ្ញាតប្រកបអាជីវកម្មដឹកជញ្ជូនឆ្លង ចំណូលពីការអនុញ្ញាតដឹកជញ្ជូនផ្លូវទឹក ចំណូលពីការអនុញ្ញាតដឹកជញ្ជូនតាមនាវាសមុទ្រ និងចំណូលពីរដ្ឋបាលកំពង់ផែ ត្រូវបានប្រមូលដោយមន្ត្រីដែលពុំមែនជារជ្ជទេយ្យករចំណូលរងរបស់ក្រសួង។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនគួរចាត់ចែងឱ្យរជ្ជទេយ្យករចំណូលរងដើម្បីប្រមូលចំណូលខាងលើឱ្យបានត្រឹមត្រូវ។

ឆ្លើយតបចំពោះចំណុចនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនបានបំភ្លឺថា កន្លងមកក្រសួងបានតែងតាំងរជ្ជទេយ្យករចំណូលរងចំនួន៦រូប ក្នុងនោះដែរ អគ្គនាយដ្ឋានដឹក

ជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែមានរដ្ឋទេយ្យករចំណូលរងចំនួន២រូប ហើយមូលហេតុដែលរដ្ឋទេយ្យករចំណូលរងមិនបានចុះហត្ថលេខាលើបង្កាន់ដៃបង់ប្រាក់ ដោយសារកន្លងមកនាយកដ្ឋាននីមួយៗប្រមូលចំណូលដោយផ្ទាល់ និងចុះហត្ថលេខាលើបង្កាន់ដៃបង់ប្រាក់ផ្ទាល់តាំងពីនៅអគ្គនាយដ្ឋានដឹកជញ្ជូនមកម្ល៉េះ ម៉្យាងទៀតដោយសារការចុះហត្ថលេខាលើគំរូ (Specimen) ដែលអគ្គនាយដ្ឋានរតនាគារជាតិផ្តល់ឱ្យ គឺអាចចុះបានតែចំនួន៧រូប (រដ្ឋទេយ្យករចំណូលចំនួន១រូប និងរដ្ឋទេយ្យករចំណូលរងចំនួន៦រូប) ក៏ប៉ុន្តែបច្ចុប្បន្ននេះខាងអគ្គនាយដ្ឋានរតនាគារជាតិបានកែប្រែទម្រង់គំរូហត្ថលេខាថ្មី ដោយអាចឱ្យក្រសួងសាមីមានរដ្ឋទេយ្យករចំណូលរងច្រើនតាមការចាំបាច់របស់ខ្លួន ដូច្នេះនៅដើមឆ្នាំ២០២០នេះ ក្រសួងសាធារណការនិងដឹកជញ្ជូននឹងតែងតាំងរដ្ឋទេយ្យករចំណូលរងបន្ថែមទៀតនៅតាមនាយកដ្ឋានប្រមូលចំណូលផ្ទាល់។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.១៨.កង្វះខាតក្នុងការតាមដាន និងផ្ទៀងផ្ទាត់ចំណូល**

យោងកិច្ចព្រមព្រៀងវិនិយោគBCT រវាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រុមហ៊ុនCATSពុំមានចំណុចណាមួយបានចែងអំពីយន្តការ ឬនីតិវិធីនៃការត្រួតពិនិត្យ ឬការផ្ទៀងផ្ទាត់ចំណូលពីការហោះហើរឆ្លងកាត់ និងនាំផ្លូវចុះចត ហោះហើរដែលគ្រប់គ្រងប្រមូលដោយក្រុមហ៊ុនCATS នោះទេ។ ជាមួយនេះត្រង់មាត្រា៤ ចំណុច៤១ នៃកិច្ចព្រមព្រៀងបានចែងបានថា "រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលត្រូវទទួលខុសត្រូវទាំងអស់លើប្រព័ន្ធប្រតិបត្តិការបច្ចេកទេសដែលអនុវត្តដោយមន្ត្រីបច្ចេកទេសរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល"។

តាមការពិនិត្យជាក់ស្តែងលើរបាយការណ៍របស់ក្រុមហ៊ុនCATS (Cambodia Air Traffic Services) ដែលបានផ្ញើមករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលក្នុងរយៈពេល១ត្រីមាសម្តង អំពីការបែងចែកប្រាក់ចំណូលរវាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រុមហ៊ុនCATS គឺរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានទទួលតែរបាយការណ៍បែងចែកចំណូលដែលក្រុមហ៊ុនCATS បានផ្ញើជូនតែប៉ុណ្ណោះ ដោយពុំមានឯកសារណាមួយផ្សេងទៀតសម្រាប់ធ្វើការផ្ទៀងផ្ទាត់នូវភាពត្រឹមត្រូវនៃការបែងចែកចំណូលទាំងនេះទេ។ របាយការណ៍ហោះហើរឆ្លងកាត់ និងនាំផ្លូវចុះចតហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍ទាំងអស់ត្រូវបានរាយការណ៍ដោយមន្ត្រីបច្ចេកទេសជូនទៅក្រុមហ៊ុនCATSជាប្រចាំ ប៉ុន្តែមិនបានផ្ញើមករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនោះទេ។

អាស្រ័យហេតុនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលគួរបង្កើតយន្តការ ឬនីតិវិធីក្នុងការត្រួតពិនិត្យ ដើម្បីធ្វើការផ្ទៀងផ្ទាត់ចំណូលពីការហោះហើរឆ្លងកាត់ និងនាំផ្លូវចុះចតហោះហើរដែលគ្រប់គ្រងដោយក្រុមហ៊ុនCATS ដើម្បីបញ្ជាក់ភាពត្រឹមត្រូវ និងពេញលេញនៃការបែងចែកចំណូល។

ឆ្លើយតបនឹងចំណុចនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានបញ្ជាក់ថា ក្រុមហ៊ុនCATS បានផ្តល់របាយការណ៍ចំនួនជើងហោះហើរ ជារៀងរាល់ខែមករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីធ្វើការផ្ទៀងផ្ទាត់ចំណូល ហើយបច្ចុប្បន្នរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលកំពុងរៀបចំក្រុមការងារដើម្បីចូលរួមសហការជាមួយក្រុមហ៊ុនCATS ក្នុងការផ្ទៀងផ្ទាត់ចំណូលពីកម្រៃសេវាកម្មនាំផ្លូវអាកាស។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

**៣.១.១៩.ការចំណាយ និងការកត់ត្រាចំណាយមិនទាន់ស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ**

ប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តនូវចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាការបស់ថវិការដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

តាមការពិនិត្យលើអាណត្តិបើកប្រាក់ និងធ្វើតេស្តលើប្រតិបត្តិការចំណាយ អាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញថា មានក្រសួងមួយចំនួន បានអនុវត្តចំណាយមិនទាន់សមស្របទៅនឹងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋបាលកណ្តាល។

ឆ្លើយតបទៅនឹងករណីខាងលើនេះ ក្រសួងស្ថាប័នមួយចំនួនបានឯកភាពទៅនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ និងធ្វើការកែលម្អនូវចំណុចខ្វះខាតដែលនៅសេសសល់ទៅតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ ដោយឡែក ក្រសួងមួយចំនួនទៀតបានធ្វើសេចក្តីបញ្ជាក់ចំពោះករណីលើកឡើងខាងលើថា ដោយ សារប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី ០៩ ឧសភា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្ត នូវចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិការបស់ថវិការដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ មិនបានកំណត់មុខសញ្ញាចំណាយសាងសង់តូចតាចឱ្យបានច្បាស់លាស់ ម៉្យាងទៀត ការអនុវត្ត ជាក់ស្តែង គ្រប់ក្រសួងស្ថាប័ន តែងតែកត់ត្រាមុខចំណាយនេះ ក្នុងអនុគណនី ៦១០៥២ ហេតុនេះហើយ ក្រសួងនឹងពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកំណត់វិធានការសម្រាប់កត់ត្រាចំណាយនេះតទៅមុខទៀត។

ផ្អែកលើការឆ្លើយបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិ នឹងធ្វើការតាមដានការអនុវត្តអនុសាសន៍នេះបន្តទៅទៀត។

**៣.១.២០.ការចំណាយថវិកាបុរេប្រទានពុំស្របទៅនឹងកម្មវត្ថុនៃការចំណាយ**

ដើម្បីឱ្យការអនុវត្តចំណាយ និងកត់ត្រាចំណាយថវិការបស់រដ្ឋឱ្យស្របទៅនឹងប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ បានកំណត់ពីការចំណាយ និងកត់ត្រាចំណាយ អនុគណនី៦១១០៣ បានកំណត់ពីការចំណាយ និងកត់ត្រាចំណាយលើ

ការប្រជុំ សិក្ខាសាលា សន្និបាត ដូចជា ការរៀបចំទីកន្លែង អាហារ ការឧបត្ថម្ភគ្រូឧទ្ទេស និងអ្នកសម្របសម្រួល សន្តិសុខ និងចំណាយផ្សេងៗ។ អនុគណនី៦១១០៦ បានកំណត់ពីចំណាយដែលពាក់ព័ន្ធនឹងការរៀបចំតាំងពិព័រណ៍នៅក្នុង និងក្រៅប្រទេស។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានកិច្ចការពិព័រណ៍បានចំណាយថវិកាបុរេប្រទានក្នុងការរៀបចំពិព័រណ៍ រៀបចំតាំងបង្ហាញផលិតផលក្នុងប្រទេស និងពិព័រណ៍ផលិតផលផ្សេងៗ និងកត់ត្រាចំណាយថវិកាបុរេប្រទាននេះ ពុំទាន់ស្របទៅនឹងកម្មវត្ថុនៃចំណាត់ថ្នាក់អនុគណនីនៃមាតិកាថវិការបស់រដ្ឋ។

កត្តានេះ នាំឱ្យការចំណាយ និងកត់ត្រាចំណាយមិនស្របទៅនឹងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ និងធ្វើឱ្យប៉ះពាល់ដល់ការរៀបចំរបាយការណ៍សម្រេចទូទាត់ថវិកាប្រចាំឆ្នាំរបស់រដ្ឋ។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្មគួរធ្វើការចំណាយ និងកត់ត្រាចំណាយថវិកាឱ្យស្របទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ឆ្លើយតបនឹងករណីនេះ ក្រសួងពាណិជ្ជកម្មបានធ្វើការបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មបានដឹងនូវចំណុចខ្វះចន្លោះនេះដោយហេតុថា ពាក់ព័ន្ធនឹងការរៀបចំតាំងបង្ហាញ នាយកដ្ឋានកិច្ចការពិព័រណ៍នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម មានរៀបចំកម្មវិធីផ្សព្វផ្សាយ ក៏ដូចជាការណែនាំដល់ពាណិជ្ជករ អាជីវករ និងអាជ្ញាធរមូលដ្ឋានអំពីគោលនយោបាយ ផែនការសកម្មភាព និងកម្មវិធីផ្សេងៗ នៅមុនពេលប្រារព្ធកម្មវិធី។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក្រសួងពាណិជ្ជកម្មនឹងធ្វើការណែនាំដល់នាយកដ្ឋានជំនាញ ដើម្បីកែសម្រួលបញ្ហានេះ ឱ្យសមស្របទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងពាណិជ្ជកម្ម។ ដូច្នេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

### ៣.១.២១.ការរៀបចំកិច្ចបញ្ជិកាគណនេយ្យ សម្រាប់កត់ត្រាការចំណាយប្រាក់រដ្ឋទេយ្យបុរេប្រទាន

ប្រកាសលេខ០០២ សហវ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីកិច្ចបញ្ជិកាគណនេយ្យ រដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រង់ចំណុច៣ និងចំណុច៥ បានកំណត់ថា បញ្ជីគណនេយ្យរដ្ឋទេយ្យបុរេប្រទានមាន៖ បញ្ជីបេឡាសាច់ប្រាក់ សៀវភៅទិន្នានុប្បវត្តិទូទៅ សៀវភៅធំ ហើយរបាយការណ៍រដ្ឋទេយ្យករបុរេប្រទានរួមមាន តារាងតុល្យភាពគណនី។

តាមរយៈការត្រួតពិនិត្យឯកសាររដ្ឋទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០១៨ អាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញថា ការរៀបចំកិច្ចបញ្ជិកាគណនេយ្យរបស់រដ្ឋទេយ្យករបុរេ

ប្រទាននៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅពុំទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលកត្តានេះ អាចនាំឱ្យមានការលំបាកក្នុងការតាមដានប្រតិបត្តិការដែលបានកត់ត្រា។

ដូចនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិគួររៀបចំកិច្ចបញ្ជិកាគណនេយ្យឱ្យបានគ្រប់គ្រាន់ ដើម្បីងាយស្រួលក្នុងការតាមដានប្រតិបត្តិការ និងងាយស្រួលក្នុងការផ្ទៀងផ្ទាត់។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានបញ្ជាក់ថា ក្រសួងកំពុងធ្វើការកែលម្អចំណុចនេះឱ្យបានគ្រប់ជ្រុងជ្រោយតាមប្រកាសលេខ០០២ សហវ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

### ៣.១.២២.ការប្រើប្រាស់សក្ខីបត្រចំណាយឆ្នាំ២០១៧មកធ្វើការទូទាត់ឥណទានថវិកាចំណាយឆ្នាំ២០១៨

ដើម្បីឱ្យការចំណាយ និងការទូទាត់ចំណាយថវិការដ្ឋឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលានៃឆ្នាំថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញនូវសារាចរណែនាំលេខ០០៩ សហវ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ ស្តីពីការបិទបញ្ជីចំណូលចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៨ ត្រង់ចំណុច គ ចុច១ និង២ បានកំណត់ថា "រជ្ជទេយ្យករបុរេប្រទានត្រូវប្រមូលសក្ខីបត្រ និងលិខិតយុត្តិការចំណាយដែលបានទូទាត់ជូនអាណាប័ក ដើម្បីបោះផ្សាយអាណត្តិនីយ័តកម្មទូទាត់ជម្រះបញ្ជីរជ្ជទេយ្យបុរេប្រទានឱ្យបានទាន់ពេលក្នុងថវិកាឆ្នាំ២០១៨ និងប្រាក់បុរេប្រទានគឺជាការបើកផ្តល់ប្រាក់ចំណាយមុននៅក្នុងករណីចាំបាច់បន្ទាន់។ ការផ្តល់ប្រាក់បុរេប្រទានត្រូវបញ្ឈប់នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ហើយការទូទាត់ប្រាក់បុរេប្រទាននេះក៏ត្រូវរួតរះប្រមូលឯកសារសុំទូទាត់ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងពាណិជ្ជកម្មបានប្រើប្រាស់សក្ខីបត្រចំណាយពីឆ្នាំ២០១៧ មកធ្វើការទូទាត់ឥណទានចំណាយថវិកាក្នុងឆ្នាំ២០១៨។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្មគួរធ្វើការប្រមូលសក្ខីបត្រទូទាត់ចំណាយថវិកាឱ្យបានទាន់ពេលវេលា ដើម្បីជៀសវាងការយកប្រតិបត្តិការចំណាយឆ្នាំចាស់មកធ្វើការទូទាត់ឆ្នាំថ្មីដែលនាំឱ្យប៉ះពាល់ដល់ការរៀបចំរបាយការណ៍សម្រេចទូទាត់ថវិការដ្ឋប្រចាំឆ្នាំ។

ឆ្លើយតបនឹងករណីនេះ ក្រសួងពាណិជ្ជកម្មបានធ្វើការបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មបានដឹងនូវចំណុចខ្វះចន្លោះនេះ ដោយហេតុថា ឥណទានថវិកានៅមានកម្រិត ហើយសកម្មភាពរបស់ក្រសួងមានច្រើន ដែលជាហេតុធ្វើឱ្យខ្វះឥណទានថវិកាសម្រាប់ទូទាត់ក្នុង

ឆ្នាំ ដូច្នេះ តម្រូវឱ្យធ្វើការទូទាត់ដោយប្រើប្រាស់តណទានឆ្នាំបន្ទាប់។ ចំណុចនេះដែរ ក្រសួងពាណិជ្ជកម្មនឹងខិតខំធ្វើវិចារណកម្មចំណាយ និងអនុវត្តផែនការសកម្មភាពឱ្យកាន់តែសុក្រឹតបន្ថែមទៀត។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងពាណិជ្ជកម្ម។ ដូច្នេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

### ៣.១.២៣.ការប្រមូលសក្ខីបត្រចំណាយយកមកទូទាត់ពុំបានត្រឹមត្រូវ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ៨២៩ សហវ.ប្រក ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន ត្រង់ប្រការ១៦ បានបញ្ជាក់ថា អនុញ្ញាតឱ្យរជ្ជទេយ្យករបុរេប្រទានយកវិក្កយបត្រ ឬសក្ខីបត្រចំណាយដែលបានចុះកាលបរិច្ឆេទរយៈពេលយ៉ាងយូរ៣០ថ្ងៃ មុនពេលមានសាច់ប្រាក់ក្នុងបេឡារជ្ជទេយ្យបុរេប្រទានមកធ្វើជាលិខិតយុត្តិការចំណាយ ដើម្បីបោះផ្សាយអាណត្តិនិយ័តកម្ម ប៉ុន្តែបណ្ណចំណាយត្រូវចុះកាលបរិច្ឆេទនៅក្រោយពេលបានបំពេញបេឡាសាច់ប្រាក់រជ្ជទេយ្យបុរេប្រទាន។ ក្នុងករណីវិក្កយបត្រ ឬសក្ខីបត្រចំណាយបានចុះកាលបរិច្ឆេទលើសពី៣០ថ្ងៃ មុនពេលមានសាច់ប្រាក់ក្នុងបេឡារជ្ជទេយ្យបុរេប្រទាន រជ្ជទេយ្យបុរេប្រទានត្រូវរាយការណ៍ជូនអាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិ ដើម្បីសុំគោលការណ៍ដោយឡែកពីអភិបាលហិរញ្ញវត្ថុ ឬគណនេយ្យករសាធារណៈ។

តាមការចុះធ្វើសវនកម្មនៅអគ្គយកដ្ឋានបច្ចេកទេសនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសម្រាប់ការិយបរិច្ឆេទ២០១៨ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានបច្ចេកទេសបានយកវិក្កយបត្រ ឬសក្ខីបត្រលើមុខទំនិញ ដូចជាជួសជុលម៉ាស៊ីនត្រជាក់ ទិញកន្សែងពោះគោ ច្រាសដុសធ្មេញ ស្បែកជើង ខ្មៅដៃដែលចុះកាលបរិច្ឆេទហួសរយៈពេល៣០ថ្ងៃ មកធ្វើជាលិខិតយុត្តិការចំណាយ ដើម្បីបោះផ្សាយអាណត្តិនិយ័តកម្មដែលមានទឹកប្រាក់មួយចំនួន ដោយពុំបានសុំគោលការណ៍ដោយឡែកពីអភិបាលហិរញ្ញវត្ថុ ឬគណនេយ្យករសាធារណៈឡើយ។

ដោយហេតុនេះ ដើម្បីប្រមូលវិក្កយបត្រ ឬសក្ខីបត្រចំណាយមកធ្វើលិខិតយុត្តិការចំណាយ ដើម្បីបោះផ្សាយអណត្តិនិយ័តកម្មឱ្យបានត្រឹមត្រូវ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរតែណែនាំដល់មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋានបច្ចេកទេសឱ្យធ្វើកែលំអឱ្យបានប្រសើរ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានឯកភាពតាមអនុសាសន៍សវនកម្ម ហើយបានបំភ្លឺថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងណែនាំ និងបណ្តុះបណ្តាលបន្ថែមទៀតដល់មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពថវិកានៃអគ្គនាយកដ្ឋានបច្ចេកទេសក្នុងឆ្នាំបន្ទាប់។ ដូច្នេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.២៤.ការបំបែកបណ្ណចំណាយដើម្បីគេចវេសនីតិវិធីលទ្ធកម្ម

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន ត្រង់ប្រការ១៦ បានបញ្ជាក់ថា រជ្ជទេយ្យបុរេប្រទានត្រូវជៀសវាងដាច់ខាតនូវការបំបែកបណ្ណចំណាយ ទៅតាមទីកន្លែង ឬគោលដៅចំណាយ ពេលវេលា និងទឹកប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយក្នុងគោលដៅគេចវេសការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និងប្រកាសលេខ១៨៦៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ២០១៤ ស្ដីពីការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម ត្រង់ប្រការ១ បានចែងថា ត្រូវកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវា នៅក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដូចក្នុងតារាងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ សម្រាប់ទឹកប្រាក់ក្រោម២០លានរៀល ត្រូវអនុវត្តវិធីសាស្ត្រស្ទង់តម្លៃ ទឹកប្រាក់ចាប់ពី ២០លានរៀលដល់ក្រោម១០០លានរៀល ត្រូវអនុវត្តវិធីសាស្ត្រពិគ្រោះថ្លៃ ចាប់ពី១០០លានរៀលដល់ក្រោម ៥ ០០០លានរៀល ត្រូវប្រើវិធីសាស្ត្រដេញថ្លៃក្នុងស្រុក និងចាប់ពី ៥ ០០០លានរៀលឡើង ត្រូវអនុវត្តវិធីសាស្ត្រដេញថ្លៃលក្ខណៈអន្តរជាតិ។

តាមការចុះធ្វើសវនកម្មនៅអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសម្រាប់ការិយបរិច្ឆេទ២០១៨ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានបច្ចេកទេសបានប្រើប្រាស់ថវិការជ្ជទេយ្យបុរេប្រទានកម្មវិធីមួយចំនួនចំណាយលើមុខទំនិញ ដូចជា ទិញសម្ភារបរិក្ខារបច្ចេកទេស កុំព្យូទ័រ និងព្រីនធ័រ ជូននាយកដ្ឋានសុខុមាលភាពមនុស្សចាស់ ពុំទាន់ត្រឹមត្រូវតាមនីតិវិធីនៃការចំណាយថវិការជ្ជទេយ្យបុរេប្រទាននោះទេ ដោយធ្វើការបំបែកបណ្ណ ចំណាយ ដើម្បីធ្វើការគេចវេសពីការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។

ដោយហេតុនេះ ដើម្បីឱ្យការចំណាយថវិការជ្ជទេយ្យបុរេប្រទានកម្មវិធីឱ្យបានត្រឹមត្រូវ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាគួរតែណែនាំដល់រជ្ជទេយ្យករបុរេប្រទានរបស់អគ្គនាយកដ្ឋានបច្ចេកទេសឱ្យធ្វើកែលំអឱ្យបានប្រសើរ ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានឯកភាពតាមអនុសាសន៍សវនកម្ម ហើយបានបំភ្លឺថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងពិនិត្យដោយប្រុងប្រយ័ត្ន និងណែនាំដល់អង្គភាពថវិកានៃអគ្គនាយកដ្ឋានបច្ចេកទេស កុំឱ្យកើតមាននៅក្នុងការិយបរិច្ឆេទលើកក្រោយ។

ផ្អែកតាមការបំភ្លឺរបស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាព។

### ៣.១.២៥.ការចំណាយមុនការស្នើសុំការឯកភាពពីប្រធានអង្គភាពថវិកា

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់ថ្នាក់ជាតិ ត្រង់

ប្រការ១៥ ជាគោលការណ៍ រដ្ឋទេយ្យបុរេប្រទានត្រូវចំណាយជាសាច់ប្រាក់ ដោយមានសក្ខីបត្របញ្ជាក់ត្រឹមត្រូវ។ មុននឹងធ្វើការចំណាយជាសាច់ប្រាក់ រដ្ឋទេយ្យករបុរេប្រទានត្រូវស្នើសុំគោលការណ៍ចំណាយទៅអាណាប័ក ឬអ្នកដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក។ ក្រោយពីទទួលបានគោលការណ៍ចំណាយ រដ្ឋទេយ្យបុរេប្រទានត្រូវអនុវត្តការទូទាត់ចំណាយ ដោយតម្រូវឱ្យអ្នកទទួលប្រាក់ចុះហត្ថលេខាបញ្ជាក់អំពីការបានទទួលប្រាក់គ្រប់ចំនួនលើសក្ខីបត្រ។

តាមការចុះធ្វើសវនកម្មនៅមូលនិធិជនពិការសម្រាប់ការិយបរិច្ឆេទ២០១៨ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋទេយ្យករបុរេប្រទានបានធ្វើការចំណាយមួយចំនួន មុនទទួលបានគោលការណ៍ចំណាយឯកភាពពីអង្គភាពថវិកា ដូចជា ចំណាយទិញសម្ភារប្រើប្រាស់ ទិញឧបករណ៍សិប្បនិម្មិត និងរណប ។

ដោយហេតុនេះ ដើម្បីឱ្យការចំណាយថវិការដ្ឋទេយ្យបុរេប្រទានស្របតាមនីតិវិធី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាគួរណែនាំដល់រដ្ឋទេយ្យកររបស់មូលនិធិជនពិការឱ្យកែលម្អឱ្យបានប្រសើរ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានឯកភាពតាមអនុសាសន៍សវនកម្ម ហើយបានបំភ្លឺថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងប្រាប់ទៅរដ្ឋទេយ្យករបុរេប្រទាននៃមូលនិធិជនពិការ (គ្រឹះស្ថានសាធារណៈរដ្ឋបាល) ត្រូវអនុវត្តតាមនីតិវិធីថវិកាកម្មវិធី។

ផ្អែកតាមការបំភ្លឺរបស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាព។

**៣.១.២៦.ការអនុវត្តកិច្ចលទ្ធកម្មមិនស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំ**

ប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំផែនការលទ្ធកម្ម ត្រង់ប្រការ១៦ បានចែងថា "គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម និងអង្គភាពថវិកា ត្រូវចាត់ចែងអនុវត្តកិច្ចលទ្ធកម្មឱ្យបានត្រឹមត្រូវ និងទៀងទាត់តាមផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានអនុម័តរួច"។ សារាចរណែនាំលេខ០០២ សហវ.អលក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុច៣ បានចែងថា "ស្ថាប័នអនុវត្តលទ្ធកម្មត្រូវប្រមូលផ្តុំគម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មទាំងឡាយដែលមិនបានកត់ត្រានៅក្នុងផែនការលទ្ធកម្មមិនអនុញ្ញាតឱ្យសុំ ឬផ្តល់ធានាចំណាយឡើយ" និងសារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ២០០៨ និងបន្តបន្ទាប់ ត្រង់ចំណុច II ចំណុចគ្រេទី៣ បានចែងថា "រាល់គម្រោងចំណាយដែលត្រូវអនុវត្តតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មត្រូវកត់ត្រាទាំងអស់តាមលំដាប់លំដោយបញ្ចូលក្នុងផែនការលទ្ធកម្ម។ ករណីមិនមានកត់ត្រាក្នុងផែនការលទ្ធកម្មមិនត្រូវបានអនុញ្ញាតឱ្យធ្វើលទ្ធកម្មឡើយ ហើយសាមីស្ថាប័នអនុវត្តលទ្ធកម្មត្រូវទទួលខុសត្រូវលើរាល់បាតុភាពអសកម្ម ដែលនឹងកើតឡើងដោយយថាហេតុ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០១៨ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះវិហារ បានលើកផែនការលទ្ធកម្មចំនួន០៥គម្រោង ក្នុងនោះមន្ទីរបានអនុវត្តតែ០២គម្រោងប៉ុណ្ណោះ។ បន្ថែមពីនេះ នៅក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៨ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានគម្រោងលទ្ធកម្មចំនួន២៥ និងរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំបានអនុវត្តគម្រោងចំនួន៣៣ ដែលនៅក្នុងនោះ មានគម្រោងចំនួន០៩ មិនមាននៅក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៨។

ឆ្លើយតបនឹងការសង្កេតខាងលើ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះវិហារ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ដោយឡែក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក៏បានបញ្ជាក់បន្ថែមថា ក្រសួងបានស្នើសុំផែនការលទ្ធកម្មកែតម្រូវនូវគម្រោងទាំងនោះដែលមានលក្ខណៈបន្ទាន់ និងចាំបាច់ ប៉ុន្តែមិនទាន់ពេលវេលា ដែលធ្វើឱ្យកិច្ចលទ្ធកម្មភាគច្រើនមិនមានក្នុងផែនការលទ្ធកម្ម ហើយប្រភពថវិកានោះបានមកពីការនិយ័តថវិការបស់អង្គភាពប្រើប្រាស់ ដើម្បីយកមកប្រើប្រាស់នៅចុងឆ្នាំ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

### ៣.១.២៧.ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ

សារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី៧ បានកំណត់ថា ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃត្រូវធ្វើឡើងជាចំហ និងដោយទូលំទូលាយ។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវប្រកាសផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃជាសាធារណៈតាមរយៈបញ្ជរព័ត៌មាន និងគេហទំព័ររបស់ខ្លួន និងសារព័ត៌មានដែលពលរដ្ឋទូទៅនិយមអាន។ ការផ្សព្វផ្សាយសារព័ត៌មានត្រូវធ្វើឡើងឱ្យបានយ៉ាងតិចចំនួន០២លើក។ តារាងផែនការលទ្ធកម្មកែតម្រូវចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ បានបញ្ជាក់ថា ការផ្សព្វផ្សាយសេចក្តីជូនដំណឹងដេញថ្លៃត្រូវធ្វើឡើងចំនួន០២លើក មានរយៈពេល៣០ថ្ងៃ។

តាមរយៈការត្រួតពិនិត្យឯកសារនៃការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃសម្រាប់ឆ្នាំ២០១៨ អាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញថាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃចំនួន៩គម្រោងតាមរយៈសារព័ត៌មាន ដែលប្រព្រឹត្តទៅតែមួយលើកគត់ ហើយក្នុងនោះមាន៣គម្រោង ដែលការផ្សព្វផ្សាយមានរយៈពេលតិចជាង៣០ថ្ងៃ ដោយសាររយៈពេលនៃដំណើរការកិច្ចលទ្ធកម្មខិតជិតចុងឆ្នាំ ដែលកត្តានេះអាចនាំឱ្យការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃពុំបានទូលំទូលាយ និងផ្តល់ពេលវេលាគ្រប់គ្រាន់ដល់អ្នកដែលមានបំណងចូលរួមដេញថ្លៃ។

ដូចនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិគួរពង្រឹងយន្តការនៃការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃដោយមានលក្ខណៈកាន់តែទូលាយ ដើម្បីឱ្យដំណើរការនៃការអនុវត្តកិច្ចលទ្ធកម្មបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានបញ្ជាក់ថា ក្រសួងកំពុងពង្រឹងការអនុវត្តក្នុងចំណុចនេះឱ្យបានត្រឹមត្រូវ និងទូលំទូលាយ តាមសារាចរណែនាំលេខ ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

**៣.១.២៨.ភាពយឺតយ៉ាវក្នុងការរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយប្រចាំឆ្នាំ**

សារាចរណែនាំលេខ០០៩ សហវ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបិទបញ្ជីចំណូលចំណាយថវិកា និងការបូកសរុបអនុវត្តចំណូលចំណាយថ្នាក់ជាតិ ត្រូវរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណូលចំណាយថវិកា ឱ្យបានមុនថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ ជាកំហិត។

អាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល យឺតយ៉ាវក្នុងការរៀបចំរបាយការណ៍សម្រេចទូទាត់ថវិកាសម្រាប់ឆ្នាំ២០១៨។

ឆ្លើយតបនឹងចំណុចនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងបានបញ្ជាក់ថា ភាពយឺតយ៉ាវក្នុងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូលចំណាយថវិកា គឺដោយសារត្រូវរង់ចាំប្រមូលទិន្នន័យតួលេខពីបណ្តាមន្ទីរទាំង២៥រាជធានី-ខេត្ត និងការផ្ទៀងផ្ទាត់តួលេខជាមួយអគ្គនាយកដ្ឋានរតនាគារជាតិពុំសូវត្រូវគ្នា ហើយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក៏បានបញ្ជាក់បន្ថែមទៀតថា៖

១.លម្អៀងតួលេខសរុបក្នុងអាណត្តិ និងតួលេខក្នុងប្រព័ន្ធដែលត្រូវការផ្ទៀងផ្ទាត់យូរ

២.មានអាណត្តិមួយចំនួនកកស្ទះនៅរតនាគារដល់ខែមីនា ឆ្នាំ២០១៩

៣.រតនាគារមានបញ្ចូលអាណត្តិរបស់អង្គការARMACដែលក្រសួងមិនបានចំណាយ

៤.ប្រើពេលយូរក្នុងការផ្ទូផ្ទងតួលេខរបស់ក្រសួងជាមួយរតនាគារជាតិ និងអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិ នឹងធ្វើការតាមដានការអនុវត្តអនុសាសន៍នេះជាបន្តទៀត។

**៣.១.២៩.វិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលសាងសង់មិនសមស្របនឹងទំហំទឹកប្រាក់ចុះកិច្ចសន្យា**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសេចក្តីណែនាំស្តីពីនីតិវិធីនៃការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់ ត្រង់ចំណុចទី៧ សិទ្ធិចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា អ្នកទទួលការសាងសង់ដែលបានចុះបញ្ជីរួចហើយ អាចមាន

សិទ្ធិចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈតាមតម្លៃគម្រោង ដូចជា៖១. ប្រភេទតូច តម្លៃគម្រោងតិចជាង៥០០លានរៀល ២. ប្រភេទមធ្យមតម្លៃគម្រោង មិនលើសពី៣ ០០០លានរៀល និង៣.ប្រភេទធំតម្លៃគម្រោងមិនកំណត់។

តាមការធ្វើសវនកម្មនៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ (នាយកដ្ឋានលទ្ធកម្មសំណង់ និងសេវា និងនាយកដ្ឋានរដ្ឋបាលថ្នាក់ក្រោមជាតិ) អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ក្រុមហ៊ុនដែលបានចូលរួមដេញថ្លៃប្រកួតប្រជែង និងចរចាថ្លៃលើគម្រោងសាងសង់របស់ក្រសួង ស្ថាប័ន និងរាជធានីខេត្តមួយចំនួន មានប្រភេទវិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលការសាងសង់ប្រភេទតូច និងមធ្យម ប៉ុន្តែបានអនុវត្តកិច្ចសន្យាការងារដែលមានទំហំទឹកប្រាក់លើសពីកម្រិតវិញ្ញាបនបត្រដែលបានចុះបញ្ជីចំណាត់ថ្នាក់ប្រភេទអ្នកទទួលការនោះ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបានបំភ្លឺបន្ថែមថា ក្នុងគោលបំណងកំណត់សមត្ថភាពអនុវត្តការងារ និងលក្ខណៈសម្បត្តិរបស់អ្នកទទួលការសាងសង់ និងលក្ខណៈវិនិច្ឆ័យ និងនីតិវិធីវាយតម្លៃលក្ខណៈសម្បត្តិរបស់អ្នកទទួលការសាងសង់សម្រាប់ការចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំ និងដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំលេខ០១៣ សហវ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីនីតិវិធីនៃការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នាពេលកន្លងមកបានរៀបចំប្រជុំផ្សព្វផ្សាយសេចក្តីណែនាំលេខ០១៣ សហវ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីនីតិវិធីនៃការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់ ជូនដល់ស្ថាប័នអនុវត្តលទ្ធកម្ម អង្គភាពថវិកា ក្រុមហ៊ុន និងសហគ្រាសដែលពាក់ព័ន្ធចាប់ពីថ្ងៃទី១១-១៣ ខែមិថុនា ឆ្នាំ២០១៨ និងថ្ងៃទី២៧-២៨ ខែកញ្ញា ឆ្នាំ២០១៨។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានមើលនូវវឌ្ឍនភាពបន្តទៀត។

**៣.១.៣០.ប៉ាតង់របស់ក្រុមហ៊ុនចូលរួមដេញថ្លៃពុំទាន់ស្របនឹងមុខរបរទំនិញដែលត្រូវដេញថ្លៃ**

លិខិតជូនដំណឹងលេខ៦១៣៤ សហវ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការអនុវត្តវិធីកាត់ទុកពន្ធដោយរតនាគារជាតិលើកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុច២ បានកំណត់ថា " សេចក្តីណែនាំចំពោះអ្នកដេញថ្លៃត្រូវបំពេញបន្ថែមចំណុចមួយទៀត បណ្ណប៉ាតង់ក្នុងឆ្នាំដេញថ្លៃ ត្រូវមានមុខរបរឱ្យស្របគ្នានឹងមុខរបរដែលត្រូវចូលរួមដេញថ្លៃ"។

តាមការពិនិត្យសំណុំឯកសារលទ្ធកម្មនៃការផលិតផលផ្ទាំងរូបភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងការផ្គត់ផ្គង់សម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនចូលរួមដេញថ្លៃ ដែលមានផលរបរមិនស្របទៅនឹងផលរបរនៃការងារលទ្ធកម្ម។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនគួរណែនាំដល់ក្រុមហ៊ុនចូលរួមដេញថ្លៃឱ្យរៀបចំលក្ខណសម្បត្តិគ្រប់គ្រាន់ ពិសេសបណ្ណប៉ាតង់ឱ្យស្របនឹងទំនិញដែលត្រូវធ្វើការដេញថ្លៃ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងសាធារណការ និងដឹកជញ្ជូនបានបំភ្លឺដូចខាងក្រោមៈ

ក. សម្រាប់ "ការផ្គត់ផ្គង់សម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យាសម្រាប់ប្រើប្រាស់ក្នុងទីស្ដីការក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងឆ្នាំ២០១៨" ការងារនេះ បណ្ណប៉ាតង់ឆ្នាំ២០១៨ជាប្រភេទ (សម្ភារការិយាល័យ) ព្រមទាំងភ្ជាប់មកជាមួយលិខិតអនុញ្ញាតចេញដោយមន្ទីរព័ត៌មានរាជធានីជាប្រភេទបន្តធ្វើអាជីវកម្ម "ទិញលក់សម្ភារបរិក្ខារអេឡិចត្រូនិច និងសេវាបោះពុម្ព"។ សម្រាប់ការងារ "ការបោះពុម្ពឯកសារពាក់ព័ន្ធការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោករបស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូនប្រចាំឆ្នាំ២០១៨" ការងារនេះ បណ្ណប៉ាតង់ឆ្នាំ២០១៨ជាប្រភេទ (សេវាបោះពុម្ព) ព្រមទាំងភ្ជាប់មកជាមួយលិខិតអនុញ្ញាតចេញដោយមន្ទីរព័ត៌មានរាជធានី ជាប្រភេទបន្តធ្វើអាជីវកម្ម "សេវាបោះពុម្ពគ្រប់ប្រភេទ" ។

ខ. ពិនិត្យទៅលើសំណុំឯកសារលទ្ធកម្មមានការងារ "ការផ្គត់ផ្គង់សម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា សម្រាប់ប្រើប្រាស់ក្នុងទីស្ដីការក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងឆ្នាំ២០១៨" និងការងារ "ការបោះពុម្ពឯកសារពាក់ព័ន្ធការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោករបស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកនៃក្រសួងសាធារណការ និងដឹកជញ្ជូនប្រចាំឆ្នាំ២០១៨" ដែលអាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានក្រុមហ៊ុនចូលរួមដេញថ្លៃមានផលរបរមិនស្របទៅនឹងផលរបរនៃការងារលទ្ធកម្មនោះ ក្រសួងសូមបញ្ជាក់ថា សម្រាប់ការងារទាំងពីរគឺធ្វើឡើងតាមការដាក់តម្លៃប្រកួតប្រជែងជាសាធារណៈរបស់ក្រុមហ៊ុនដែលបានចូលរួម ហើយគណៈកម្មាធិការលទ្ធកម្មបានពិនិត្យទៅលើលក្ខណសម្បត្តិ ព្រមទាំងផ្ទៀងផ្ទាត់ទៅលើឯកសារភស្តុតាងនានារបស់ក្រុមហ៊ុន ដើម្បីធានាភាពត្រឹមត្រូវនៃតម្រូវការតាមផ្លូវច្បាប់ ព្រមទាំងពិនិត្យទៅលើ "ហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍" ដើម្បីឱ្យសមស្របតាមប្រកាសលេខ ៣២៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្តង់តម្លៃសម្រាប់លទ្ធកម្មទំនិញ និងសំណង់ផងដែរ ដោយផ្អែកទៅលើមូលដ្ឋានទាំងអស់នេះ ទើបគណៈកម្មាធិការលទ្ធកម្មក្រសួងសាធារណការ និងដឹកជញ្ជូន បានឯកភាពសម្រេចប្រគល់កិច្ចសន្យា ព្រមទាំងបានធ្វើការស្នើសុំការពិនិត្យ និងសម្រេចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ ។

គ. ជាក់ស្ដែងពិនិត្យទៅលើការសន្និដ្ឋានរបស់អាជ្ញាធរសវនកម្មជាតិ ទៅលើចំណុចដែលថា កិច្ចលទ្ធកម្មមិនទាន់មានលក្ខណៈសមស្របតាមគោលការណ៍លទ្ធកម្មសាធារណៈ និងទំនិញដែលក្រុមហ៊ុនបានផ្គត់ផ្គង់អាចមានតម្លៃខ្ពស់ ក្រសួងបានបញ្ជាក់ថា រាល់ការពិនិត្យ និងអនុម័តទៅលើក្រុមហ៊ុនដែលបានដាក់ដេញថ្លៃ គណៈកម្មាធិការលទ្ធកម្មបានពិនិត្យទៅលើលក្ខណសម្បត្តិ ព្រមទាំងតម្លៃដែលក្រុមហ៊ុនបានដាក់ដេញថ្លៃ និង

ឃើញថា តម្លៃដែលបានដាក់នៅទាបជាងការផ្តល់ធានាចំណាយដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានពិនិត្យ និងឯកភាពផងដែរ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.៣១.ភាពយឺតយ៉ាវក្នុងការទាមទារស្តុកមកវិញ**

អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុនហ្គ្រីនត្រេដ ជំពូក២ ការដឹកនាំ និងគ្រប់គ្រង ត្រង់មាត្រា១៣ ចំណុច៤ បានចែងថា "តំណាងឱ្យក្រុមហ៊ុនហ្គ្រីនត្រេដ ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល រដ្ឋបាល ឬលិខិតតុលាការក្នុងក្របខណ្ឌច្បាប់ និងការសម្រេចរបស់ក្រុមប្រឹក្សាភិបាល"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ ក្រុមហ៊ុនហ្គ្រីនត្រេដ នៅពុំទាន់បានពន្លឿនក្នុងការទាមទារស្តុកអង្ករមួយចំនួនដែលបានផ្ញើនៅរោងម៉ាស៊ីនមួយចំនួន។

អាស្រ័យហេតុនេះ ដើម្បីការគ្រប់គ្រងស្តុកឱ្យមានប្រសិទ្ធភាព ក្រុមហ៊ុនហ្គ្រីនត្រេដគួរមានយន្តការក្នុងការទាមទារស្តុកអង្ករត្រឡប់មកវិញឱ្យបានឆាប់រហ័ស។

ឆ្លើយតបនឹងការលើកឡើងនេះ ក្រុមហ៊ុនហ្គ្រីនត្រេដកំពុងអនុវត្តតាមនីតិវិធីតុលាការ ហើយបានសងដល់ខែកក្កដា ឆ្នាំ២០១៩ នៅសល់មួយចំនួនកំពុងដាក់ពាក្យបណ្តឹងនៅតុលាការ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រុមហ៊ុនហ្គ្រីនត្រេដ។ ដូច្នេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

**៣.១.៣២.ភាពយឺតយ៉ាវក្នុងការបូកសរុបចំណាយថវិកាកម្មវិធីទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព**

ប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ត្រង់ចំណុច១ វាក្យខណ្ឌ២ បានកំណត់ថា " ក្រសួង ស្ថាប័ន និងមន្ទីរជំនាញ រាជធានី ខេត្ត តម្រូវឱ្យធ្វើរបាយការណ៍គំរូរួម និងតាមទម្រង់នៃប្រភេទរបាយការណ៍នីមួយៗ ដូចមានភ្ជាប់នៅក្នុងតារាងឧបសម្ព័ន្ធទី១៦ ដល់ទី២៣។ របាយការណ៍ហិរញ្ញវត្ថុទាំងអស់ត្រូវរៀបចំ និងផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការិយបរិច្ឆេទ (នាយកដ្ឋានថវិកានៃអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ) ដូចខាងក្រោម៖ របាយការណ៍ចំណាយប្រចាំឆ្នាំនៃការអនុវត្តថវិកាកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពទៅតាមជំពូកចំណាយត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែមករានៃឆ្នាំបន្ទាប់ "។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់មានភាពយឺតយ៉ាវក្នុងការបញ្ចប់ការរៀបចំបូកសរុបចំណាយថវិកាកម្មវិធីរបស់ខ្លួន

ទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពប្រចាំឆ្នាំនៃគម្រោងចំណាយថវិកាកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព និងគោលការណ៍ណែនាំស្តីពីនីតិវិធីនៃការអនុវត្តថវិកាកម្មវិធីនៅឡើយ។

ឆ្លើយតបនឹងការសង្កេតនេះ រដ្ឋលេខាធិការដ្ឋានអាកាសស៊ីវិលបានឯកភាពទៅនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ដោយឡែក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានបញ្ជាក់បន្ថែមថា មន្ត្រីអនុវត្តថវិកាកម្មវិធីរបស់ក្រសួង គឺនៅមានកម្រិត ចំណែកក្រសួងពាណិជ្ជកម្មក៏បានបង្ហាញថា ក្រសួងមានភាពយឺតយ៉ាវក្នុងការផ្ទៀងផ្ទាត់តួលេខជាមួយរតនាគារជាតិ និងក្រសួងសាធារណការ និងដឹកជញ្ជូន គឺមិនទាន់បានទទួលគំរូណែនាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឡើយ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺខាងលើ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យវឌ្ឍនភាពជាបន្តទៀត។

**៣.១.៣៣.ការអនុវត្តប្រកាសអន្តរក្រសួងលេខ២៦១ ស.អ.យ មិនទាន់បានពេញលេញ**

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា ត្រង់មាត្រា១ បានចែងថា អង្គភាពថវិកាគឺជាអង្គភាពដែលត្រូវបានទទួលស្គាល់អាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពការងារ ដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ និងអាចវាស់វែងបាន និងរួមចំណែកក្នុងការសម្រេចគោលបំណង គោលនយោបាយអាទិភាពរបស់ក្រសួងស្ថាប័ន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានចេញប្រកាសអន្តរក្រសួងលេខ២៦១ស.អ.យ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកាចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ត្រង់ប្រការ១ ទទួលស្គាល់ និងដាក់ឱ្យអនុវត្តអង្គភាពថវិកាចំនួន៣០ ដូចខាងក្រោម៖

១.អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ

២.អគ្គនាយកដ្ឋានបច្ចេកទេស

៣.បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

៤.បេឡាជាតិអតីតយុទ្ធជន

៥.មូលនិធិជនពិការ

៦.មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្តទាំង២៥

តាមការចុះធ្វើសវនកម្មនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសម្រាប់ការិយបរិច្ឆេទ២០១៨ អាជ្ញាធរសវនកម្មជាតិឃើញថា អគ្គនាយកដ្ឋានបច្ចេកទេសនៅមិនទាន់មានអាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពការងាររបស់ខ្លួននៅឡើយ។

ដោយហេតុនេះ ដើម្បីឱ្យអគ្គនាយកដ្ឋានបច្ចេកទេសក្លាយជាអង្គភាពថវិកាពេញលេញ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាគួរតែអនុវត្តស្របតាមប្រកាសរួមខាងលើ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានឯកភាពតាមអនុសាសន៍សវនកម្ម ហើយបានបំភ្លឺថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងខិតខំបន្តបណ្តុះបណ្តាលដល់មន្ត្រីក្រុមការងារហិរញ្ញវត្ថុរបស់អង្គភាពថវិកា នឹងឈានទៅអនុវត្តសកម្មភាពពេញលេញរបស់ខ្លួននាឆ្នាំខាងមុខ។

ផ្អែកតាមការបំភ្លឺរបស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាព។

**៣.១.៣៤.ការពុំទាន់បង្កើតអង្គភាពសវនកម្មផ្ទៃក្នុង**

ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រង់ជំពូកទី៥ ការត្រួតពិនិត្យ និងសវនកម្ម មាត្រា៤៦ បានចែងថា "គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានអង្គភាពសវនកម្មផ្ទៃក្នុង ដែលត្រូវបង្កើត តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ច ដោយអាណាព្យាបាលបច្ចេកទេសតាមសំណើរបស់ក្រុមប្រឹក្សាភិបាល" និងអនុក្រឹត្យលេខ៤០ អនក្រ.បង ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈ ត្រង់មាត្រា២ វាក្យខណ្ឌ៣ និងមាត្រា៣ បានចែងថា "ថ្នាក់ដឹកនាំស្ថាប័នក្រសួង និងសហគ្រាសសាធារណៈត្រូវទទួលខុសត្រូវលើការបង្កើត និងរក្សាឱ្យមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ តួនាទីសវនកម្មផ្ទៃក្នុងគឺត្រូវវាយតម្លៃដោយឯករាជ្យនូវភាពសមស្របគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងទាំងនោះ និងផ្តល់នូវការធានាលើភាពគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលកំពុងមាន និងកំពុងដំណើរការទៅតាមគោលបំណង"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា បេឡាជាតិអតីតយុទ្ធជន និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មិនទាន់បានបង្កើតនូវអង្គភាពសវនកម្មផ្ទៃក្នុងនៅឡើយទេ។

ឆ្លើយតបនឹងការសង្កេតខាងលើ បេឡាជាតិអតីតយុទ្ធជន និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានទទួលយកនូវអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងកំពុងរៀបចំស្នើសុំគោលការណ៍ដើម្បីបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មសង្ឃឹមថា គ្រប់អង្គភាពទាំងអស់ នឹងធ្វើការបង្កើតនូវអង្គភាពសវនកម្មផ្ទៃក្នុង ដើម្បីពិនិត្យតាមដាន វាយតម្លៃ និងបង្កើនប្រសិទ្ធភាពកិច្ចប្រតិបត្តិការការងាររបស់ខ្លួន។

**៣.១.៣៥.អង្គភាពអនុវត្តគម្រោងពុំមានឧបករណ៍បំពេញការងារ**

អនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ ត្រង់មាត្រា៦ ចំណុចទី២ បានចែងថា "ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបានប្រើប្រាស់សម្រាប់ស្ថាប័នអនុវត្តលទ្ធកម្មណាដែលមានស្រាប់នូវបច្ចេកទេស ជំនាញ កម្លាំងពលកម្ម និងឧបករណ៍សម្រាប់បំពេញការងារក្នុងគម្រោងនោះ" និងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៧ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨ របស់នាយកដ្ឋានផ្លូវលំជនបទ។

តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានផ្លូវលំជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ ជាអ្នកទទួលការលើការងារស្ថាបនាផ្លូវ ស្ពាន និងលូ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ជាអ្នកទទួលការលើការថែទាំខួប ការថែទាំប្រចាំ និងការជួសជុលបន្ទាន់។ ប៉ុន្តែតាមការពិនិត្យបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់នាយកដ្ឋានផ្លូវលំជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តព្រៃវែង អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានផ្លូវលំជនបទពុំឃើញមានគ្រឿងចក្រគ្រប់គ្រាន់សម្រាប់អនុវត្តការងារស្ថាបនាផ្លូវ ស្ពាន និងលូ។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តខ្លះមានគ្រឿងចក្រតិចតួចបំផុត (ខូចអស់ហើយ) និងខេត្តខ្លះពុំឃើញមានគ្រឿងចក្រគ្រប់គ្រាន់សម្រាប់ការថែទាំខួប ការថែទាំប្រចាំ និងការជួសជុលបន្ទាន់ទេ។ ចំពោះការអនុវត្តលើស្ថាបនាផ្លូវ ស្ពាន និងលូរបស់នាយកដ្ឋានផ្លូវលំជនបទ និងការថែទាំខួប ការថែទាំប្រចាំ និងការជួសជុលបន្ទាន់របស់មន្ទីរអភិវឌ្ឍន៍ជនបទពុំបានបញ្ជាក់ពីការជួល ឬបានគ្រឿងចក្រពីប្រភពណាមួយច្បាស់លាស់នោះទេ)។

អាស្រ័យដោយ អង្គភាពអនុវត្តគម្រោងពុំមានគ្រឿងចក្រគ្រប់គ្រាន់សម្រាប់អនុវត្តការងារស្ថាបនាផ្លូវ ស្ពាន និងលូ ដូចនេះហើយ នឹងនាំឱ្យការអនុវត្តតាមអនុក្រឹត្យខាងលើពុំមានប្រសិទ្ធភាព។

ក្រសួងអភិវឌ្ឍន៍ជនបទ គួរចុះកិច្ចសន្យាលើការងារសាងសង់ ស្ថាបនាផ្លូវ ស្ពាន លូ និងការថែទាំផ្លូវ ឱ្យស្របតាមអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ ត្រង់មាត្រា៦ ចំណុចទី២ខាងលើ។

ក្រសួងអភិវឌ្ឍន៍ជនបទ បានឯកភាពលើការអង្កេត និងអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ប៉ុន្តែបានធ្វើការបំភ្លឺថា ករណីនេះ អង្គភាពអនុវត្តគម្រោងបានអនុវត្តនីតិវិធីលទ្ធកម្មដោយឡែក ជាមួយក្រសួងអភិវឌ្ឍន៍ជនបទលើការជួសជុល សាងសង់ និងថែទាំផ្លូវក្រាលក្រួសក្រហម ប៉ុន្តែទោះជាយ៉ាងណាក្តី ក្រសួងអភិវឌ្ឍន៍ជនបទបានទទួលស្គាល់ថាចំណុចនេះ មិនស្របតាមនីតិវិធីលទ្ធកម្មសាធារណៈនៅឡើយ ដូចច្នេះ ក្រសួងអភិវឌ្ឍន៍ជនបទនឹងខិតខំបន្ថែមទៀត ដើម្បីធ្វើការកែលម្អចំណុចខ្វះខាតនេះឡើងវិញ។

អាជ្ញាធរសវនកម្មជាតិបានឃើញការបំភ្លឺរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ ដូចនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តតាមអនុសាសន៍ជាបន្តទៀត។

### ៣.១.៣៦.ការមិនបានបែងចែក និងវិភាជឥណទានថវិកាទៅឱ្យអង្គភាពថវិកា

ប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ត្រង់ចំណុច III.២ កថាខណ្ឌទី២ បានចែងថា "ដើម្បីឱ្យអង្គភាពថវិកាទទួលខុសត្រូវលើការអនុវត្តថវិកា និងការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពពិសេស ដើម្បីបង្កើនគណនេយ្យភាពចំណាយឱ្យកាន់តែប្រសើរ រដ្ឋមន្ត្រីប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលដែលជាអាណាប័ក

ដើមខ្សែ តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុត្រូវវិភាជថវិកាឱ្យអង្គភាពថវិកាក្រោមឱវាទឱ្យបានទាន់ពេលវេលាស្របតាមការិយបរិច្ឆេទនៃឆ្នាំសារពើពន្ធនៃការអនុវត្តថវិកា"។

ប្រកាសអន្តរក្រសួងលេខ៥៨៨ ប្រក.សក.ហវ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិការវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង សាធារណការ និងដឹកជញ្ជូន ត្រង់ប្រការ១ បានចែងថា "ទទួលស្គាល់ និងដាក់ឱ្យអនុវត្តអង្គភាពថវិកាចំនួន ៣៣ ដូចជាៈ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានសាធារណការ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ...និងមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្តចំនួន២៥" និងប្រការ៣ បានចែងថា "ប្រកាសនេះមានប្រសិទ្ធភាពសម្រាប់ការអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ"។

តាមការពិនិត្យរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំឆ្នាំ២០១៨ និងប្រកាសអន្តរក្រសួងស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកាចាប់ពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៨ ក្រសួងសាធារណការ និងដឹកជញ្ជូនពុំទាន់បានបែងចែក ឬវិភាជថវិកាទៅឱ្យអង្គភាពថវិកា ដើម្បីទទួលខុសត្រូវលើការអនុវត្តថវិកាកម្មវិធី ហើយរាល់ប្រតិបត្តិការនៃការចំណាយថវិកាកម្មវិធីបានអនុវត្តតែនៅក្នុងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ) ប៉ុណ្ណោះ។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនគួរធ្វើការបែងចែង និងវិភាជឥណទានថវិកាទៅឱ្យអង្គភាពថវិការបស់ខ្លួន។

ឆ្លើយតបនឹងចំណុចខាងលើ ក្រសួងសាធារណការ និងដឹកជញ្ជូនបានបំភ្លឺថា ក្នុងឆ្នាំ២០១៨ ក្រសួងបានវិភាជថវិកាទៅឱ្យអង្គភាពថវិកានូវខ្ទង់ចំណាយប្រេងឥន្ធនៈ សម្ភារការិយាល័យ ការបោះពុម្ព និងបេសកកម្មក្នុងប្រទេស។ ចំពោះការវិភាជន៍លើមុខចំណាយផ្សេងៗទៀតគឺត្រូវមានការសម្រេចពីថ្នាក់ដឹកនាំក្រសួងសាធារណការ និងដឹកជញ្ជូន។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.៣៧.កង្វះខាតក្នុងការដាក់បញ្ចូលសម្ភារការិយាល័យក្នុងផែនការលទ្ធកម្ម

ជាទូទៅ ការធ្វើលទ្ធកម្មសាធារណៈ គេតែងតែអនុវត្តវិធីសាស្រ្តលទ្ធកម្មដោយចរចាថ្លៃ ពិគ្រោះថ្លៃ ដេញថ្លៃក្នុងស្រុក និងដេញថ្លៃជាលក្ខណៈអន្តរជាតិ ផ្អែកទៅតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ទន្ទឹមនឹងនេះ ត្រូវប្រមូលផ្តុំសម្ភារបរិក្ខារ ឬសម្ភារដែលដូចៗគ្នាដាក់ចូលទៅក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ។ តាមសារាចរលេខ០០៧ សហវ អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី៤ បានតម្រូវឱ្យស្ថាប័នអនុវត្តលទ្ធកម្មត្រូវប្រមូលផ្តុំគម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មទាំងអស់កត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្ម។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៨ អាជ្ញាធរអគ្គិសនីកម្ពុជាចំណាយទិញសម្ភារការិយាល័យមួយចំនួន ដោយពុំទាន់បានដាក់បញ្ចូលក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៨។ អាជ្ញាធរអគ្គិសនីកម្ពុជាគួរតែអនុវត្តឱ្យបានសមស្របតាមសារាចរខាងលើ។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ អាជ្ញាធរអគ្គិសនីកម្ពុជា ទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ក្នុងការដាក់បញ្ចូលសម្ភារការិយាល័យក្នុងផែនការលទ្ធកម្ម។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.៣៨.ភាពយឺតយ៉ាវក្នុងការទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត**

សារាចរណែនាំលេខ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើទឹកចិត្តលើការផ្តល់សេវាសាធារណៈ ត្រង់ផ្នែកទី១ ចំណុចទី៥ បានចែងថា "ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្ត ត្រូវធ្វើការទូទាត់ប្រចាំខែ (ម្តងក្នុងមួយខែ ឬត្រីមាសម្តង) លើកលែងតែក្នុងខែនោះមិនមានការប្រមូលចំណូល" និងត្រង់ផ្នែកទី២ ចំណុចទី៧.៥ បានចែងថា "ជារៀងរាល់ខែ រដ្ឋទេយ្យករចំណូលនៃរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្តនៃក្រសួងស្ថាប័ននីមួយៗត្រូវធ្វើការបូកសរុបចំនួនទឹកប្រាក់បុរេប្រទាន ដោយគិតត្រឹមថ្ងៃទី២៥ នៃខែនីមួយៗ និងគិតត្រឹមថ្ងៃទី៣១ចំពោះខែធ្នូ តាមរយៈការប្រើប្រាស់តារាងស្តីពីការគណនាប្រាក់រង្វាន់ ដែលចំនួនទឹកប្រាក់សរុបនេះត្រូវប្រើជាមូលដ្ឋានសម្រាប់ការចុះនៅសលាកប័ត្រចំណូលថវិកាជាតិ និងចុះក្នុងអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម)ផង" និងចំណុចទី៨ បានចែងថា ករណីដែលក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តណាមួយ មិនយកចិត្តទុកដាក់ក្នុងការអនុវត្តនីតិវិធីទូទាត់ប្រាក់បុរេប្រទានលើប្រាក់រង្វាន់លើកទឹកចិត្តឱ្យបានទាន់ពេលវេលា ឬមិនបានរៀបចំសំណុំឯកសារដើម្បីធ្វើការទូទាត់ទេនោះនឹងត្រូវប្រឈមមុខទៅនឹងការពិន័យរដ្ឋបាលពីប្រមុខរាជរដ្ឋាភិបាលជាយថាហេតុ។

តាមការពិនិត្យ និងធ្វើតេស្តលើរបាយការណ៍ចំណាយប្រាក់រង្វាន់លើកទឹកចិត្តពីកម្រៃសេវាអាកាសចរស៊ីវិល និងអាណត្តិទូទាត់ប្រាក់រង្វាន់លើកទឹកចិត្តឆ្នាំ២០១៨ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានធ្វើការទូទាត់ប្រាក់រង្វាន់លើកទឹកចិត្តមួយចំនួនដោយមានភាពយឺតយ៉ាវ។

អាស្រ័យហេតុនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលគួរធ្វើការទូទាត់ចំណាយប្រាក់រង្វាន់លើកទឹកចិត្តឱ្យបានទាន់ពេលវេលា និងការិយបរិច្ឆេទនៃឆ្នាំថវិកា និងស្របតាមខ្លឹមសារនៃសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងចំណុចនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានឯកភាពទៅនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ។ ប៉ុន្តែ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានបញ្ជាក់ថា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានអនុវត្តទៅតាមនីតិវិធីទូទាត់ប្រាក់រង្វាន់ដែលមានចែងក្នុងសារាចរណែនាំលេខ០០១ សហវ.ចពម ចុះថ្ងៃទី២៦ ខែកុម្ភៈឆ្នាំ២០១៣ ស្តីពីគោលការណ៍និងនីតិវិធីផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត។ ដោយឡែក ទឹកប្រាក់មួយចំនួន

គឺជាប្រាក់រង្វាន់ដែលទទួលបានពីការប្រមូលចំណូលពីក្រុមហ៊ុនអាកាសចរណ៍ផ្សេងៗធ្វើការទូទាត់នូវកម្រៃសិទ្ធិហោះហើរតែម្ខាង (Royalty fees) និងកម្រៃសេវារដ្ឋបាល និងសេវាផ្សេងៗពីក្រៅប្រទេសចូលមកគណនីរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនៅធនាគារជាតិនៃកម្ពុជា នៅចន្លោះពីថ្ងៃទី២៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ហើយនៅក្នុងអំឡុងពេលនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលទទួលបានប្រកាសឥណទានពីធនាគារជាតិនៃកម្ពុជាមានការយឺតយ៉ាវគឺនៅចុងខែតែម្តង ដូច្នេះហើយការទូទាត់ប្រាក់រង្វាន់មិនអាចធ្វើនីតិវិធីទូទាត់ក្នុងឆ្នាំបានទេ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.៣៩.ភាពយឺតយ៉ាវក្នុងការទារបំណុលពីកម្រៃសេវាចេញលិខិតអនុញ្ញាតសាងសង់បង់ចូលថវិកាជាតិ

ដើម្បីពង្រឹងការគ្រប់គ្រងបំណុលសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញនូវប្រកាសរួមលេខ៦៤៥ សហវ.ប្រក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រង់ប្រការ៩ វាក្យខណ្ឌ២ បានចែងថា "នៅពេលអនុវត្តចំណូល រដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលដែលប្រមូលបានបង់ប្រាក់ចំណូល និងធ្វើសលាកបត្រចំណូលថវិកាជាតិ ព្រមទាំងចុះបញ្ជីកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានចំណូលនៅក្នុងជំពូកគណនី អនុគណនីនៃមាតិកាចំណូលថវិកា"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅមានភាពយឺតយ៉ាវក្នុងការទារបំណុលមួយចំនួនពីកម្រៃសេវាចេញលិខិតអនុញ្ញាតសាងសង់ គិតចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨។

អាស្រ័យហេតុនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់គួរធ្វើការទារបំណុលពីកម្រៃសេវាសាធារណៈពីការចេញលិខិតអនុញ្ញាតសាងសង់បង់ចូលថវិកាជាតិឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

ឆ្លើយតបនឹងករណីនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានធ្វើការបញ្ជាក់ថា យោងតាមប្រកាសលេខ០៧៥ ប្រក.បក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការបែងចែកភារកិច្ចលើការប្រមូល ការគ្រប់គ្រង និងការបែងចែកចំណូលពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រង់ប្រការ៦ ចែងថា "ការបង់ប្រាក់កម្រៃសេវាសាធារណៈដោយអ្នកប្រើប្រាស់សេវាត្រូវធ្វើនៅពេលដែលសំណើសុំសេវាត្រូវបានផ្តល់ជូន" សេវាត្រូវបានផ្តល់ជូនម្ចាស់សំណើមួយចំនួនមិនបានមកបង់សេវា បើទោះជាក្រសួងបានធ្វើលិខិតជាស់តឿនចំនួន៣ដងរួចហើយក្តី ដោយម្ចាស់សំណើមានហេតុផល ដូចខាងក្រោម៖

-ពុំមានថវិកាគ្រប់គ្រាន់សម្រាប់ការបង់សេវា(ស្នើសុំពន្យារពេល១ឆ្នាំ)

-បានលក់ទីតាំងស្នើសុំច្រើនតំណ ហើយអ្នកទិញចុងក្រោយគាត់មិនព្រមបង់សេវា

-បានបង់សេវាតាមអ្នករត់ការ ហើយអ្នករត់ការយឺតយ៉ាវមកបង់សេវា។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់គួរប្រើប្រាស់យន្តការ ឬវិធានការឱ្យបានម៉ឺងម៉ាត់ចំពោះសំណង់ទាំងឡាយណាដែលខកខានក្នុងការបង់សេវាសំណង់ឱ្យធ្វើការបង់ប្រាក់សេវាឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលាចូលថវិកាជាតិ។

### ៣.១.៤០. ភាពយឺតយ៉ាវក្នុងការទារបំណុលពីផលទុនអាកាសចរស៊ីវិល

បទបញ្ជាលេខ០៤បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ចំណុច១៤ ចែងថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវដាក់ចេញវិធានការជាមួយក្រសួងស្ថាប័នសាមី និងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តការតឹងទារបំណុលដែលផ្នែកឯកជន ឬក្រុមហ៊ុននានាជំពាក់រដ្ឋ ដូចជាៈ បញ្ឈប់ការអនុញ្ញាតនាំចូល-នាំចេញ បង្កកគណនីធនាគារ បញ្ឈប់អាជ្ញាបណ្ណ និងក្នុងករណីការអនុវត្តតឹងទារបំណុលនេះមិនមានប្រសិទ្ធភាព ក្រសួងស្ថាប័នសាមីត្រូវរៀបចំសំណុំរឿងប្តឹងទៅតុលាការ។

តាមការពិនិត្យ និងផ្ទៀងផ្ទាត់តារាងសម្រង់ចំណូលពីសេវាកម្មដែលត្រូវទូទាត់ និងបានទូទាត់ គិតពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងតារាងបំណុលកុំរ៉ៃរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលសម្រាប់ឆ្នាំ២០១៨ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនៅមានភាពយឺតយ៉ាវក្នុងការទារបំណុលចរន្ត និងបំណុលកុំរ៉ៃមួយចំនួនពីផលទុនអាកាសចរណ៍ស៊ីវិលដែលក្រុមហ៊ុនអាកាសចរមិនទាន់បានបង់ចូលថវិការដ្ឋគិតមកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

អាស្រ័យហេតុនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលគួរចាត់វិធានការឱ្យបានម៉ឺងម៉ាត់ទារបំណុលពីក្រុមហ៊ុនអាកាសចរនៅជំពាក់ឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

ឆ្លើយតបចំពោះការលើកឡើងខាងលើ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានឯកភាពទៅនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ។ ក៏ប៉ុន្តែ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបញ្ជាក់ថា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានប្រឹងប្រែងប្រមូលចំណូលបានកើនឡើងជារៀងរាល់ឆ្នាំ។ ដោយឡែក ចំពោះបំណុលដែលនៅសល់ចុងឆ្នាំនីមួយៗជាបំណុលចរន្តតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានបន្ថែមផងដែរថា នីតិវិធីនៃការទូទាត់គឺៈ

- ការចេញវិក្កយបត្រទូទាត់គឺនៅដើមខែថ្មីបន្ទាប់ពីខែប្រតិបត្តិការ
- ក្រុមហ៊ុនភាគច្រើនធ្វើការទូទាត់ពីការិយាល័យកណ្តាលរបស់ក្រុមហ៊ុនដែលមានទីតាំងនៅក្រៅប្រទេស។

ហេតុដូច្នេះហើយទើបនៅចុងការិយបរិច្ឆេទនៃឆ្នាំនីមួយៗតែងតែមានបំណុលចុងគ្រាជារៀងរាល់ឆ្នាំ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.៤១.ការពុំមានវិធានការតឹងទារបំណុល

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០១៨ ក្រុមហ៊ុនហ្គ្រីនត្រេដ មានបំណុលមួយចំនួនត្រូវទារពីអតិថិជនចាប់តាំងពីឆ្នាំ១៩៩៨មក។

អាស្រ័យហេតុនេះ ដើម្បីការគ្រប់គ្រងបំណុលមានប្រសិទ្ធភាព ក្រុមហ៊ុនហ្គ្រីនត្រេដ គួរមានយន្តការក្នុងការទាមទារបំណុលឱ្យមានប្រសិទ្ធភាព។

ឆ្លើយតបនឹងការលើកឡើងនេះ យោងអង្គប្រជុំក្រុមប្រឹក្សាភិបាលគោរពជូន ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបានឆ្លងក្រុមប្រឹក្សាភិបាលក្រុមហ៊ុនហ្គ្រីនត្រេដ បានធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃប្រតិបត្តិការការងាររបស់ក្រុមហ៊ុនហ្គ្រីនត្រេដចាប់ពីខែមិថុនា ឆ្នាំ២០១៦ ដល់ខែមីនា ឆ្នាំ២០១៨ ដើម្បីស្នើសុំអនុសាសន៍។ ជាលទ្ធផលបានលើកឡើងពីបញ្ហាបំណុល និងសំណើសុំអន្តរាគមន៍ទៅឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជួយសម្រួលនីតិវិធីនៃការប្តឹងទាមទារបំណុលរបស់ក្រុមហ៊ុនហ្គ្រីនត្រេដនៅសាលាដំបូងរាជធានី ខេត្តកំពង់ឆ្នាំង ខេត្តសៀមរាប និងខេត្តព្រៃវែង។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រុមហ៊ុនហ្គ្រីនត្រេដ នឹងមានយន្តការក្នុងការទាមទារបំណុល។

## ៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១. កង្វះខាតក្នុងការប្រមូលចំណូលអាករលើការស្នាក់នៅ

ប្រកាសលេខ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ត្រង់ជំពូកទី២ ប្រការ៥ ចំណុចទី៣ បានចែងថា "អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចប្រមូលប្រាក់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ" និងត្រង់ជំពូកទី១៤ ប្រការ១០៩ បានចែងថា "សាខាពន្ធដារខេត្ត ខណ្ឌ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យមស្ថិតក្នុងមណ្ឌលដែនដីរបស់ខ្លួន"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៨ សាខាពន្ធដារខេត្តប៉ៃលិន បានរៀបចំស្ថិតិ ជំរឿនផ្ទះសំណាក់ និងសណ្ឋាគារ មានចំនួនសរុប២៩ទីតាំង ប៉ុន្តែសាខាពន្ធដារខេត្តប្រមូលចំណូលបានតែ១២ទីតាំង ដែលមានចំនួនទឹកប្រាក់១៤ ០៥៧ ០៣៩រៀល។

ឆ្លើយតបនឹងការលើកឡើងនេះ សាខាពន្ធដារខេត្តប៉ៃលិន សូមទទួលស្គាល់ការអនុវត្តប្រមូលចំណូលអាករលើការស្នាក់នៅពិតជានៅមានការខ្វះខាត ដោយសារនៅក្នុងខេត្តប៉ៃលិន មានអាជីវកម្មប្រភេទផ្ទះសំណាក់ និងសណ្ឋាគារ ក្នុងបរិមាណតិច ជាហេតុធ្វើឱ្យចំណូលអាករប្រភេទនេះមានកម្រិតទាបនៅឡើយ។ ទន្ទឹមនឹងនោះដែរ នាដើមឆ្នាំ២០១៩ សាខាពន្ធដារខេត្ត ក៏បានខិតខំយកចិត្តទុកដាក់ខ្ពស់ ក្នុងការប្រមូលចំណូលអាករលើការស្នាក់នៅ ដោយធ្វើការចុះស្រង់ស្ថិតិផ្ទះសំណាក់ សណ្ឋាគារតាមបណ្តាមុខព្រួញទាំងពីរ (ក្រុងប៉ៃលិន និងស្រុកសាលាក្រៅ) ព្រមទាំងបានធ្វើលិខិតជូនដំណឹងដល់ម្ចាស់ផ្ទះសំណាក់

ដែលមានផលរបរដល់កម្រិត ដើម្បីចូលខ្លួនមកបំពេញកាតព្វកិច្ចចុះបញ្ជី និងប្រកាសបង់ប្រាក់ពន្ធឱ្យស្របតាមច្បាប់សារពើពន្ធ ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានលើការកែលម្អអនុវត្តតាមអនុសាសន៍សវនកម្មជាបន្តទៀត។

**៣.២.២. ការប្រមូលពន្ធប៉ាតង់**

ប្រកាសលេខ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការកែសម្រួលវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ត្រង់ប្រការ៥ ចំណុច៤ បានតម្រូវឱ្យអ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានីខេត្តផ្សេងគ្នាត្រូវបង់ពន្ធប៉ាតង់ទៅតាមរាជធានី ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។ ត្រង់ប្រការ៧ នៃប្រកាសខាងលើ បានចែងថា ពន្ធប៉ាតង់ត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

សេចក្តីជូនដំណឹងលេខ៣៦២១ អពដ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨ ស្តីពីការដាក់លិខិតប្រកាស និងបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ២០១៨ ត្រង់ចំណុចទី១ បានចែងថា "អ្នកជាប់ពន្ធទាំងអស់ រួមទាំងអ្នកជាប់ពន្ធដែលមិនទាន់បានធ្វើបច្ចុប្បន្នភាព និងអ្នកជាប់ពន្ធដែលធ្វើបច្ចុប្បន្នភាពរួចរាល់ហើយ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធប៉ាតង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨" និងត្រង់ចំណុចទី៩ បានកំណត់ថា "អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចបង់ប្រាក់ពន្ធឱ្យបានត្រឹមត្រូវទៅតាមពេលវេលាដែលច្បាប់បានកំណត់..."។

តាមការធ្វើតេស្តក្រុមហ៊ុន សាខាក្រុមហ៊ុនចំនួន៦ ៦១៧ (សាខាក្រុមហ៊ុនចំនួន៣១២ ក្រុមហ៊ុនរបបស្វ័យប្រកាសអ្នកជាប់ពន្ធមធ្យមចំនួន៣ ៧១៦ ក្រុមហ៊ុនរបបស្វ័យប្រកាសអ្នកជាប់ពន្ធតូចចំនួន២ ៥៨៩) ដែលចុះបញ្ជីនៅតាមបណ្តាសាខាពន្ធដារខណ្ឌចំនួន៨ និងខេត្តចំនួន១២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានក្រុមហ៊ុន សាខាក្រុមហ៊ុនភាគច្រើនដែលបានធ្វើអាជីវកម្មនៅតាមខេត្តផ្សេងគ្នា បានបង់ពន្ធប៉ាតង់រួច ប៉ុន្តែក្រុមហ៊ុន សាខាក្រុមហ៊ុនតិចតួចទៀតមិនទាន់បានបង់ពន្ធប៉ាតង់នៅឡើយ។ ការខកខានក្នុងការបង់ពន្ធប៉ាតង់របស់ក្រុមហ៊ុនទាំងនោះ នាំឱ្យការប្រមូលពន្ធប៉ាតង់មិនអស់លទ្ធភាព។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរមានវិធានការបន្ថែមទៀត ដើម្បីពង្រឹងយន្តការប្រមូលពន្ធប៉ាតង់ឱ្យអស់លទ្ធភាព។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងបានបំភ្លឺបន្ថែមថា នៅមានសាខាក្រុមហ៊ុនមួយចំនួនប៉ុណ្ណោះ ដែលមិនទាន់បានបង់ពន្ធប៉ាតង់ ព្រោះក្រុមហ៊ុនមួយចំនួនត្រូវផ្ទេរពីអ្នកជាប់ពន្ធមធ្យមទៅជាអ្នកជាប់ពន្ធធំ ខ្លះក៏បានបង់នៅកន្លែងដែលស្នាក់ការកណ្តាលរបស់សហគ្រាសដែលបានចុះបញ្ជី និងមួយចំនួនទៀតជាសហគ្រាសលទ្ធកម្ម។ ក្រុមហ៊ុនខ្លះធ្វើបច្ចុប្បន្នភាពមិនទាន់ចប់ និងម្ចាស់ក្រុមហ៊ុនខ្លះ មិនព្រមសហការក្នុងការផ្តល់ឯកសារពាក់ព័ន្ធនានា ដែលជាហេតុធ្វើឱ្យការប្រមូលពន្ធប៉ាតង់ពុំបានអស់។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺនេះ។ ដូច្នេះអាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

**៣.២.៣.ការប្រមូលពន្ធប្រថាប់ត្រា**

អនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជំពូកទី១០ អគ្គនាយកដ្ឋានពន្ធដារ ត្រង់មាត្រា៣៦ បានចែងថា "អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចរៀបចំលិខិតបទដ្ឋាននានា កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់ និងរក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ...។"

ប្រកាសលេខ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ត្រង់ជំពូកទី៦ ប្រការ៣៩ នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យមានភារកិច្ចរៀបចំគោលនយោបាយ នីតិវិធី និងស្តង់ដារការងារដែលពាក់ព័ន្ធនឹងការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិ ឬសិទ្ធិកាន់កាប់ចលនទ្រព្យ និងអចលនទ្រព្យ។ ប្រកាសលេខ៥០៧ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា ត្រង់ប្រការ៨ បានណែនាំថា អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធប្រថាប់ត្រាឱ្យបានគ្រប់ដោយភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ។

តាមការពិនិត្យសំណុំឯកសារប្រថាប់ត្រាលើអចលនទ្រព្យចំនួន២ ៣៨១ នៅសាខាពន្ធដារខេត្តចំនួន១២ សម្រាប់ការិយបរិច្ឆេទ២០១៨ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានសំណុំឯកសារប្រថាប់ត្រាមួយចំនួននៅសាខាពន្ធដារខេត្តចំនួន៤ មានភ្ជាប់ជាមួយ ដូចជា ដីកាបញ្ជូនរបស់មេឃុំ ឬអភិបាលនៃគណៈអភិបាលក្រុង ស្រុក ឯកសារបញ្ជាក់អត្តសញ្ញាណអ្នកផ្ទេរសិទ្ធិ ឬអ្នកទទួលសិទ្ធិ គំនូសប្លង់ទីតាំង និងលិខិតប្រកាសពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់អចលទ្រព្យដោយបំពេញព័ត៌មានមួយចំនួននៅមិនទាន់បានពេញលេញ ដោយខ្វះឯកសារបញ្ជាក់ប្រវត្តិអចលនទ្រព្យចំពោះការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យមិនទាន់ចុះបញ្ជី។ ការខ្វះប្រវត្តិអចលនទ្រព្យ ចំពោះការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យមិនទាន់ចុះបញ្ជីមួយចំនួននាំឱ្យការប្រថាប់ត្រាលើសំណុំឯកសារអចលនទ្រព្យពុំទាន់ច្បាស់លាស់។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបានបំភ្លឺបន្ថែមថា ការអនុវត្តការប្រមូលពន្ធប្រថាប់ត្រា នៅមានបញ្ហាប្រឈមមួយចំនួនក្នុងការកំណត់នូវព័ត៌មានពីអាយុកាលសំណង់ និងទីតាំងរបស់អចលនទ្រព្យ ដែលទាមទារឱ្យមានការសហការពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងការផ្តល់និយាមការឱ្យបានច្បាស់លាស់ ដើម្បីជាឯកសារគាំទ្រក្នុងការប្រមូលពន្ធប្រថាប់ត្រាឱ្យបានត្រឹមត្រូវ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួង។ ដូច្នេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.២.៤.កង្វះខាតក្នុងការប្រមូលចំណូលពីការអនុញ្ញាតបើក និងបិទការដ្ឋានសំណង់

អនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីលិខិតអនុញ្ញាតសាងសង់ បានតម្រូវឱ្យម្ចាស់សំណង់មុនចាប់ដំណើរការការដ្ឋាន ម្ចាស់សំណង់ត្រូវមានលិខិតអនុញ្ញាតសាងសង់ បើកការដ្ឋាន និងបិទការដ្ឋានពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ឬការិយាល័យខេត្ត ក្រុង និងប្រកាសអន្តរក្រសួងលេខ៩៩៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានកំណត់នូវដែនសមត្ថកិច្ចជូនមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីលើការគ្រប់គ្រងការផ្ដល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន និងលិខិតអនុញ្ញាតបិទការដ្ឋានសំណង់លំនៅឋានដូចជាភូមិគ្រឹះ ផ្ទះល្វែង ផ្ទះថ្មក្រោមឈើលើ ទាំងនៅក្រៅក្រុង ក្នុងក្រុង និងរាជធានី ព្រមទាំងបានកំណត់នូវថ្លៃសេវាលើវិស័យសំណង់ត្រូវប្រមូលផងដែរ។

តាមការធ្វើសវនកម្មឆ្នាំ២០១៨ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្តចំនួន១១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មន្ទីរទាំងនោះបានផ្ដល់លិខិតអនុញ្ញាតសាងសង់ជូនម្ចាស់សំណង់ និងបានប្រមូលចំណូលពីសេវានេះរួចហើយ ប៉ុន្តែមន្ទីរទាំងនោះខកខានមិនបានប្រមូលចំណូលពីសេវាបើក និងបិទការដ្ឋានបានគ្រប់តាមចំនួនលិខិតអនុញ្ញាតសាងសង់ឡើយ។

ដោយសារកង្វះខាតក្នុងការបំពេញកាតព្វប្រមូលចំណូលពីការអនុញ្ញាតបើក និងបិទការដ្ឋានសំណង់នេះ នាំឱ្យបាត់ចំណូលជាគុណប្រយោជន៍ថវិការាជធានី ខេត្ត និងអាចកើតមានសំណង់មិនរៀបរយ បទដ្ឋានបច្ចេកទេសសំណង់ពុំសមស្រប។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំដល់មន្ទីរទាំងនោះឱ្យខិតខំអនុវត្តតាមគោលការណ៍ណែនាំខាងលើឱ្យមានប្រសិទ្ធភាព។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តបានឱ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយដីជាអ្នកបំភ្លឺ ហើយមន្ទីរបានបំភ្លឺថា បន្ទាប់ពីបានផ្ដល់លិខិតអនុញ្ញាតសាងសង់ជូនម្ចាស់សំណង់រួច ទើបមន្ទីរឱ្យម្ចាស់សំណង់ដាក់លិខិតស្នើសុំបើកការដ្ឋាន ។ ជាមួយគ្នានេះ ក៏មានម្ចាស់សំណង់ខ្លះបានគេចវេះពុំព្រមដាក់ពាក្យទេ ម៉្យាងទៀតដោយសារពុំមានច្បាប់ផាកពិន័យលើសំណង់សាងសង់ខុសច្បាប់ ហើយមន្ត្រីគ្រប់គ្រងសំណង់មិនមែនជារដ្ឋបាលយុត្តិធម៌ទើបមន្ទីរពុំអាចចាត់វិធានការណាមួយចំពោះពួកគាត់ ក្រៅពីអញ្ជើញពួកគាត់មកស្នើសុំបើក និងបិទការដ្ឋានប៉ុណ្ណោះ។ ប៉ុន្តែ នៅឆ្នាំ២០១៩ មន្ទីរបានប្រជុំពិភាក្សាថា នៅពេលម្ចាស់សំណង់ដាក់ពាក្យស្នើសុំសាងសង់ គឺមន្ទីរស្នើសុំឱ្យគាត់បំពេញបែបបទបើកការដ្ឋានសាងសង់ជាមួយគ្នាតែម្ដងជៀសវាងគាត់គេចវេះដូចឆ្នាំកន្លងមក។ ចំពោះលិខិតបិទការដ្ឋាន មន្ទីរនឹងស្នើសុំឲ្យគាត់បង់ប្រាក់នៅមន្ទីរជាមុននៅពេលគាត់សាងសង់បញ្ចប់ មន្ទីរ

នឹងចេញលិខិតអនុញ្ញាតបិទការដ្ឋានឲ្យតែម្តង។ មន្ទីរផ្សេងទៀតថា ខ្វះមន្ត្រីជំនាញបំពេញការងារនេះ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសូមឱ្យរដ្ឋបាលខេត្តជួយជំរុញការងារនេះឱ្យបានប្រសើរនាពេលខាងមុខ ហើយអាជ្ញាធរសវនកម្មជាតិនឹងតាមដានលើការអនុវត្តការងារនេះបន្តទៀត។

**៣.២.៥. ការបង់ចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្លងការិយបរិច្ឆេទ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំណត់ក្នុងប្រកាសលេខ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូល សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកទី២-ការបង់ប្រាក់រជ្ជទេយ្យចំណូល ត្រង់ប្រការ ១១ បានចែងថា "រៀងរាល់ថ្ងៃទី២៥ នៃខែនីមួយៗ គឺពីខែមករា ដល់ខែវិច្ឆិកា និងថ្ងៃទី៣១ ខែធ្នូ រជ្ជទេយ្យករចំណូល ត្រូវធ្វើសលាកប័ត្រចំណូលទៅតាមមាតិកាថវិកានូវចំនួនទឹកប្រាក់ចំណូលដែលខ្លួនបានប្រមូល។ រជ្ជទេយ្យករចំណូលត្រូវធ្វើសលាកប័ត្របង្វែរចំណូលថវិកាជាបី (៣) ច្បាប់ ដើម្បីដាក់ជូនអាណាប័កចុះហត្ថលេខា ហើយបញ្ជូនទៅគណនេយ្យករសាធារណៈ យ៉ាងយូរត្រឹមថ្ងៃទី២៦ រៀងរាល់ខែ និងថ្ងៃទី៣១ ខែធ្នូ។ ក្រោយពីពិនិត្យថាត្រឹមត្រូវ គណនេយ្យករសាធារណៈត្រូវរៀបចំបង្វែរចំណូលចូលថវិកាជាតិ ចុះហត្ថលេខាលើសលាកប័ត្រចំណូល និងបញ្ជូន២ច្បាប់ មករជ្ជទេយ្យករចំណូលវិញ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០១៨ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្តកំពង់ធំបានប្រមូលចំណូលលើវិស័យជំនាញទាំង១២ រួមមាន វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ វិស័យកសិកម្ម វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យសាធារណការ និងដឹកជញ្ជូន វិស័យសុខាភិបាល វិស័យរ៉ែ និងថាមពល វិស័យឧស្សាហកម្ម និងសិប្បកម្ម វិស័យទេសចរណ៍ វិស័យព័ត៌មាន វិស័យបរិស្ថាន វិស័យពាណិជ្ជកម្ម និងវិស័យវប្បធម៌ ប្រចាំខែធ្នូ (ចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨) សរុបចំនួន ១១១ ៦០៦ ៤០០រៀល។ ជាក់ស្តែង បេឡាករនៃអង្គភាពច្រកចេញចូលតែមួយ បានធ្វើការបង់ចំណូលខាងលើនេះជូនរជ្ជទេយ្យករចំណូលរដ្ឋបាលខេត្តកំពង់ធំនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ បន្ទាប់មកទើបរជ្ជទេយ្យករចំណូលបានធ្វើការបើកផ្តល់ និងបង្វែរចំណូលពីសេវាសាធារណៈទាំងនោះជូនមន្ទីរជំនាញទាំង១២វិស័យ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ ដើម្បីឱ្យរបាយការណ៍ចំណូលបង្ហាញត្រឹមត្រូវ រដ្ឋបាលខេត្តគួរជំរុញឱ្យអង្គភាពច្រកចេញចូលតែមួយឱ្យបង់ចំណូលថវិកាត្រឹមត្រូវស្របតាមប្រកាសខាងលើ។

ឆ្លើយតបនឹងការលើកឡើង រដ្ឋបាលខេត្តកំពង់ធំបានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងធ្វើការណែនាំដល់អង្គភាពច្រកចេញចូលតែមួយឱ្យអនុវត្តស្របតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានការអនុវត្តតាមអនុសាសន៍សវនកម្មជាបន្តទៀត។

### ៣.២.៦.ការពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ

ប្រកាសលេខ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា ត្រង់ប្រការ២៣ បានចែងថា "របាយការណ៍សមិទ្ធកម្មគឺឆ្លុះបញ្ចាំងអំពីការវាស់វែងលទ្ធផល និងវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាព អនុកម្មវិធី ឬកម្មវិធីរបស់អង្គភាពថវិកាក្នុងការរួមចំណែកសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួងស្ថាប័ន។ អង្គភាពថវិកានៃក្រសួងស្ថាប័ន ត្រូវតាមដានការអនុវត្តថវិការបស់ខ្លួនជាប្រចាំ និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពលើសូចនាករលទ្ធផលក្នុងឆ្នាំជាចាំបាច់ និងសូចនាករលទ្ធផលចុងក្រោយ ដោយអនុលោមទៅតាមទម្រង់តារាងគំរូរួម និងតាមទម្រង់នៃប្រភេទរបាយការណ៍របស់ក្រសួង ស្ថាប័នសាមី។ របាយការណ៍សមិទ្ធកម្មទាំងអស់ត្រូវធ្វើឡើងតាមកាលបរិច្ឆេទ ដូចខាងក្រោម ៖

របាយការណ៍សមិទ្ធកម្មប្រចាំឆមាស កម្រិតចង្កោមសកម្មភាព និង/ឬកម្រិតអនុកម្មវិធី ត្រូវផ្ញើមកយ៉ាងយូរបំផុត២០ថ្ងៃ បន្ទាប់ពីការបញ្ចប់ការអនុវត្តនៃឆមាសទី១។ របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំដល់កម្រិតកម្មវិធីត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមខែមីនានៃឆ្នាំបន្ទាប់"។

តាមរយៈការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមខែមីនា ឆ្នាំ២០១៩ អង្គភាពថវិកានៃមន្ទីរជំនាញមួយចំនួនក្នុងខេត្តចំនួន៥ ពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំឡើយ រួមមាន៖

១. ខេត្តស្វាយរៀងមានមន្ទីរចំនួន៣ គឺមន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរពាណិជ្ជកម្ម មន្ទីររ៉ែ និងថាមពល។

២.ខេត្តបន្ទាយមានជ័យមានមន្ទីរចំនួន៤ គឺមន្ទីរពាណិជ្ជកម្ម មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរឧស្សាហកម្ម និងសិប្បកម្ម និងមន្ទីរព័ត៌មាន។

៣.ខេត្តកោះកុងមានអង្គភាពចំនួន១២ គឺរដ្ឋបាលខេត្ត មន្ទីរពាណិជ្ជកម្ម មន្ទីររ៉ែ និងថាមពល មន្ទីរទេសចរណ៍ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរឧស្សាហកម្ម និងសិប្បកម្ម មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរកិច្ចការនារី មន្ទីរបរិស្ថាន មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៤.ខេត្តកំពង់ឆ្នាំងមានអង្គភាពចំនួន១៤ គឺ រដ្ឋបាលខេត្ត មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរឧស្សាហកម្ម និងសិប្បកម្ម មន្ទីរកិច្ចការនារី មន្ទីរបរិស្ថាន មន្ទីររ៉ែ និងថាមពល មន្ទីរពាណិជ្ជកម្ម មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរសុខាភិបាល និង

៥.ខេត្តពោធិ៍សាត់មានមន្ទីរចំនួន១ គឺមន្ទីរឧស្សាហកម្ម និងសិប្បកម្ម

ដោយសារការពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ នាំឱ្យពុំមានសក្ខីកម្មក្នុងការវាស់វែងនូវប្រសិទ្ធភាព ប្រសិទ្ធផល នៃការអនុវត្តថវិកាតាមកម្មវិធី ដែលជាគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្ត គួរជំរុញអង្គភាពពាក់ព័ន្ធក្រោមឱវាទអនុវត្តឱ្យបានសមស្របតាមប្រកាសណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តបានឯកភាព និងសន្យាជំរុញដល់មន្ទីរ អង្គភាពដែលអនុវត្តថវិកាកម្មវិធីឱ្យរៀបចំរបាយការណ៍នេះ នាពេលខាងមុខ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា រដ្ឋបាលខេត្តនឹងជួយជំរុញការងារនេះឱ្យបានល្អប្រសើរនាការិយបរិច្ឆេទក្រោយៗ ហើយអាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តការងារនេះបន្តទៀត។

### ៣.២.៧.ការមិនបានចាត់តាំងអ្នកគ្រប់គ្រងគម្រោងដើម្បីតាមដានការងារសំណង់

ប្រកាសលេខ៣៨១ ប្រក.សហវ/២០១០ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើសៀវភៅលទ្ធកម្មស្តីពីការអនុវត្តន៍វិធាន និងបទប្បញ្ញត្តិ ស្តីពីលទ្ធកម្មសាធារណៈ ត្រង់ជំពូកទី២ ចំណុច៣.១៤.៨ បានបញ្ជាក់ថា ជាទូទៅការត្រួតពិនិត្យកិច្ចសន្យាសំណង់មានការស្មុគស្មាញ ដោយសារកត្តាទាំងឡាយដែលមិនអាចដឹងបានមុនពេលចាប់ផ្តើមការងារ។ ដូច្នេះ តម្រូវឱ្យមានការចាត់តាំងអ្នកគ្រប់គ្រងគម្រោង ដើម្បីធ្វើការគ្រប់គ្រងទីតាំងគម្រោង និងត្រួតពិនិត្យសកម្មភាពប្រចាំថ្ងៃរបស់ "អ្នកទទួលការ"។ អ្នកគ្រប់គ្រងគម្រោងអាចជាបុគ្គលនៅក្នុងអង្គភាពលទ្ធកម្ម ឬជាទីប្រឹក្សាជំនាញ ឬជាបុគ្គលដែលមានជំនាញមកពីស្ថាប័នអនុវត្តលទ្ធកម្ម។ អ្នកគ្រប់គ្រងគម្រោងត្រូវធ្វើរបាយការណ៍ជាប្រចាំអំពីវឌ្ឍនភាព និងបញ្ហាដែលកើតមានឡើងក្នុងពេលអនុវត្តការងារ។

តាមការធ្វើតេស្តសវនកម្មលើសំណុំឯកសារលទ្ធកម្មឆ្នាំ២០១៨ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ខេត្តស្វាយរៀង កណ្តាល រតនគីរី កំពង់ឆ្នាំង និងរាជធានីភ្នំពេញ ពុំបានចាត់តាំងអ្នកគ្រប់គ្រងគម្រោងដើម្បីតាមដានការងារសាងសង់របស់អ្នកទទួលការ និងធ្វើរបាយការណ៍វឌ្ឍនភាពឡើយ។

ដោយសារការពុំបានចាត់តាំងឱ្យមានអ្នកគ្រប់គ្រងគម្រោង នាំឱ្យគ្មាននូវរបាយការណ៍វឌ្ឍនភាពការងារសំណង់ និងពុំមានមូលដ្ឋានសម្រាប់គណៈកម្មការលទ្ធកម្មធ្វើការវាយតម្លៃ និងប្រគល់ទទួលសំណង់ និងអាចនាំឱ្យខាតបង់ថវិការដ្ឋនៅពេលដែលសំណង់ត្រូវបានកេងបន្លំបទដ្ឋានលក្ខណៈបច្ចេកទេស ដូចជា ដែក ស៊ីម៉ង់ត៍។ល។

អាស្រ័យហេតុនេះ រដ្ឋបាលរាជធានីខេត្តខាងលើគួរណែនាំគណៈកម្មការលទ្ធកម្មឱ្យចាត់តាំងអ្នកគ្រប់គ្រងគម្រោង ដើម្បីធ្វើការតាមដានរាល់សកម្មភាពការងាររបស់អ្នកទទួល

ការ និងរាល់បញ្ហាដែលកើតមានក្នុងអំឡុងពេលអនុវត្តការងារ ព្រមទាំងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពជូនប្រធានឡេណៈកម្មការលទ្ធកម្មជាប្រចាំ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តមួយចំនួន និងរដ្ឋបាលរាជធានីបានបំភ្លឺថា បានណែនាំដល់មន្ទីរជំនាញរួចហើយ និងមួយចំនួនទៀតថា ដោយសារការយល់ច្រឡំថា មានក្រុមការងារចុះពិនិត្យការងាររបស់អ្នកទទួលការរួចហើយ ដោយគ្រាន់តែពុំបានធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពប៉ុណ្ណោះ។ ជាមួយគ្នានេះ រដ្ឋបាលខេត្តមួយចំនួនផ្សេងទៀតក៏បានសន្យាថាជំរុញការងារនេះបន្ថែមទៀត។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិរំពឹងថា រដ្ឋបាលខេត្តនឹងណែនាំការអនុវត្តការងារនេះឱ្យបានល្អប្រសើរ ហើយអាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តការងារនេះបន្តទៀត។

### ៣.២.៨.ការវាយតម្លៃអ្នកចូលរួមដេញថ្លៃ និងប្រគល់កិច្ចសន្យាដោយពុំមានតារាងទិន្នន័យតម្លៃទីផ្សារ

ជាទូទៅ ការធ្វើកិច្ចលទ្ធកម្មសាធារណៈ គេតែងតែអនុវត្តវិធីសាស្រ្តលទ្ធកម្មដោយចរចាថ្លៃ ពិគ្រោះថ្លៃ ដេញថ្លៃក្នុងស្រុក និងដេញថ្លៃជាលក្ខណៈអន្តរជាតិ ផ្អែកទៅតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។ ទន្ទឹមនឹងនេះ អង្គភាពលទ្ធកម្មត្រូវធ្វើតារាងទិន្នន័យតម្លៃទីផ្សារដើម្បីទុកជាបទដ្ឋានមួយក្នុងការជ្រើសរើសអ្នកដេញថ្លៃ។ សារាចរលេខ០០២ សហវ អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី១៣ បានតម្រូវឱ្យស្ថាប័នអនុវត្តលទ្ធកម្មត្រូវចាត់ចែងរៀបចំតារាងទិន្នន័យតម្លៃទីផ្សារនៃសមាសធាតុលទ្ធកម្មសម្រាប់ទុកជាព័ត៌មានបន្ថែមក្នុងការវាយតម្លៃ ជ្រើសរើសអ្នកដេញថ្លៃ និងប្រគល់កិច្ចសន្យា។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈឆ្នាំ ២០១៨ មានមន្ទីរមួយចំនួននៃខេត្តត្បូងឃ្មុំ និងមន្ទីរមួយចំនួននៃខេត្តកែប ពុំទាន់បានរៀបចំតារាងទិន្នន័យតម្លៃទីផ្សារនៃសមាសធាតុលទ្ធកម្ម ដែលជាព័ត៌មានបន្ថែមសម្រាប់ពិចារណាក្នុងការជ្រើសរើសអ្នកដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃ និងប្រគល់កិច្ចសន្យានៅឡើយ។ រដ្ឋបាលខេត្តត្បូងឃ្មុំ និងរដ្ឋបាលខេត្តកែប គួរណែនាំឱ្យមន្ទីរពាក់ព័ន្ធខាងលើ រៀបចំតារាងទិន្នន័យតម្លៃទីផ្សារ ដើម្បីជាព័ត៌មានបន្ថែមសម្រាប់ពិចារណាក្នុងការជ្រើសរើសអ្នកចូលរួមកិច្ចលទ្ធកម្មសាធារណៈ និងប្រគល់កិច្ចសន្យា។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ រដ្ឋបាលខេត្តត្បូងឃ្មុំ និងរដ្ឋបាលខេត្តកែបបានឯកភាព នឹងខិតខំកែលំអតាមអនុសាសន៍ដែលបានលើកឡើងសម្រាប់ឆ្នាំបន្ទាប់។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានមើលនូវវឌ្ឍនភាពបន្តទៀត។

## ៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០១៨ នាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មមួយចំនួន ដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើង ត្រូវបានក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាខិតខំអនុវត្តកែលម្អគួរឱ្យកត់សម្គាល់ និងកោតសរសើរ រីឯចំណុចមួយចំនួនទៀតមិនទាន់បានអនុវត្តបានពេញលេញនៅឡើយ ជាអាទិ៍ ៖

### ៤.១. ប្រសិទ្ធភាពនៃការធ្វើសវនកម្ម

ដើម្បីឱ្យការធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាព អគ្គនាយកដ្ឋានពន្ធដារបានណែនាំឱ្យអង្គភាពពន្ធដារក្រោមឱវាទជ្រើសរើសអ្នកជាប់ពន្ធដែលមានហានិភ័យខ្ពស់ជាអាទិភាពសម្រាប់ការធ្វើសវនកម្ម។ តាមការពិនិត្យមើលតារាងលទ្ធផលការងារសវនកម្មប្រចាំឆ្នាំ២០១៨ របស់សាខាពន្ធដារខណ្ឌចំនួន៨ និងខេត្តចំនួន១១ (ការធ្វើសវនកម្មលើលិខិតស្នាម និងមានកម្រិត) អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាពន្ធដារខណ្ឌចំនួន៤ និងខេត្តចំនួន២បានធ្វើសវនកម្ម និងកំណត់ពន្ធសហគ្រាសមួយចំនួនសូន្យ។ ការកំណត់ពន្ធសូន្យនេះដោយសារការកំណត់ហានិភ័យរបស់សហគ្រាសដែលត្រូវធ្វើសវនកម្មពុំទាន់បានល្អ អាចនាំឱ្យការធ្វើសវនកម្មមិនមានប្រសិទ្ធភាព។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា ការវិភាគហានិភ័យក្នុងការធ្វើសវនកម្មមិនទាន់បានសុក្រិតនៅឡើយ ដោយពុំទាន់មានព័ត៌មានគ្រប់គ្រាន់ និងអនុវត្តដោយដៃ។ ក្នុងករណីមួយចំនួន អ្នកជាប់ពន្ធមានឯកសារគ្រប់គ្រាន់ ដើម្បីដោះបន្ទុក នោះអាចនាំឱ្យមានការកំណត់ពន្ធសូន្យ។

### ៤.២. ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន

ដើម្បីគ្រប់គ្រងការប្រមូលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតបទដ្ឋាន និងនីតិវិធីទាក់ទងទៅនឹងការប្រមូលព័ត៌មានអ្នកជាប់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបានបង្កើតក្រុមការងារមួយចំនួន និងបានសហការធ្វើការងារជាមួយក្រសួងពាណិជ្ជកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ប៉ុន្តែ អគ្គនាយកដ្ឋានពន្ធដារ មិនទាន់បានប្រមូលព័ត៌មានសហគ្រាសនៅតាមបណ្ដាក្រសួង ស្ថាប័នមួយចំនួនផ្សេងទៀតឱ្យបានពេញលេញ និងទាន់ពេលវេលានៅឡើយ។ អាជ្ញាធរសវនកម្មជាតិបានឃើញនូវការបង្កើតក្រុមការងារមួយចំនួនរួចហើយ និងលើកទឹកចិត្តចំពោះការប្រមូលព័ត៌មានអំពីសហគ្រាសដែលបានចុះបញ្ជីតាមក្រសួងស្ថាប័ននានាបន្ថែមទៀត។

### ៤.៣. ការគ្រប់គ្រងអ្នកជាប់ពន្ធ

រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់បេសកកម្មជូនអគ្គនាយកដ្ឋានពន្ធដារនូវភារកិច្ច ដូចជា៖ ផ្ដល់សេវាដល់អ្នកជាប់ពន្ធ ប្រមូលចំណូលពន្ធ និងអនុវត្តកម្មវិធីចាប់បង្ខំចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្ដីពីសារពើពន្ធ។ ផ្អែកតាមស្ថិតិសហគ្រាសប្រចាំខែ ឆ្នាំ របស់ការិយាល័យ

ស្ថិតិសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សហគ្រាសមួយចំនួនតូចពុំបានដាក់លិខិតប្រកាសពន្ធទេ។ ការខកខានរបស់អ្នកជាប់ពន្ធក្នុងការដាក់លិខិតប្រកាសពន្ធទៅតាមទម្រង់ និងទីកន្លែងកំណត់ បានផ្តល់ផលលំបាកចំពោះរដ្ឋបាលសារពើពន្ធក្នុងការប្រមូលពន្ធ និងជាបច្ច័យមួយនៃការគេចវេះពន្ធ។ សហគ្រាសដែលមិនបានមកដាក់លិខិតប្រកាស គឺរួមមានទាំងសហគ្រាសដែលបាត់ខ្លួនផងដែរ។ បច្ចុប្បន្ន អគ្គនាយកដ្ឋានពន្ធដារបានខិតខំជំរុញណែនាំដល់នាយកដ្ឋានពាក់ព័ន្ធ និងសាខាពន្ធដារខេត្ត ខណ្ឌ បន្តការធ្វើសវនកម្មឱ្យបានម៉ឺងម៉ាត់ និងដាក់ទណ្ឌកម្មពិន័យតាមច្បាប់ចំពោះក្រុមហ៊ុន សហគ្រាស ដែលខកខានមិនបានមកបំពេញកាតព្វកិច្ចសារពើពន្ធ។ ចំពោះការមិនបានដាក់ទោសទណ្ឌតាមមាត្រា១២៩ បទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ អគ្គនាយកដ្ឋានពន្ធដារ នៅតែព្យាយាមប្រើប្រាស់វិធានការទន់ភ្លន់ និងបន្តអប់រំដល់អ្នកជាប់ពន្ធឱ្យអនុវត្តបំពេញកាតព្វកិច្ចសារពើពន្ធ ស្របតាមច្បាប់ស្តីពីសារពើពន្ធសិន។ កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានប្រើប្រាស់វិធានការរដ្ឋបាលជាច្រើន មានដូចជា ការឃាត់ទុកការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ មិនឱ្យបើកក្រុមហ៊ុនថ្មី និងមិនឱ្យលក់ភាគហ៊ុនជាដើម ។ល។

### ៤.៤. ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ

ច្បាប់ស្តីពីសារពើពន្ធបានកំណត់ឱ្យអ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជីលិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ នោះអ្នកជាប់ពន្ធត្រូវរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ...”។ តាមការពិនិត្យសំណុំឯកសារសវនកម្មនៃការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារលើអ្នកជាប់ពន្ធចំនួន៨៧ក្រុមហ៊ុនសហគ្រាស អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អ្នកជាប់ពន្ធចំនួន៦០ (ក្រុមហ៊ុនសហគ្រាសស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំចំនួន១៦ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារខេត្ត ខណ្ឌចំនួន៤៤) ពុំទាន់បានកាន់កាប់ កត់ត្រា និងថែរក្សាទុកកិច្ចបញ្ជិកាគណនេយ្យ និងលិខិតយុត្តិការឱ្យបានត្រឹមត្រូវស្របតាមច្បាប់ស្តីពីសារពើពន្ធនៅឡើយ ដែលជាហេតុនាំឱ្យរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ។ ករណីនេះ កន្លងមកអគ្គនាយកដ្ឋានពន្ធដារតែងតែធ្វើការអប់រំ ផ្សព្វផ្សាយ និងណែនាំដល់អ្នកជាប់ពន្ធទាំងអស់តាមរយៈការធ្វើសិក្ខាសាលា ដើម្បីជំរុញការអប់រំអ្នកជាប់ពន្ធឱ្យមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីកាតព្វកិច្ចសារពើពន្ធ ការអនុវត្តច្បាប់ពន្ធដារ និងការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ជាមួយគ្នានេះ ក្រុមប្រឹក្សាជាតិគណនេយ្យ ក៏កំពុងជំរុញការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យនេះដែរ។

### ៤.៥. របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ

សហគ្រាសវិនិយោគទាំងឡាយ ដែលបានធ្វើសកម្មភាពអាជីវកម្ម មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនជូនសវនករឯករាជ្យសម្រាប់ធ្វើសវនកម្មស្របទៅតាមច្បាប់ដែលបានកំណត់ចំពោះសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យពីរក្នុងចំណោមលក្ខណៈវិនិ

ថ្ឋ័យបីគឺ (១)ផលរបរប្រចាំឆ្នាំរបស់សហគ្រាសមានចំនួនចាប់ពីបីពាន់លានរៀលឡើងទៅ (២) ទ្រព្យសកម្មសរុបមានតម្លៃចាប់ពីពីរពាន់លានរៀលឡើងទៅ (៣) និយោជិកបម្រើការងារមានចំនួនចាប់ពីមួយរយនាក់ឡើងទៅ និងរាល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយបានចុះឈ្មោះនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពោលគឺសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យដូចនេះត្រូវមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ។ តាមការពិនិត្យសំណុំឯកសារសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនសហគ្រាសមួយចំនួន បានបំពេញកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនឱ្យសវនករឯករាជ្យធ្វើសវនកម្ម និងក្រុមហ៊ុនសហគ្រាសមួយចំនួនទៀត មិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងប្រកាសខាងលើទេ។ កន្លងមក អគ្គនាយកដ្ឋានពន្ធដារ តែងតែបានណែនាំអ្នកជាប់ពន្ធជាប្រចាំ ហើយជាមួយគ្នានេះ ក្រុមប្រឹក្សាជាតិគណនេយ្យក៏កំពុងជំរុញដល់អ្នកជាប់ពន្ធឱ្យធ្វើរបាយការណ៍នេះ ដោយមានទាំងពិន័យតាមច្បាប់ បើមិនអនុវត្តតាម។

**៤.៦. ការប្រើប្រាស់វិក្កយបត្រ**

តាមច្បាប់ស្តីពីសារពើពន្ធគឺតម្រូវឱ្យមានការប្រើប្រាស់ ឬចេញវិក្កយបត្រចំពោះរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធ និងបុគ្គលដទៃទៀត។ ចំពោះវិក្កយបត្រអាករលើតម្លៃបន្ថែម គឺត្រូវមានចុះលេខរៀងត្រឹមត្រូវឱ្យទៅអ្នកទិញ និងត្រូវមានចុះនិទ្ទេស ដូចជា ឈ្មោះ និងលេខចុះបញ្ជីរបស់អ្នកលក់កាលបរិច្ឆេទចេញវិក្កយបត្រ ឈ្មោះអ្នកទិញ ឬនិយោជិក ឬភ្នាក់ងារអ្នកទិញ បរិមាណ សេចក្តីបរិយាយ និងថ្លៃលក់ទំនិញ ឬសេវា។ ជាងនេះទៅទៀត វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវមានអាសយដ្ឋាន លេខអត្តសញ្ញាណកម្ម "អតប" លេខវិក្កយបត្រ ថ្ងៃខែឆ្នាំចេញវិក្កយបត្រ រាយមុខទំនិញ ឬសេវា បរិមាណ ថ្លៃឯកតា ថ្លៃសរុប គោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។ តាមការធ្វើតេស្តលើលិខិតប្រកាសពន្ធ និងឯកសារភ្ជាប់ផ្សេងៗរបស់ក្រុមហ៊ុនសហគ្រាសមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៨ ក្រុមហ៊ុនសហគ្រាសមួយចំនួនបានប្រើប្រាស់ និងចេញវិក្កយបត្រពុំទាន់បានត្រឹមត្រូវតាមការណែនាំទៅឱ្យអតិថិជនរបស់ខ្លួន ដូចជា វិក្កយបត្រគ្មានលេខអត្តសញ្ញាណកម្ម "អតប" គ្មានលេខវិក្កយបត្រ គ្មានគោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងចាត់វិធានការជាបន្តបន្ទាប់ ដោយបានធ្វើការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ រៀបចំសិក្ខាសាលាណែនាំដល់អ្នកជាប់ពន្ធ ធ្វើលិខិតជូនដំណឹងពាក់ព័ន្ធនឹងការប្រើប្រាស់វិក្កយបត្រជូនដល់សហគ្រាស និងណែនាំដល់មន្ត្រីពន្ធដារពាក់ព័ន្ធគ្រប់ផ្នែកពិនិត្យមើលឱ្យបានម៉ឺងម៉ាត់ និងចាត់វិធានការមួយចំនួន ដូចជា ធ្វើកំណត់ហេតុជាមួយតំណាងសហគ្រាសឱ្យធ្វើការកែសម្រួលឡើងវិញនូវការចេញវិក្កយបត្រ ឱ្យបានត្រឹមត្រូវតាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ និងមិនអនុញ្ញាតឱ្យឥណទានអាករលើធាតុចូល ឬព្យួរការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ក្នុងករណីមិនអនុវត្តតាមវិធានវិក្កយបត្រ។

**៤.៧. ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ**

ការដាក់លិខិតប្រកាសពន្ធអាករប្រចាំខែ ប្រចាំឆ្នាំនៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងច្បាស់លាស់ ហើយបណ្ណាធិការសហគ្រាសជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់

ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ រីឯការត្រួតពិនិត្យលិខិតប្រកាសពន្ធ ជាភារកិច្ចរបស់មន្ត្រីពន្ធ។ តាមការធ្វើតេស្តលើការត្រួតពិនិត្យលិខិតប្រកាសពន្ធប្រចាំខែ និងលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំរបស់ក្រុមហ៊ុនចំនួន៧៣០នៅអង្គភាពពន្ធចំនួន២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានលិខិតប្រកាសពន្ធប្រចាំខែរបស់ក្រុមហ៊ុនមួយចំនួន គណនាពន្ធលើប្រាក់បៀវត្សមិនត្រឹមត្រូវ បន្ថាបបៀវត្សបុគ្គលិក មិនប្រកាសពន្ធកាត់ទុកលើសេវាកម្ម១៥% ប្រកាសចំណូលថេរ ប្រកាសចំណូលតិចជាងចំណាយជារៀងរាល់ខែ មិនប្រកាសពន្ធកាត់ទុកលើការជួលការិយាល័យខណៈដែលសហគ្រាសមិនមានអគារការិយាល័យដែលជាទ្រព្យសកម្មរបស់ខ្លួន។ កន្លងមក អគ្គនាយកដ្ឋានពន្ធដារតែងតែធ្វើការណែនាំជាប់ជាប្រចាំ និងតាមរយៈសិក្ខាសាលាផងដែរ ដើម្បីធ្វើការផ្សព្វផ្សាយដល់អ្នកជាប់ពន្ធឱ្យមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីកាតព្វកិច្ចសារពើពន្ធ ការអនុវត្តច្បាប់ស្តីពីសារពើពន្ធ និងការកាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ។ ម្យ៉ាងវិញទៀត អ្នកជាប់ពន្ធតែងតែសម្រុកមកដាក់លិខិតប្រកាសពន្ធប្រចាំខែ នៅថ្ងៃផុតកំណត់ការទទួលលិខិតប្រកាស ដែលធ្វើឱ្យមានភាពកកស្ទះ នាំឱ្យមន្ត្រីទទួលលិខិតប្រកាស មិនអាចពិនិត្យទិន្នន័យលើលិខិតប្រកាសពន្ធរបស់អ្នកជាប់ពន្ធបានគ្រប់ជ្រុងជ្រោយនោះឡើយ។ ប៉ុន្តែបន្ទាប់ពីទទួលលិខិតប្រកាសរួចហើយ មន្ត្រីទទួលបន្ទុកលិខិតប្រកាស បានធ្វើការត្រួតពិនិត្យតាមក្រោយ ករណីលិខិតប្រកាសពន្ធណាមួយដែលមានភាពមិនប្រក្រតី មន្ត្រីទទួលបន្ទុកបានអញ្ជើញតំណាងមកធ្វើការណែនាំឱ្យធ្វើការកែតម្រូវលិខិតប្រកាសឡើងវិញ និងដាក់កម្មវិធីធ្វើសវនកម្មមានកម្រិត។

### ៤.៨. ការប្រមូលពន្ធអចលនទ្រព្យ

គោលការណ៍នៃការប្រមូលពន្ធលើអចលនទ្រព្យបានតម្រូវឱ្យម្ចាស់អចលនទ្រព្យបំពេញព័ត៌មានអចលនទ្រព្យ ចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធ។ តាមការធ្វើតេស្តនៅសាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តចំនួន១៦ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អចលនទ្រព្យមួយចំនួននៅមិនទាន់បានបង់ពន្ធអចលនទ្រព្យសម្រាប់ឆ្នាំ២០១៨។ អគ្គនាយកដ្ឋានពន្ធដារ នៅមានបញ្ហាប្រឈមមួយចំនួន ដូចជា កង្វះខាតទិន្នន័យអចលនទ្រព្យ ខ្វះមន្ត្រី និងខ្វះការសហការពីម្ចាស់អចលនទ្រព្យ។

### ៤.៩. ការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានបញ្ជាក់ថា នាយកដ្ឋានច្បាប់ និងទំនាក់ទំនងសាធារណៈមានតួនាទីនិងភារកិច្ចពិនិត្យកំណត់ហេតុបទល្មើសគយ លើកសំណើសម្រុះសម្រួល និងសម្រេចវិនិច្ឆ័យលើបទល្មើសគយ និងវិវាទផ្សេងទៀតជូនអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាពិនិត្យ និងសម្រេច និងប្រកាសស្តីពីការសម្រុះសម្រួលបទល្មើសគយ ត្រង់ប្រការ៤ បានបញ្ជាក់ថា ប្រសិនបើក្នុងរយៈពេលកៅសិប(៩០)ថ្ងៃ គិតពីកាលបរិច្ឆេទក្នុងកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុគយផ្សេងទៀត សេចក្តីសម្រេចជាផ្លូវការស្តីពីការសម្រុះ

សម្រួលនូវបទល្មើសគយមិនអាចទៅបាន រដ្ឋបាលគយត្រូវបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច។ ជាក់ស្តែង នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ មានកំណត់ហេតុល្មើសច្បាប់គយចំនួន ៤១០ករណី ក្នុងនោះកំណត់ហេតុល្មើសច្បាប់ចំនួន៣៧១ករណី បានធ្វើសេចក្តីសម្រេចវិនិច្ឆ័យរួច (បូករួមកំណត់ហេតុសល់ឆ្នាំ២០១៧) និងនៅសល់កំណត់ហេតុល្មើសចំនួន១៦៦ករណីទៀត នៅពុំទាន់បានធ្វើការដោះស្រាយ និងមានវិធានការសមស្របនៅឡើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា នាយកដ្ឋានកិច្ចការច្បាប់និងទំនាក់ទំនងសាធារណៈនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាតែងតែខិតខំរិះរកមធ្យោបាយសម្រុះសម្រួលបទល្មើសគយ ដូចមានចែងក្នុងបញ្ញត្តិមាត្រា៧៧ នៃច្បាប់ស្តីពីគយ ដែលការសម្រុះសម្រួលនេះអាចធ្វើទៅបាន នៅមុនពេលមានសាលក្រមរបស់តុលាការមានសមត្ថកិច្ចប៉ុណ្ណោះ។ ទំនិញដែលនៅសល់ក្នុងឆ្នាំ២០១៨ រហូតមកដល់ត្រឹមខែកញ្ញា ឆ្នាំ២០១៩ ភាគច្រើនគឺម្ចាស់ទំនិញគ្មានលទ្ធភាពបង់ពន្ធអាករ រួមមាន៖ យានយន្តចង្កូតឆ្វេង ទោចក្រយានយន្ត ម៉ាស៊ីនភ្លើង ទំនិញចម្រុះមួយចំនួន និងទំនិញជាប់កម្រិតកំណត់ មានជាអាទិ៍ រថយន្តចង្កូតស្តាំ ឈើ ជាដើម។

**៤.១០. ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការបិទបញ្ជីចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូលចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៨ ត្រង់ចំណុច៤ អំពីការបិទបញ្ជីចំណូលចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៨ បានបញ្ជាក់ថា ប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ (ភាគទី III និងមាត្រា១០៦នៃអនុក្រឹត្យលេខ៨២ អនក្រ.បកចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥)។ ដូចនេះ ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ជាកំហិត។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (នាយកដ្ឋានចំណូលសាធារណៈ) មានសមតុល្យតួលេខចំណូលមិនមែនសារពើពន្ធ (រដ្ឋបាលកណ្តាល) នៅសល់ចុងឆ្នាំ២០១៨ ចំនួន ២ ៨០២លានរៀល មិនទាន់បានបង្វែរចូលថវិការដ្ឋនៅឡើយទេ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានការយឺតយ៉ាវក្នុងការបង់ចំណូលដែលមានទឹកប្រាក់ចំនួន ២ ៨០២,៥លានរៀល។ ប៉ុន្តែចំណូលនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានបង់ និងកត់ត្រាជាចំណូលក្នុងឆ្នាំ២០១៩ រួចហើយ។ ក្នុងលទ្ធផលនៃការអនុវត្តចំណូលឆ្នាំ២០១៨ ក៏មានចំណូលប្រមូលបាននៅឆ្នាំ២០១៧ ដែលយកមកបង់ និងកត់ត្រាជាចំណូលក្នុងឆ្នាំ២០១៨ ចំនួន ៣ ២០៤,៥លានរៀល ផងដែរ។ យោងតាមមាត្រា៤ នៃអនុក្រឹត្យលេខ១២៥ សហវ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ បានតម្រូវឱ្យក្រសួងស្ថាប័នដែលចំណូលមិនមែនសារពើពន្ធ ត្រូវចាត់តាំងរដ្ឋលេខាធិការមួយរូប ដើម្បីចូលរួមជាសមាជិក(គ.ម.ព.)ដែលត្រូវទទួលបន្ទុកគ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងបូកសរុបការប្រមូល ការកត់ត្រា ការកៀរគរចំណូល

និងការចាត់វិធានការ នៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់សាមីក្រសួង ស្ថាប័ន។ (គ.ម.ព.) មានភារកិច្ច ពិនិត្យ តាមដាន បូកសរុប វាយតម្លៃ និងស្នើសុំវិធានការពីប្រមុខរាជរដ្ឋាភិបាល។ យោងតាម សារាចរណែនាំលេខ០១០ សហវ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការអនុវត្តច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវវិធានការ សំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលជំរុញឱ្យ ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានការទទួលខុសត្រូវក្នុងការកត់ត្រា ការតាមដាន ការកៀរគរចំណូល ការបង់ចំណូល និងការតឹងទារបំណុលមិនមែនសារពើពន្ធ។ សារាចរណែនាំនេះ ក៏បានលើកឡើងអំពីការចាត់វិធានការរដ្ឋបាល និងតុលាការ ចំពោះមន្ត្រីសាធារណៈ ណាដែលបានប្រព្រឹត្តកំហុសឆ្គងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យទទួលទោសតាមច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងទទួលតាមកម្រិតទោសទណ្ឌនៃក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ។ មួយវិញទៀត នៅក្នុងខែកញ្ញា ឆ្នាំ២០១៨ អទច បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យលេខ៧២អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធជូនដល់គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងចំណូល មិនមែនសារពើពន្ធឱ្យកាន់តែមានប្រសិទ្ធភាព។

**៤.១១.ការទូទាត់ និងការកត់ត្រាចំណាយ**

ជាគោលការណ៍ ការបញ្ជូនអាណត្តិបើកប្រាក់ទៅអគ្គនាយកដ្ឋានរតនាគារជាតិត្រូវបញ្ឈប់ការ ទទួលអាណត្តិបើកប្រាក់ឆ្នាំ២០១៨ ត្រឹមវេលាម៉ោង១៧ និង៣០នាទីនាថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើកប្រាក់ (សម្រាប់រដ្ឋបាលកណ្តាល) មួយចំនួន ត្រូវបានបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការទូទាត់នៅក្រោយថ្ងៃកំណត់បិទបញ្ជី (អំឡុងពេលខែកុម្ភៈ ឆ្នាំ២០១៩) ហើយបានកត់ត្រាជាចំណាយថវិកាប្រចាំឆ្នាំ២០១៨ មានចំនួន ៤ ៨៥៤អាណត្តិបើកប្រាក់ ស្មើនឹងទឹកប្រាក់ចំនួន ២ ២០២ ៣១៩ ៩០៦ ៦៣២ រៀល (អាណត្តិ បើកប្រាក់ជាប្រាក់រៀលមានចំនួន៤ ៧៥២អាណត្តិបើកប្រាក់ ស្មើនឹង ១ ៩៦៥ ៤៧១ ៨៥៥ ៧៧០រៀល និងអាណត្តិបើកប្រាក់ជាដុល្លារមានចំនួន១០២អាណត្តិបើកប្រាក់ ស្មើនឹងទឹកប្រាក់ ចំនួន២៣៦ ៨៤៨ ០៥០ ៨៦២រៀល)។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា នៅ រៀងរាល់ដំណាច់ឆ្នាំនីមួយៗ គឺមានការបញ្ជូនអាណត្តិបើកប្រាក់ក្នុងចំនួនច្រើន មកអគ្គនាយកដ្ឋាន រតនាគារជាតិ ដោយមានភាពយឺតយ៉ាវ និងមិនទាន់ពេលវេលានៃកាលបរិច្ឆេទកំណត់តាមសារាចរ ណែនាំស្តីពីការបិទបញ្ជីចំណូលចំណាយថវិកាប្រចាំឆ្នាំ ជាពិសេសគឺនៅក្នុងខែធ្នូ ឆ្នាំ២០១៨។ ដោយឡែកបើពិនិត្យប្រភេទអាណត្តិបើកប្រាក់ទាំងនោះគឺមានអាណត្តិនិយ័តកម្មមួយចំនួន (អាណត្តិ ទូទាត់ប្រាក់បុរេប្រទាន និងអាណត្តិទូទាត់ប្រាក់រដ្ឋទេយ្យបុរេប្រទាន) ដែលចាំបាច់ត្រូវទូទាត់ជម្រះបញ្ជី ក្នុងឆ្នាំថវិកា២០១៨ ដើម្បីបិទបញ្ជីដោយកត់ត្រាចំណាយថវិកាឱ្យបានពេញលេញ និងបង្ការកុំឱ្យ មានការលំបាកច្រើនដល់កិច្ចទូទាត់ជម្រះបញ្ជីនៅឆ្នាំបន្តបន្ទាប់។ម្យ៉ាងទៀត រយៈពេលនេះគឺស្ថិតនៅ

ក្នុងរយៈពេលបំពេញបន្ថែមសម្រាប់ប្រតិបត្តិការនិយ័តកម្មនៃរតនាគារ។ បន្ថែមពីលើនេះ តាមលិខិតលេខ៣៧៥ អរតន ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំណត់កាលបរិច្ឆេទបញ្ឈប់ការទទួលអាណត្តិបើកប្រាក់នៅអគ្គនាយកដ្ឋានរតនាគារជាតិ ត្រឹមវេលាម៉ោង១៧ និង៣០នាទី នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ ដើម្បីសម្រួលដល់ការទូទាត់ចំណាយចាំបាច់ និងការទូទាត់ជម្រះបញ្ជីប្រតិបត្តិការចំណាយក្នុងឆ្នាំថវិកា២០១៨ និងដើម្បីជៀសវាងការបង្គរបន្ទុកចំណាយទៅឆ្នាំថវិកា២០១៨ និងឆ្នាំបន្តបន្ទាប់។

## ៤.១២. ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់

ដើម្បីធានាបាននូវការទទួលខុសត្រូវក្នុងការអនុវត្តចំណាយថវិការដ្ឋ អគ្គនាយកដ្ឋានរតនាគារជាតិ ដែលជាគណនេយ្យករសាធារណៈមានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវនៃការអនុវត្តចំណាយថវិការដ្ឋ។ ការអនុវត្តតួនាទីនេះបានគត់មុត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ចំណាយថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ តម្រូវឱ្យក្រសួងស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវភ្ជាប់លិខិតយុត្តិការជាមួយនឹងអាណត្តិបើកប្រាក់សម្រាប់ទូទាត់ចំណាយ ដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ ដូចជា៖ កិច្ចសន្យាលទ្ធកម្ម ដែលមានពន្ធប្រថាប់ត្រា និងបណ្ណប៉ាតង់ដែលប្រភេទអាជីវកម្មត្រូវស្របតាមការផ្គត់ផ្គង់ជាដើម។ល។ តាមការធ្វើតេស្តលើអាណត្តិបើកប្រាក់ចំនួន១៧៣ របស់ក្រសួងស្ថាប័នមួយចំនួន ដែលទទួលបានការយល់ព្រមទូទាត់ដោយអគ្គនាយកដ្ឋានរតនាគារជាតិ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើកប្រាក់មួយចំនួនមិនបានភ្ជាប់នូវឯកសារគាំទ្រត្រឹមត្រូវ ដូចជា ប្រភេទអាជីវកម្មរបស់អ្នកផ្គត់ផ្គង់មិនសមស្របតាមកម្មវត្ថុនៃការចំណាយ (ប្រភេទអាជីវកម្មមិនត្រូវតាមការផ្គត់ផ្គង់) កិច្ចសន្យាលទ្ធកម្មមិនបានប្រថាប់ត្រា និងប្រថាប់ត្រាក្រោយកាលបរិច្ឆេទក៏ដោយ ក៏អគ្គនាយកដ្ឋានរតនាគារជាតិឯកភាពទូទាត់ឱ្យដែរ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា អាស្រ័យដោយនៅកៀកដំណាច់ឆ្នាំថវិកា២០១៨ មានការបញ្ជូនអាណត្តិបើកប្រាក់គំហុកច្រើនមកអគ្គនាយកដ្ឋានរតនាគារជាតិ ហើយក្នុងនោះអាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្មមួយចំនួន មានបញ្ហាខ្វះចន្លោះមិនត្រឹមត្រូវតាមនីតិវិធីនៃការទូទាត់។ ផ្អែកតាមសារាចរណែនាំលេខ០០៦សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានរតនាគារជាតិបានយកចិត្តទុកដាក់ពង្រឹងការត្រួតពិនិត្យអាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្ម ដើម្បីមានមូលដ្ឋានក្នុងការទូទាត់ចំណាយថវិកាដោយផ្អែកលើកំណត់ហេតុប្រគល់ ទទួល ឬកំណត់ហេតុវាយតម្លៃលទ្ធផលការងាររបស់គណៈកម្មការលទ្ធកម្ម ដែលបញ្ជាក់អំពីភាពត្រឹមត្រូវ និងច្បាស់លាស់លើទំនិញ ឬសេវាដែលបានបំពេញរួច។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរតនាគារជាតិបានណែនាំដល់ក្រសួង ស្ថាប័ន ក៏ដូចជាអ្នកផ្គត់ផ្គង់ឱ្យបំពេញបន្ថែមនូវសក្ខីបត្រចំណាយឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ដូចជា៖ ការបង់ពន្ធប៉ាតង់បន្ថែមឱ្យស្របតាមប្រភេទអាជីវកម្ម និងការបង់ពន្ធប្រថាប់ត្រាលើកិច្ចសន្យាជាដើម។ កត្តានេះ ក៏បានរួមចំណែកក្នុងការប្រមូលពន្ធបង់ចូលថវិការដ្ឋផងដែរ។ ទោះបីជាយ៉ាងនេះក៏ដោយ ដោយសារកត្តាពេលវេលា

និងការមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ពីដើមទី ក៏មាននៅសល់បញ្ហាខ្វះចន្លោះមួយចំនួនដែលតម្រូវឱ្យមានកិច្ចសហការចូលរួមពង្រឹងបន្ថែមពីសាមីក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធចាប់ពីដើមទីនៅដំណាក់កាលអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងដំណាក់កាលរៀបចំលិខិតយុត្តិការចំណាយបោះផ្សាយអាណត្តិបើកប្រាក់។

**៤.១៣. ការផ្ញើរបាយការណ៍លទ្ធកម្មមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ត្រង់មាត្រា២៣ បានបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍លទ្ធកម្មប្រចាំខែមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។ សារាចរណែនាំលេខ០០២សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី២៤ បានបញ្ជាក់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មរបស់ខ្លួនប្រចាំត្រីមាស ឆមាស និងឆ្នាំ (តាមគំរូដែលបានកំណត់) មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់នៅរៀងរាល់ចុងសប្តាហ៍ទី១ខែមេសា ខែកក្កដា ខែតុលា និងខែមករា។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា នៅក្នុងឆ្នាំ២០១៨ មានក្រសួងស្ថាប័នចំនួន៩មិនបានផ្ញើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ និងសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈចំនួន៦ អង្គភាពក្នុងចំណោមសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈចំនួន៣៨ នៅមិនទាន់បានផ្ញើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំមកអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៅឡើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា តាមរយៈប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម ត្រង់ប្រការ៣៧ បានកំណត់ថា "ស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកា ត្រូវផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើការក្រើនរំលឹកជូនស្ថាប័នអនុវត្តលទ្ធកម្មឱ្យផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០១៨ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈលិខិតលេខ២១៨ សហវ.អលសា និងលិខិតលេខ២៣០ សហវ.អលសា ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីសំណើសុំផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ២០១៨ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៤.១៤. ការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ**

រាជរដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដោយបានបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជារៀងរាល់ឆ្នាំឱ្យបានត្រឹមត្រូវគ្រប់ចំនួន និងចប់សព្វគ្រប់នៅក្នុងត្រីមាសទី១នៃឆ្នាំបន្ទាប់។ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវអនុវត្តតាមទម្រង់ដូចជា តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋដែលត្រូវធ្វើឡើងក្នុងឆ្នាំនីមួយៗ ក្នុងចន្លោះរយៈពេល០៥(ប្រាំ) ឆ្នាំនៃឆ្នាំគោល។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួននៅតែមានការយឺតយ៉ាវក្នុងការធ្វើបញ្ជីសារពើភណ្ឌឆ្នាំ

គោល ហើយខ្លះទៀតយឺតយ៉ាវក្នុងការរៀបចំតារាងប្រៀបធៀបការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋដែលមានដូចជា៖ ក្រសួង ស្ថាប័នថ្នាក់កណ្តាលចំនួន៣៦ ស្មើនឹង២៤៤អង្គភាព ក្នុងនោះមានអង្គភាពចំនួន១៦៣ បានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋ ប៉ុន្តែនៅសល់ចំនួន៨១អង្គភាពទៀតមិនបានផ្ញើ។ មន្ទីរជំនាញជុំវិញរាជធានី ខេត្តមានអង្គភាពចំនួន៧៦៩ ក្នុងនោះមានអង្គភាពចំនួន៦៦៥ បានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋ ប៉ុន្តែនៅសល់អង្គភាពចំនួន១១៣ទៀតមិនបានផ្ញើ។ រដ្ឋបាលថ្នាក់ក្រោមជាតិរាជធានី ខេត្ត មានអង្គភាពចំនួន២៥ ក្នុងនោះមានអង្គភាពចំនួន២៣ បានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋ ប៉ុន្តែនៅសល់អង្គភាពចំនួន២ទៀតមិនបានផ្ញើ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌនៃរាជធានី ខេត្ត មានអង្គភាពចំនួន២០៣ ក្នុងនោះមានអង្គភាពចំនួន១១៤ បានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋ ប៉ុន្តែនៅសល់អង្គភាពចំនួន៨៩ទៀតមិនបានផ្ញើ។ រដ្ឋបាលឃុំ សង្កាត់នៃរាជធានី ខេត្ត មានអង្គភាពចំនួន ១ ៦៤៦ ក្នុងនោះមានអង្គភាពចំនួន៨០២ បានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋ ប៉ុន្តែនៅសល់អង្គភាពចំនួន៨៤៤ទៀតមិនបានផ្ញើ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តែងតែចេញលិខិតជំរុញជារៀងរាល់ឆ្នាំ ហើយការរៀបចំបញ្ជីឆ្នាំ២០១៨ កសហវ បានចេញលិខិតជម្រាបទៅអាជ្ញាធរកាន់កាប់ ដែលជាក្រសួងស្ថាប័នថ្នាក់កណ្តាល តាមរយៈលិខិតលេខ១២១០៧ សហវ.អទច និងទៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈលិខិតលេខ ១២១០៨ សហវ.អទច ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨។ ដោយឡែកថ្មីៗនេះ កសហវ ទើបតែចេញលិខិតជំរុញជាថ្មី (កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩) ទៅអាជ្ញាធរកាន់កាប់ដែលមិនទាន់បានផ្តល់បញ្ជីមក កសហវ ដូចជាក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គភាពប្រឆាំងអំពើពុករលួយ ព្រមទាំងជម្រាបទៅមន្ទីរសហវ រាជធានីខេត្ត ឱ្យជួយផ្សព្វផ្សាយនៅថ្នាក់ក្រោមជាតិ មុននឹងឈានទៅដល់ការចាត់វិធានការ។

### ៤.១៥. ការធ្វើបណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ

រាជរដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើទ្រព្យសម្បត្តិរដ្ឋ ជាអចលនវត្ថុទាំងអស់ ស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួនឱ្យបានឆាប់រហ័ស និងតាមពេលវេលាកំណត់ដោយសហការជាមួយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ ត្រូវបញ្ចូលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលរៀបចំរួចទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធានាបាននូវភាពគង់វង្ស និងភាពស្របច្បាប់នៃទ្រព្យសម្បត្តិទាំងឡាយនោះ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងស្ថាប័នចំនួន១០ ដែលមានអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋចំនួន៥០

មានទីតាំងចំនួន១១ (អង្គភាពប្រើប្រាស់ចំនួន១១) មិនទាន់មានបណ្ណកម្មសិទ្ធិ និងមន្ទីរជំនាញជុំវិញរាជធានីខេត្តចំនួន៧ មានអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋចំនួន១២៨ ដែលមានទីតាំងចំនួន៦៥៦ ក្នុងនោះទីតាំងចំនួន៣០៥ នៅតែពុំទាន់បានធ្វើបណ្ណសម្គាល់កម្មសិទ្ធិនៅឡើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តែងតែចេញលិខិតជំរុញជារៀងរាល់ឆ្នាំ។ ចំណែកការរៀបចំបញ្ជីឆ្នាំ២០១៨ កសហវ បានចេញលិខិតជម្រាបទៅអាជ្ញាធរកាន់កាប់ ដែលជាក្រសួងស្ថាប័នថ្នាក់កណ្តាល តាមរយៈលិខិតលេខ១២១០៧ សហវ.អទច និងទៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈលិខិតលេខ១២១០៨ សហវ.អទច ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ដោយបានបញ្ជាក់អំពីការរៀបចំធ្វើបណ្ណកម្មសិទ្ធិផងដែរ។ ចំពោះការយឺតយ៉ាវគឺដោយសារអាជ្ញាធរកាន់កាប់ខ្វះថវិកាក្នុងការរៀបចំ។ ប៉ុន្តែថ្មីៗនេះ រាជរដ្ឋាភិបាលបានសម្រេចជាគោលការណ៍ឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កែសម្រួលប្រកាសរួម ដើម្បីលើកលែងការយកកំរៃសេវាសាធារណៈលើការធ្វើបណ្ណកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ដីគ្រឹះស្ថានសាធារណៈរដ្ឋបាល និងគរុភណ្ឌជាដីវត្ត តាមរយៈប្រកាសរួមលេខ៣៥៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ បានបង្ហាញឱ្យឃើញនូវការខិតខំប្រឹងប្រែងពុះពាររបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រត្រឹមត្រូវស្របតាមសភាពការណ៍ជាក់ស្តែង ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពរីកចម្រើន និងគត់មត់ពីមួយឆ្នាំទៅមួយឆ្នាំ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។ សមិទ្ធផលទាំងនេះ មានប្រសិទ្ធភាពបំផុតសម្រាប់ឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ និងបានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ និងឥតងាករេរបស់រាជរដ្ឋាភិបាល ក្នុងការបន្តរក្សានូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការបន្តពង្រឹង និងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ ការបន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច និងការធានាបាននូវភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីសម្រេចបាននូវគោលដៅជាសារវ័ន្តនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ព្រមទាំងការកាត់បន្ថយភាពក្រីក្រ និងបានផ្តល់នូវមធ្យោបាយ និងធនធានសមស្របដល់ក្រសួង ស្ថាប័ន ជាពិសេសការបង្កើនល្បឿននៃការអភិវឌ្ឍ ការលើកកម្ពស់ប្រសិទ្ធភាពសេវាសាធារណៈ និងការចូលរួមដោះស្រាយបញ្ហាជាច្រើនទៀតរបស់ជាតិ និងប្រជាជន រួមមាន ការបន្តដំឡើងបៀវត្សជូនមន្ត្រីរាជការទូទៅ ការបន្តគាំទ្រការវិនិយោគចាំបាច់នានា ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចដោយឈរលើគោលការណ៍ប្រសិទ្ធភាព ទាំងក្នុងកម្រិតវិភាជ និងទាំងក្នុងកម្រិតប្រតិបត្តិការ និងបច្ចេកទេស។

តាមរយៈការផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្មនានាបានយកចិត្តទុកដាក់ខិតខំអនុវត្តកែលម្អនូវអនុសាសន៍សវនកម្មបានល្អប្រសើរ។ អាជ្ញាធរសវនកម្ម

ជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតនានាឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ហើយជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗជាបន្តទៅទៀត ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានកាន់តែល្អប្រសើរថែមទៀត។

ក្នុងបរិបទនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើរបាយការណ៍គោរពជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លើលទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុ ដែលបានរកឃើញនូវកំហុសឆ្គងរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ និងបានធ្វើលិខិតចាត់វិធានការវិន័យរដ្ឋបាល ដើម្បីកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរកឃើញក្នុងការគ្រប់គ្រង ការប្រើប្រាស់ចំណូលចំណាយថវិការដ្ឋ ចំណូលមិនមែនសារពើពន្ធ កាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពតាមនីតិវិធីហិរញ្ញវត្ថុ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ហើយបានចម្លងជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរសវនកម្មជាតិ ដើម្បីចាត់ការបន្ត។

ទន្ទឹមនឹងនេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយនឹងបន្តចូលរួមផ្តល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឱ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយសីលធម៌វិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាពសវនកម្មឱ្យស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្តង់ដារតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។